**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# អង្គការអយ្យការក្នុងរឿងក្តីព្រហ្មទណ្ឌ នៅសាលាដំបូង

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ញ៉ិល ចន្ធា**
កញ្ញា **នូ ឌឹង**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៧ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៨
ឆ្នាំសរសេរសារណា ២០២២

## **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីររូបឈ្មោះ **នូ ឌីង** និង ឈ្មោះ **ញិល ចន្ធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី ៤ ជំនាន់ទី ២៧ ក្រុម **L4B1** ក្នុងឆ្នាំសិក្សា ២០១៨~២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

## **យើងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

លោកឪពុកឈ្មោះ **វ៉ាន់ចាស នូ**, អ្នកម្តាយឈ្មោះ **ឌឿង យ៉ុយ** និង លោកឪពុកឈ្មោះ **ញិល យ៉ុន**, អ្នកម្តាយឈ្មោះ **ម៉ុក ស្រាន់** ។ កូនសូមអនុញ្ញាតសម្តែងនូវការរំលឹកដឹងគុណ ចំពោះលោកអ្នកមានគុណដ៏ធំធេងលើសលប់ដែលមិនអាចកាត់ថ្លៃបានរបស់លោកឪពុក និងអ្នកម្តាយដែលបានផ្តល់នូវកំណើត ហើយខិតខំថ្នាក់ថ្នមចិញ្ចឹមបីបាច់ ថែរក្សាកូនតាំងពីតូចរហូតដល់ធំដឹងក្តី និងព្រមទាំងបានផ្គត់ផ្គង់ទៅលើការសិក្សាទាំងសម្ភារៈសម្លៀកបំពាក់ និងថវិកា សម្រាប់ចំណាយទៅលើការសិក្សា តាំងពីថ្នាក់បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ រហូតដល់បានរៀនចប់ថ្នាក់មហាវិទ្យាល័យថែមទៀតផង។ តាំងពីកូនកើតដឹងក្តី រហូតមកដល់ពេលនេះ គឺកូនតែងតែរស់នៅក្រោមការផ្គត់ផ្គង់របស់ឪពុកម្តាយនៅឡើយទេ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការរស់នៅដោយពឹងផ្អែកទៅលើខ្លួនឯងទាំងស្រុងនោះទេ។ បន្ថែមលើសពីនេះទៅទៀត គឺលោកមានគុណទាំងពីរ គឺតែងតែ អប់រំទូន្មានប្រៀនប្រដៅបានផ្តល់នូវដំបូន្មានល្អៗ គឺបានជម្រុញលើកទឹកចិត្តកូនគ្រប់ពេលវេលា និងជួយថែរក្សាការពារកូនៗគ្រប់គ្នា ដោយអស់ពីកម្លាំងកាយចិត្តរបស់លោកអ្នកមានគុណទាំងទ្វេ ដើម្បីចង់ឲ្យកូនក្លាយទៅជាមនុស្សដែលមានចំណេះ និងជំនាញជ្រៅជ្រះ មានសមត្ថភាពខ្ពស់ប្រកបទៅដោយ គុណធម៌ និងមានសុជីវធម៌ប្រពៃថ្លៃថ្លា។ ជាការពិតណាស់កូនៗពិតជាមិនអាចបំភ្លេចនូវគុណតម្លៃដ៏ខ្ពង់ខ្ពស់ និងថ្លៃថ្លា ដែលអ្នកមានគុណទាំងពីរបានផ្តល់ចំពោះកូនទាំងពីរបានឡើយ។

លើសពីនេះទៅទៀតក្រុមយើងខ្ញុំសូមថែងអំណរគុណ **ក្រសួងអប់រំ យុវជន និងកីឡា** ដែលបានផ្តល់អាហារូបករណ៍ ១០០% ដល់នាងខ្ញុំទាំងពីរនាក់ ក្នុងការសិក្សាបរិញ្ញាបត្រនីតិសាស្ត្រ ដែលមានរយៈពេល ៤ ឆ្នាំកន្លងមកនេះ រហូតដល់បានជោគជ័យ។ ឆ្លៀតឱកាសនេះដែរ នាងខ្ញុំឈ្មោះ **នូ ឌីង** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅដល់អង្គការ CLEW (អង្គការអប់រំផ្នែកច្បាប់ដើម្បីស្ត្រីកម្ពុជា) ជាម្ចាស់ជំនួយ ដែលបានផ្តល់អាហារូបករណ៍ជាកន្លែងកន្លែងស្នាក់នៅ និងការចំណាយផ្សេងៗក្នុងការចាយវាយប្រចាំថ្ងៃផងដែរ។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ ដែលបានខិតខំប្រឹងប្រែងជួយបង្ហាត់បង្រៀនអស់ពីសមត្ថភាព ទាំងកម្លាំងកាយចិត្ត និងជួយពង្រឹងគុណភាពក៏ដូចជាការដឹកនាំ ក្នុងស្ថាប័ន ក្នុងកម្មវិធីសិក្សាទៅដល់និស្សិតលើគ្រប់ជំនាញទាំងអស់ នៅក្នុងសាកលវិទ្យាល័យ ប្រកបទៅដោយប្រសិទ្ធិភាពខ្ពស់បំផុត និង

ទទួលបានពុទ្ធិមួយឲ្យពិតប្រាកដ សម្រាប់បន្តវេនក៏ដូចជាសសរទ្រូងដល់ប្រទេសជាតិអោយមានការអភិវឌ្ឍទៅមុខ។

**លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកច្បាប់នេះ ។ ប្រសិនបើគ្មានវត្តមានលោកគ្រូសាស្ត្រាចារ្យណែនាំ ក្នុងការជួយជ្រោមជ្រែង ផ្តល់ជាមតិយោបល់ និងជួយតម្រង់ទិសទេនោះ ក៏ក្រុមយើងខ្ញុំមិនអាចដំណើរការក្នុងការសរសេរសារណានេះទៅមុខទៀតបាននោះទេ។ ដូច្នេះ លោកគ្រូសាស្ត្រចារ្យណែនាំ គឺពិតជាដើរតួនាទីដ៏សំខាន់ នៅក្នុងការជួយត្រួសត្រាយផ្លូវ និងវិធីសាស្ត្រល្អៗមួយចំនួន ដែលអាចឱ្យក្រុមយើងខ្ញុំ យល់កាន់តែស៊ីជម្រៅទៅលើប្រធានបទមួយនេះ ជាពិសេសបានបំផុសគំនិតទៅដល់ក្រុមយើងខ្ញុំកាន់តែច្រើនក្នុងការសរសេរ ទើបបានធ្វើឲ្យការតាក់តែងសរសេរបញ្ចប់សារណាមួយនេះ កាន់តែមានភាពរលូនរហូតដល់ទទួលបានជោគជ័យ។

**សិស្សច្បង និងមិត្តនិស្សិតរួមជំនាន់** ដែលបានជួយជ្រោមជ្រែង ក៏ដូចជាបានជួយលើកទឹកចិត្តមិនថាក្នុងម៉ោងសិក្សា ឬក្រៅម៉ោងសិក្សា ហើយថែមទាំងចេះសហការគ្នាក្នុងគ្រាលំបាក និងមានទំនាក់ទំនងល្អចំពោះគ្នាទៅវិញទៅមក ។ លើសពីនេះ រៀមច្បងក៏បាន ធ្វើការចែករំលែកអំពីបទពិសោធន៍ល្អៗ ដែលគាត់ធ្លាប់បានឆ្លងកាត់ ហើយក៏បានផ្តល់ជា គំនិត មតិយោបល់ល្អៗ នៅក្នុងដំណើរការសរសេរសារណានេះឲ្យកាន់តែច្បាស់លាស់បន្ថែមទៀត។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមអនុញ្ញាត លំអោនកាយគោរព និងលើកហត្ថាទាំងទ្វេប្រណម ដោយចេញពីដួងចិត្ត សូមថ្លែងអំណរគុណទៅដល់អ្នកទាំងអស់គ្នា ដែលបានរៀបរាប់ខាងនូវលើនេះ សូមអោយមានសុខភាពល្អបរិបូរណ៍ មានរាងកាយមាំមួន ហើយសូមឲ្យទទួលបានជោគជ័យក្នុងការប្រកបរបរការងាររកស៊ី ធ្វើអាជីវកម្មផ្សេងៗ ព្រមទាំងសូមឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ជាកិច្ចចាប់ផ្តើម បន្ទាប់ពីបានឆ្លងកាត់ការសិក្សាទៅលើជំនាញផ្នែកច្បាប់រយៈពេលកន្លងមកនេះ ដែលសិក្សានៅសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុមយើងខ្ញុំ បានមានចំណាប់អារម្មណ៍ទៅលើប្រធានបទមួយដែលនិយាយអំពីៈ **អង្គការអយ្យការក្នុងរឿងក្តីព្រហ្មទណ្ឌ នៅសាលាដំបូង** ដែលជាប្រធានបទដ៏មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់អ្នកសិក្សាលើជំនាញច្បាប់ផ្ទាល់ និងសម្រាប់និស្សិតនៅជំនាន់ក្រោយៗ ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមទៅលើប្រធានបទមួយនេះ ។

សារណានេះគឺ កើតចេញពីកិច្ចខិតខំប្រឹងប្រែង ក្នុងការសិក្សាស្រាវជ្រាវ នៃក្រុមរបស់យើងខ្ញុំ ដែលបានខិតខំសម្រិតសម្រាំង ស្រាវជ្រាវ ដោយចំណាយអស់រយៈពេលបីខែ ក្នុងការចងក្រងសៀវភៅសារណានេះ។ បន្ថែមពីនេះទៅទៀត សារណានេះអាចមានភាពរលូនទៅបាន ក៏ដោយសារមានការសហការចូលរួមផ្តល់ជាមតិយោបល់ ពីអ្នកជំនាញផ្នែកច្បាប់ ជាពិសេសនោះគឺក៏មានការចូលរួមពីលោកគ្រូសាស្ត្រាចារ្យណែនាំផងដែរ។ កត្តាទាំងនេះហើយ ដែលធ្វើឲ្យក្រុមយើងខ្ញុំ មានកម្លាំងចិត្ត និងមានយុត្តិសាស្ត្រនៅក្នុងការសរសេររហូតដល់ទទួលបានជោគជ័យ។ កម្រងសារណានេះ គឺគ្រាន់តែជាផ្នែកមួយនៃការពណ៌នា អំពី អង្គការអយ្យការនៅក្នុងដំណើរការនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ តែប៉ុណ្ណោះទេ។

ជាកិច្ចបន្ទាប់ក្រុមយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះលោកគ្រូសាស្ត្រាចារ្យណែនាំឈ្មោះលោក **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យលើជំនាញផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងការយកចិត្តទុកដាក់បង្ហាត់បង្រៀន ពន្យល់ណែនាំ និងជួយជម្រុញលើកទឹកចិត្តរហូតដល់ក្រុមយើងខ្ញុំ បានសរសេរសៀវភៅសារណានេះឡើងបានដោយជោគជ័យ។

ចំពោះការសរសេរសារណាមួយនេះ ក្រុមយើងខ្ញុំ ក៏នៅមានការខ្វះចន្លោះ ហើយមិនទាន់បានសរសេរក្បោះក្បាយ និងគ្រប់ជ្រុងជ្រោយនៅឡើយនោះទេ។ ហេតុដូច្នេះហើយ ក្រុមយើងខ្ញុំសូមមេត្តាអធ្យាស្រ័យ និងសូមអភ័យទោសពីប្រិយមិត្តអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងទាំងឡាយ និងសូមទទួលស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនា ពីសំណាក់អ្នកអានគ្រប់រូប មន្ត្រីរាជការគ្រប់ស្ថាប័នទាំងអស់ ដើម្បីជួយក្នុងការកែលម្អចំពោះស្នាដៃមួយនេះ អោយកាន់តែមានអត្ថន័យស៊ីជម្រៅជាងនេះបន្ថែមទៀត។

ជាចុងបញ្ចប់ ក្រុមយើងខ្ញុំសូមគោរពជូនពរចំពោះលោកគ្រូ សាស្ត្រាចារ្យណែនាំ ក៏ដូចជាប្រិយមិត្តអ្នកអាន សិស្សនិស្សិត មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ បុគ្គលិកគ្រប់ស្ថាប័ន សូមអោយជួបប្រទះតែភាពសុខសាន្តសេចក្តីចំរុងចម្រើន និងទទួលបានជោគជ័យក្នុងការប្រកបរាល់ភារកិច្ចការងារទាំងអស់។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅរបស់អង្គការអយ្យការ**

**១.១. និយមន័យ** ........................................................................................................ ៥

**១.២ អំពីឋានានុក្រមនៃអង្គការអយ្យការ** ........................................................................ ៥

១.២.១. មហាអយ្យការអមតុលាការកំពូល ........................................................................ ៦

១.២.២. មហាអយ្យការអមសាលាឧទ្ធរណ៍ ........................................................................ ៧

១.២.៣. អយ្យកាអមសាលាដំបូងរាជធានី-ខេត្ត ................................................................ ៧

**១.៣. គោលការណ៍នៃអង្គការអយ្យការ** ........................................................................ ៨

**១.៣.១. គោលការណ៍នៃការធ្វើសកម្មភាពរបស់ព្រះរាជអាជ្ញា** ............................................ ៨

១.៣.១.១. គោលការណ៍ឯកភាព ................................................................................ ៨

១.៣.១.២. គោលការណ៍អវិភាគ ................................................................................ ៩

១.៣.១.៣. គោលការណ៍ឯករាជ្យរវាងអង្គការអយ្យការ និងតុលាការ ...................................... ១០

១.៣.១.៤. គោលការណ៍មិនអាចប្តឹងជិតចិត្ត ................................................................ ១២

១.៣.១.៥. គោលការណ៍នៃការមិនទទួលខុសត្រូវ ........................................................ ១២

**១.៣.២. គោលការណ៍នៃភាពមិនលំអៀង** .................................................................... ១៣

១.៣.២.១. ឥរិយាបថរបស់ព្រះរាជអាជ្ញាចំពោះជនជាប់ចោទ .............................................. ១៣

១.៣.២.២. ការចោទប្រកាន់ក្នុងផលប្រយោជន៍ច្បាប់ ...................................................... ១៥

១.៣.២.៣. ទំនាស់ផលប្រយោជន៍ ............................................................................ ១៦

១.៣.២.៤. ការរើសអើងពូជសាសន៍ និងមតិនយោបាយ .................................................. ១៦

១.៣.២.៥. ការថ្លែងការណ៍ជាសាធារណៈ ...................................................................... ១៧

១.៣.២.៦. ចំណាត់ការនឹងការរំលោភអំណាចរបស់មន្ត្រីសាធារណៈ ...................................... ១៧

## ជំពូកទី២

## អង្គការអយ្យការនៅដំណាក់កាលពាក្យបណ្ដឹង


**២.១. អង្គការអយ្យការក្នុងទំនាក់ទំនងទូទៅ** ............ ១៩

២.១.១. ការទទួលពាក្យបណ្ដឹង ............ ១៩

២.១.២. ទំនាក់ទំនងជាមួយមន្ត្រីនគរបាលយុត្តិធម៌ ............ ២០

២.១.៣. ទំនាក់ទំនងជាមួយចៅក្រមស៊ើបសួរ ............ ២១

**២.២. អង្គការអយ្យការក្នុងការចោទប្រកាន់** ............ ២២

**២.២.១. សេចក្ដីសម្រេចក្នុងការចោទប្រកាន់** ............ ២២

២.២.១.១. មូលដ្ឋាននៃការចោទប្រកាន់ ............ ២៣

២.២.១.២. ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ ............ ២៤

**២.២.២ ការតម្កល់រឿងទុកឥតចាត់ការ** ............ ២៦

២.២.២.១. អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ ............ ២៧

២.២.២.២. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ............ ២៨

២.២.២.៣. អាជ្ញាធរដែលមានសមត្ថកិច្ចតម្កល់រឿងទុកឥតចាត់ការ ............ ៣៥

២.២.២.៤. នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ............ ៣៥


## ជំពូកទី៣

## អយ្យការក្នុងកិច្ចដំណើរការស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ


**៣.១. ការដឹកនាំការស៊ើបអង្កេតរបស់ស្ថាប័នអយ្យការ** ............ ៣៧

**៣.១.១ ការស៊ើបអង្កេតករណីជាក់ស្ដែង** ............ ៣៧

៣.១.១.១. ការចុះទៅកន្លែងកើតហេតុ ............ ៣៨

៣.១.១.២. ការឆែកឆេរ ............ ៣៨

៣.១.១.៣. ការស្ដាប់ចម្លើយ ............ ៣៩

៣.១.១.៤. ការឃាត់ខ្លួន និងការបញ្ជូនខ្លួន ............ ៤០

**៣.១.២. ការស៊ើបអង្កេតបឋម** ............ ៤០

៣.១.២.១. ការឆែកឆេរ ............ ៤១

៣.១.២.២. ការបញ្ជាឱ្យចូលខ្លួន ............ ៤១

**៣.២. ការចូលរួមរបស់អយ្យការក្នុងដំណើរការកិច្ចស៊ើបសួរ**..........................................៤១
**៣.២.១. នីតិវិធីបើកការស៊ើបសួរ** ........................................................................ ៤២
៣.២.១.១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ..................................................៤២
៣.២.១.២. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី................................................ ៤៣
**៣.២.២. ការចូលរួមក្នុងវិធានការណ៍និរន្តរាយ** ................................................................៤៤
៣.២.២.១. ការបង្គាប់ឱ្យចាប់ខ្លួន ...........................................................................៤៤
៣.២.២.២. ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន .........................................................៤៥
៣.២.២.៣. ការត្រួតពិនិត្យតាមផ្លូវតុលាការ................................................................ ៤៧
**៣.២.៣. ការបិទ និងមោឃភាពការស៊ើបសួរ**...............................................................៤៩
៣.២.៣.១. ការបិទការស៊ើបសួរ.................................................................................៤៩
៣.២.៣.២. មោឃភាពនៃកិច្ចស៊ើបសួរ........................................................................៥០
**៣.៣. អយ្យការក្នុងដំណើរការជំនុំជម្រះ** ............................................................................៥១
៣.៣.១. មុនពេលជំនុំជម្រះ ................................................................................................៥១
៣.៣.២. នៅពេលសវនាការ ................................................................................................ ៥៣

## ជំពូកទី៤

## អយ្យការក្នុងការអនុវត្តទោស

**៤.១. វិធានទាក់ទងការឃុំខ្លួន** ....................................................................................................៥៤
៤.១.១. ការគ្រប់គ្រងពន្ធនាគារ......................................................................................................៥៥
៤.១.២. ការធ្វើអធិការកិច្ចពន្ធនាគារ................................................................................................៥៥
**៤.២. ការដោះលែងដោយមានលក្ខខណ្ឌ**..........................................................................................៥៦
**៤.៣. ការបង្ខំរូបកាយ** ................................................................................................................ ៥៧
**សេចក្តីសន្និដ្ឋាន** ........................................................................................................................ ៥៨
**អនុសាសន៍**.......................................................................................................................... ៥៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

នៅគ្រប់បណ្តាប្រទេសទូទាំងពិភពលោកយើងនេះឃើញថាតែងតែមានស្ថាប័នអយ្យការទេ ដែលទទួលបន្ទុកធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌផ្សេងៗពីគ្នា អាស្រ័យត្រង់ថាទៅតាមប្រព័ន្ធច្បាប់ដែលប្រទេសនោះកាន់។ នៅក្នុងបទល្មើសព្រហ្មទណ្ឌនេះដែរ គឺជាបញ្ហាដែលនាំឱ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ និងសង្គមជាតិយ៉ាងធ្ងន់ធ្ងរ ដែលបង្កឱ្យមានភាព អានាធិបតេយ្យ អស្ថេរភាព និងអសន្តិសុខនៅក្នុងប្រទេស។ បើងាកមកមើលនៅប្រទេសកម្ពុជាយើងវិញ ក៏មិនខុសគ្នាពីបណ្តាប្រទេសនៅលើពិភពលោកយើងនេះដែរ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង បានបង្កើតឱ្យមានអង្គការអយ្យការដែលបានទទួលបន្ទុកយ៉ាងច្បាស់លាស់ ក្នុងការជួយបង្ក្រាប ជួយទប់ស្កាត់ និងធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ តាមរយៈបណ្តឹងអាជ្ញា ដែលត្រូវបានអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយព្រះរាជអាជ្ញា ឬក៏អង្គការអយ្យការ[1]។ បណ្តឹងអាជ្ញានេះទៀតសោត គឺអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល នីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ឋានៈ ឬធនធានឡើយ[2]។

ហេតុនេះហើយទើបបានជាអាជ្ញាធររដ្ឋបានបង្កើតឱ្យមានអង្គការអយ្យការ នៅក្នុងយន្តការការពារ និងជួយទប់ស្កាត់ ទៅលើបទល្មើសទាំងអស់នោះ ដែលស្ថាប័ននេះបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ ដែលមានសិទ្ធិធ្វើជាបណ្តឹងអាជ្ញា។ ចំណែក ចំពោះដំណើរការនៃបណ្តឹងព្រហ្មទណ្ឌវិញ គឺមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស និងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យតុលាការអនុវត្តច្បាប់ឱ្យមាន តម្លាភាព យុត្តិធម៌ និងទទួលបាននូវភាពឯករាជ្យ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ការបង្កើតនូវអង្គការអយ្យការ គឺពិតជាមានសារៈសំខាន់ណាស់ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌដោយហេតុថា បទល្មើសព្រហ្មទណ្ឌ គឺជាបទល្មើសដែលនាំឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅក្នុងសង្គម ហើយបង្កឱ្យសង្គមមានភាព វឹកវរ ចលាចល អាណាធិបតេយ្យពាសពេញផ្ទៃប្រទេស។ ហេតុនេះហើយទើបបង្កើតឱ្យមានអង្គការអយ្យការ ហើយបានអនុវត្តបំពេញតាមតួនាទីយ៉ាងសកម្ម នៅក្នុងដំណើរការដោះស្រាយបទចំពោះបទល្មើសនេះដែលញ៉ាំងឱ្យមានចំណោទបញ្ហាចោទឡើង

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ,មាត្រា ៤ កថាខណ្ឌ ១

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ,មាត្រា ៣

ថា តើអង្គការអយ្យការជានរណា? ហើយតើអង្គការអយ្យការនេះ មានតួនាទីអ្វីខ្លះ នៅក្នុងកិច្ចដំណើរការនីតិវិធីនីមួយៗនៃរឿងក្តីព្រហ្មទណ្ឌ ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហាខាងលើនេះ ក្រុមយើងខ្ញុំនឹងធ្វើការសរសេរបកស្រាយ និងការចងក្រងជាសៀវភៅសារណានេះ ដើម្បីជាប្រយោជន៍ទូទៅនៅក្នុងការស្វែងយល់ ពីលំហូរនៃដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ នៅក្នុងប្រព័ន្ធតុលាការ។ នៅក្នុងនោះផងដែរ ការបង្កើតឱ្យមានអយ្យការអម ទាំងសាលាជម្រះក្តីជាន់ទាប និងមហាអយ្យការសាលាជម្រះក្តីជាន់ខ្ពស់ គឺក្នុងគោលបំណង ដើម្បីធានាការគោរព និងអនុវត្តច្បាប់ប្រកបដោយតម្លាភាព និងសុចរិតភាព ហើយអាចមានទំនុកចិត្តពីសំណាក់សាធារណៈជននៅទូទាំងប្រទេស។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

គោលគំនិតនៃប្រធានបទនេះ គឺនឹងធ្វើការសិក្សាស្រាវជ្រាវកម្រិត ពីអង្គការអយ្យការនៅក្នុងលំហូនៃដំណើរការនីតិវិធីរបស់អង្គការអយ្យការ ក្នុងការអនុវត្ត តួនាទី ភារកិច្ចរបស់ខ្លួន នាសង្គមកម្ពុជាក្នុងពេលបច្ចុប្បន្ន ដែលស្របនឹងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងទាក់ទងនឹងសញ្ញាណទូទៅ ក៏ដូចជាតួនាទីទូទៅរបស់អង្គការអយ្យការ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ នៅក្នុងដំណាក់នៃសាលាដំបូងរាជធានី-ខេត្តតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃប្រធានបទ

ចំពោះកម្រងសារណាសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ គឺពិតជាមានសារៈសំខាន់ និងមានការលំបាកជាច្រើន ពីព្រោះក្រុមយើងខ្ញុំត្រូវបានចំណាយពេលវេលារយៈពេល ៣ (បី)ខែ នៅក្នុងការស្រាវជ្រាវ និងធ្វើការចងក្រង ព្រមទាំងបានចំណាយកម្លាំងចិត្ត និងការតស៊ូអំណត់ អត់ធ្មត់ ដោយសេចក្តីព្យាយាមផងដែរ។ សារណាមួយនេះ ក៏អាចក្លាយទៅជាស្ពាន ដែលមានសារៈសំខាន់បំផុតសម្រាប់ និស្សិតច្បាប់ និងអ្នកសិក្សាស្រាវជ្រាវដែលមានបំណងចង់សិក្សាស្វែងយល់អំពី តួនាទី និងភារកិច្ច របស់អង្គការអយ្យការនៅក្នុងលំហូរនីតិវិធីរឿងក្តីព្រហ្មទណ្ឌ ដែលនឹងធ្វើការបកស្រាយ ដោយផ្សារភ្ជាប់ជាមួយនឹង ច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលច្បាប់ជាតិមានដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ, ក្រមព្រហ្មទណ្ឌ, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ផ្សេងៗដែលជាប់ពាក់ព័ន្ធជាច្រើន ទៀតផង។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវ សម្រាប់ក្រុមយើងខ្ញុំបានប្រើប្រាស់នូវរាល់គ្រប់មធ្យោបាយ និងវិធីសាស្ត្រផ្សេងៗជាច្រើនទៀត ដែលបានខិតខំ ប្រឹងប្រែង ក្នុងការប្រមូលនូវឯកសារច្បាប់ផ្សេងៗ ដែលមានពាក់ព័ន្ធទៅ

នឹងប្រធានបទសារណាមួយនេះ។ ចំពោះឯកសារទាំងអស់នោះ គឺមានប្រភពមកពី សៀវភៅច្បាប់មាន ច្បាប់ជាតិ និងច្បាប់អន្តរជាតិ, ការស្រាវជ្រាវតាមប្រព័ន្ធបច្ចេកវិទ្យា ដែលមានតាមប្រព័ន្ធអនឡាញ ក៏ដូចជាសៀវភៅទ្រឹស្តីច្បាប់ផ្សេងៗ ព្រមទាំងមានការចូលរួមកែសម្រួលពីលោកគ្រូសាស្ត្រាចារ្យណែនាំ សិស្សច្បង និងមិត្តរួមថ្នាក់ផងដែរ។ បន្ថែមពីនេះទៀត ក៏បានចូលសិក្សាស្រាវជ្រាវនៅបណ្ណាល័យ ដើម្បីជាប្រយោជន៍ក្នុងការស្វែងយល់ឱ្យកាន់តែច្បាស់ពីប្រធានបទសារណានេះ ក៏ដូចជាការបំពេញបន្ថែមទៀតផង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបឱ្យកាន់តែស៊ីជម្រៅ និងក្បោះក្បាយនូវចំណោទបញ្ហាខាងលើនេះ ក្រុមយើងខ្ញុំនឹងធ្វើការបែងចែក និងពន្យល់បកស្រាយដូចខាងក្រោមនេះ។ នៅក្នុងសារណាដែលសរសេរអំពីប្រធានបទ៖ **អង្គការអយ្យការក្នុងរឿងក្តីព្រហ្មទណ្ឌ នៅសាលាដំបូង** ក្រុមយើងខ្ញុំបានបែងចែកជា បួន ជំពូកគឺ៖

**ជំពូកទី១៖ សញ្ញាណទូទៅរបស់អង្គការអយ្យការ**

- និយមន័យ
- អំពីឋានានុក្រមនៃអង្គការអយ្យការ
- គោលការណ៍នៃអង្គការអយ្យការ

**ជំពូកទី២៖ អង្គការអយ្យការដំណាក់កាលពាក្យបណ្តឹង**

- អង្គការអយ្យការក្នុងទំនាក់ទំនងទូទៅ
- អង្គការអយ្យការក្នុងការចោទប្រកាន់

**ជំពូកទី៣៖ អយ្យការក្នុងកិច្ចដំណើរការ ស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ**

- ការដឹកនាំការស៊ើបអង្កេតរបស់អង្គការអយ្យការ
- ការចូលរួមរបស់អយ្យការក្នុងដំណើរការកិច្ចស៊ើបសួរ

**ជំពូកទី៤៖ អយ្យការក្នុងការអនុវត្តទោស**

- វិធានទាក់ទងការឃុំខ្លួន
- ការដោះលែងដោយមានលក្ខខណ្ឌ
- ការបង្ខំរូបកាយ

# ជំពូកទី១

# សញ្ញាណទូទៅរបស់អង្គការអយ្យការ

# ជំពូកទី១
# សញ្ញាណទូទៅរបស់អង្គការអយ្យការ

អង្គការអយ្យការមានន័យថា គឺជាអង្គការដែលតំណាងឱ្យសង្គម ឬអ្នកតំណាងឱ្យផលប្រយោជន៍ទូទៅ និងជាម្ចាស់បណ្ដឹងអាជ្ញាផងដែរ។ អង្គការនេះមាននៅអមនៃសាលាជម្រះក្ដីនីមួយៗ ដោយរាប់ចាប់ពីសាលាជម្រះក្ដីជាន់ទាប រហូតដល់សាលាជម្រះក្ដីជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងប្រព័ន្ធច្បាប់ប្រទេសកម្ពុជាស្ថាប័នតុលាការត្រូវបានបែងចែកជាពីរជាន់ និងបីថ្នាក់ ដែលមាននៅថ្នាក់សាលាដំបូងរាជធានី-ខេត្ត (ដែលហៅថាសាលាជម្រះក្ដីជាន់ទាប), សាលាឧទ្ធរណ៍ និងតុលាការកំពូល (ហៅថាសាលាជម្រះក្ដីជាន់ខ្ពស់)។ អង្គការអយ្យការ គឺជាស្ថាប័នមួយដែលមានព្រះរាជអាជ្ញា/ រដ្ឋអាជ្ញា ដែលធ្វើការដើម្បីឱ្យទទួលបានសម្រេចសម្រាប់រាល់សកម្មភាពបេសកម្ម នៃរបស់អង្គការរបស់ខ្លួន។ តួនាទីអយ្យការត្រូវតែចែកឱ្យដាច់ពីមុខងារតុលាការ។[3] អង្គការអយ្យការ មិនមែនជាស្ថាប័នដែលទទួលបន្ទុកក្នុងការជម្រះក្ដីដូចតុលាការឡើយ ប៉ុន្តែអយ្យការគ្រាន់តែជាភាគីនៃរឿងក្ដីព្រហ្មទណ្ឌ ដែលជាអ្នកតំណាងឱ្យផលប្រយោជន៍ទូទៅ ដោយមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ បណ្ដឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។[4] នៅក្នុងពេលសវនាការរបស់តុលាការព្រហ្មទណ្ឌ អង្គការអយ្យការ គឺជាគូក្ដីដើម[5] ដោយសារតែព្រះរាជអាជ្ញាជាអ្នកចាប់ផ្ដើមដំណើរការនៃបណ្ដឹងអាជ្ញា សុំអនុវត្តចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ក្នុងន័យនេះចង់មានន័យថា អង្គការអយ្យការ គ្រាន់តែជាអ្នកចោទប្រកាន់ វែកញែក និងសេចក្ដីសន្និដ្ឋាន អំពើការប្រព្រឹត្តរបស់ជនល្មើស សម្រាប់ចង្អុលបង្ហាញភស្តុតាង ដើម្បីបញ្ជាក់អំពីពិរុទ្ធភាពទៅលើជនល្មើស និងសុំឱ្យតុលាការធ្វើការផ្ដន្ទាទោសលើជនល្មើស។

អង្គការអយ្យការក៏មានតួនាទីឱ្យតុលាការអនុវត្តច្បាប់ផងដែរ។ អង្គការនេះ ត្រូវធ្វើការធានារ៉ាប់រង ក្នុងការអនុវត្តទៅលើសេចក្ដីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ និងព្រមទាំងធានាយកចិត្តទុកដាក់ផ្ដោតសំខាន់ទៅលើការផ្សព្វផ្សាយ ដីកាបង្គាប់ឱ្យចាប់ខ្លួន ដើម្បីឱ្យការបំពេញតួនាទីភារកិច្ចរបស់ខ្លួនមានភាពពេញលេញ ។ ចៅក្រមអយ្យការ មានកាតព្វកិច្ចក្នុងការបង្ហាញមុខជាដាច់ខាត នៅក្នុងពេលសវនាការរឿងក្ដីព្រហ្មទណ្ឌ[6]។ អង្គការអយ្យការ ត្រូវបានគេតែងតាំងឱ្យអនុវត្តតួនាទីភារកិច្ច ឱ្យមានតម្លាភាព យុត្តិធម៌ត្រឹមត្រូវ ដើម្បីផលប្រយោជន៍

[3] "គោលការណ៍ណែនាំពីតួនាទីរបស់ព្រះរាជអាជ្ញា" អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី , នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ១៩៩០ ,ចំណុច ទី១០

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ,មាត្រា ៤ កថាខណ្ឌ ១

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ,មាត្រា ៤ កថាខណ្ឌ ២

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ,មាត្រា ២៧ កថាខណ្ឌ ៤

ប្រជាពលរដ្ឋទាំងមូល ដែលជាម្ចាស់អំណាចអធិបតេយ្យ។ ឬនិយាយម្យ៉ាងទៀតថា អង្គការអយ្យការត្រូវបានគេតំណាងក្នុងនាមសង្គម ឬប្រទេសទាំងមូល មិនមែនដើម្បីបុគ្គលណាម្នាក់ ឬអង្គការណាមួយនោះទេ ។

ដូច្នេះ ដើម្បីឱ្យយល់កាន់តែច្បាស់ និងងាយស្រួលដល់ការសិក្សាអំពី អង្គការអយ្យការ យើងត្រូវដឹងនិយមន័យ តើអ្វីទៅជាអង្គការអយ្យការ (១.១) ? តើឋានានុក្រមរបស់អង្គការអយ្យការមានអ្វីខ្លះ (១.២)? និង តើគោលការណ៍នៃស្ថាប័នអយ្យការមានអ្វីខ្លះ (១.៣)?

## ១.១. និយមន័យ

អយ្យការ គឺជាស្ថាប័នមួយដែលតំណាងឱ្យរដ្ឋ ក្នុងការដំណើរការពាក្យបណ្តឹងរឿងព្រហ្មទណ្ឌដល់សាធារណជន ដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ និងផលប្រយោជន៍នៅក្នុងសង្គម។ ពាក្យថា អយ្យការ គឺជាស្ថាប័នមួយ ដូចនេះពាក្យថា អង្គការអយ្យការ គឺជាស្ថាប័នទាំងឡាយ ដែលត្រូវបានដាក់ពង្រាយឱ្យអមនៅតាមសាលាជម្រះក្តីនីមួយៗ គ្រប់ជាន់ថ្នាក់។ ហេតុនេះ អង្គការអយ្យការ គឺជាស្ថាប័នមួយ ដែលមានតួនាទីក្នុងការចោទប្រកាន់ ទៅលើបទល្មើសព្រហ្មទណ្ឌផ្សេងៗ ដែលកើតមានឡើងនៅទូទាំងប្រទេសកម្ពុជា ហើយត្រូវស្ថិតនៅក្រោមឋានានុក្រម នៃអង្គការអយ្យការ។ បន្ថែមពីនេះ អង្គការអយ្យការគឺជាស្ថាប័នដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា និងជួយការពារផលប្រយោជន៍សណ្តាប់ធ្នាប់សាធារណៈពាសពេញផ្ទៃប្រទេសផងដែរ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់សម្រាប់ជាជំនួយ។[7] មានទស្សនៈមួយបានចោទសួរថា តើស្ថាប័នអយ្យការតំណាងឱ្យ រដ្ឋ ,សង្គម ,ឬរដ្ឋាភិបាល? នេះមានន័យថា នៅពេលចាត់បណ្តឹងម្តងៗ តើព្រះរាជអាជ្ញា/រដ្ឋអាជ្ញាតំណាងឱ្យអង្គមួយណា? ស្ថាប័នអយ្យការគឺតំណាងឱ្យសង្គម ឬអ្នកតំណាងឱ្យផលប្រយោជន៍ទូទៅ[8] ម្ចាស់បណ្តឹងអាជ្ញា ជាភាគីនៅក្នុងរឿងព្រហ្មទណ្ឌ។

## ១.២. អំពីឋានានុក្រមនៃអង្គការអយ្យការ

ឋានានុក្រមរបស់អយ្យការ មានច្រើនចំណុចដែលបានបង្ហាញពីឋានានុក្រម និងសិទ្ធអំណាចនៅក្នុងការអនុវត្ត តួនាទី ភារកិច្ចរបស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយ។ ហេតុនេះ រដ្ឋមន្រ្តីក្រសួងយុត្តិធម៌បានដឹងពីបទល្មើសណាមួយ ខ្លួនអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់ជូនទៅក្នុងសំណុំរឿងដោយប្តឹងបរិហារទៅ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងទាក់ទៅនឹងបទល្មើសនោះ ដើម្បីឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសេចក្តីសន្និដ្ឋាន យ៉ាងណាទៅដែល

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ,មាត្រា ២៧ កថាខណ្ឌ ៣

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ,មាត្រា ៤

រដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ ផ្ទុយមកវិញ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌គ្មានសិទ្ធិអំណាចក្នុងការធ្វើអធិបញ្ញាទៅកាន់ អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ក្នុងការឱ្យតម្កល់រឿងទុកឥតចាត់ការទៅលើរឿងក្តីព្រហ្មទណ្ឌណាមួយបាននោះឡើយ។[9]

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិអំណាច ទៅលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន និងមានសិទ្ធិក្នុងការធ្វើអធិបញ្ញាឱ្យធ្វើការចោទប្រកាន់ ឬធ្វើការចាត់ចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។

ចំណែកឯព្រះរាជអាជ្ញាវិញ មានសិទ្ធិអំណាចទៅលើចៅក្រមអយ្យការណាមួយ ដែលស្ថិតនៅក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន និងមានមានសិទ្ធិក្នុងការធ្វើអធិបញ្ញាឱចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬធ្វើការចាត់ឱ្យចោទប្រកាន់ និងធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។[10]

**១.២.១. មហាអយ្យការអមតុលាការកំពូល**

តុលាការកំពូល គឺជាតុលាការមានតែមួយគត់ ដែលទីតាំងនៅរាជធានីភ្នំពេញ។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មហាអយ្យការអមតុលាការកំពូល មានតំណាងអយ្យការដូចតទៅ៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង និង
- ព្រះរាជអាជ្ញា។[11]

ដោយយោងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ចៅក្រម
- ក្រឡាបញ្ជី និង

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៩

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៩

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣១

– មន្ត្រីរដ្ឋបាល និងអាចជាមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល។[12]

**១.២.២. មហាអយ្យការអមសាលាឧទ្ធរណ៍**

សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្តីលំដាប់ថ្នាក់ទីពីរ។ សាលាឧទ្ធរណ៍នេះ រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍នៅតាមតំបន់ចំនួន ០៣ (បី) ផ្សេងទៀត គឺសាលាឧទ្ធរណ៍ដែល មានទីតាំងស្ថិតនៅខេត្តត្បូងឃ្មុំ ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មហាអយ្យការអមសាលាឧទ្ធរណ៍ មានតំណាងអយ្យការដូចតទៅ៖

– អគ្គព្រះរាជអាជ្ញា
– អគ្គព្រះរាជអាជ្ញារង និង
– ព្រះរាជអាជ្ញា។[13]

ដោយយោងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ មហាអយ្យការអមសាលាឧទ្ធរណ៍មានសមាសភាពដូចខាងក្រោម៖

– អគ្គព្រះរាជអាជ្ញា
– អគ្គព្រះរាជអាជ្ញារង
– ព្រះរាជអាជ្ញា
– ក្រឡាបញ្ជី
– មន្ត្រីរដ្ឋបាល និងអាចជាមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍។[14]

**១.២.៣. អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

នៅទូទាំងប្រទេសនៃសាលាដំបូងរាជធានី-ខេត្ត គឺមានអង្គការអយ្យការតែមួយគត់ដែលហៅថា "អយ្យការអមសាលាដំបូង"។ នៅពេលដែលមានបទល្មើសមួយកើតឡើង គឺមានតែអង្គការអយ្យការនេះតែមួយគត់ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា និងធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌនោះ។ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ អង្គការអយ្យការអមសាលាដំបូង មានតំណាងអយ្យការដូចតទៅ៖

[12] ច្បាប់ស្តីពីការរៀបចំអង្គការតុលា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៦៨
[13] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៣
[14] ច្បាប់ស្តីពីការរៀបចំអង្គការតុលា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៤៩

- ព្រះរាជអាជ្ញា និង
- ព្រះរាជអាជ្ញារង។[15]

ដោយយោងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ បានកំណត់ថា អយ្យការអមសាលាដំបូងមានសមាសភាពដូចខាងក្រោម៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល
- និងមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងៗទៀត ដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។[16]

## ១.៣. គោលការណ៍នៃអង្គការអយ្យការ

### ១.៣.១. គោលការណ៍នៃការធ្វើសកម្មភាពរបស់ព្រះរាជអាជ្ញា

#### ១.៣.១.១. គោលការណ៍ឯកភាព

ឯកភាពនៃអង្គការអយ្យការមានន័យថា ព្រះរាជអាជ្ញាទាំងអស់ដែលបានបង្កើតក្នុងអង្គភាពជាមួយគ្នា គឺត្រូវស្ថិតក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។[17] នៅក្នុងនោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមខ្ពស់ជាងគេ នៅក្នុងអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ជាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការគ្រប់ជាន់ថ្នាក់ លើកលែងតែមហាអយ្យការតុលាការកំពូល។[18] ចំណែកឯអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ គឺជាសេនាធិការឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះផងដែរ។[19] នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ចំពោះគោលការណ៍ឋានានុក្រមនៅក្នុងអង្គការអយ្យការត្រូវបានបែងចែកដូចខាងក្រោមនេះ៖

**ក. មហាអយ្យការអមតុលាការកំពូល**

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៦

[16] ច្បាប់ស្តីពីការរៀបចំអង្គការតុលា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ២៩

[17] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥,១៤ កក្កដា ២០១៤, មាត្រា ៧៥ ចំណុច ១ កថាខណ្ឌ ១

[18] ច្បាប់ស្តីពីលក្ខខណ្ឌន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៥ ចំណុច ១ កថាខណ្ឌ ២

[19] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៥ ចំណុច ១ កថាខណ្ឌ ៣

នៅតុលាការកំពូលមានស្ថាប័នឈ្មោះ មហាអយ្យការអមតុលាការកំពូល ដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញា ០១(មួយ) រូប និងអមដោយ អគ្គព្រះរាជអាជ្ញារង ព្រមទាំងព្រះរាជអាជ្ញាមួយចំនួន តាមការចាំបាច់ផងដែរ។[20] ព្រះរាជអាជ្ញា និង អគ្គព្រះអាជ្ញារង នៃមហាអយ្យការកំពូល ត្រូវធ្វើការក្រោមការដឹកនាំ និងទំនួលខុសត្រូវ របស់អគ្គព្រះរាជអាជ្ញា[21]។ ដូច្នេះអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។ ចំណែកឯព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល គឺត្រូវបានស្ថិតក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញារង ដែលជានាយឋានានុក្រមរបស់ខ្លួន។

**ខ. មហាអយ្យការអមសាលាឧទ្ធរណ៍**

ចំណែកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រម នៃមហាអយ្យការអមសាលាឧទ្ធរណ៍។ រីឯ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ គឺត្រូវបានស្ថិតក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។[22]

**គ. អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

នៅតាមតុលាការរាជធានី-ខេត្តក្រុងនីមួយៗមានអង្គការអយ្យការតែមួយគត់ ដែលមានព្រះរាជអាជ្ញា គឺជានាយឋានានុក្រម នៃអយ្យការអមសាលាដំបូង នៅក្នុងការជាអ្នកដឹកនាំ។ ក្រៅពីនេះក៏មានព្រះអាជ្ញារងទាំងអស់នៃអយ្យការសាលាដំបូង ដែលមានភារកិច្ចជាអយ្យការដែរ ប៉ុន្តែត្រូវតែស្ថិតក្រោមបង្គាប់បញ្ជា និងការដឹកនាំរបស់ ព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមនៃអយ្យការ។ ដូច្នេះសមាជិកអយ្យការត្រូវគោរពតាមឋានានុក្រម ដែលក្នុងនោះ ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។ ចំពោះ ព្រះរាជអាជ្ញារងទាំងអស់ គឺត្រូវបានស្ថិតក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់ព្រះរាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន[23]។

**១.៣.១.២. គោលការណ៍អវិភាគ**

គោលការណ៍អវិភាគនេះ ចង់សំដៅទៅលើការបំពេញមុខងាររបស់សមាជិកនីមួយៗនៃអង្គការអយ្យការ គឺធ្វើដើម្បីទទួលបានផលប្រយោជន៍ជាសមូហភាព ។ ដូចនេះហើយបានជានៅមុខតុលាការ ព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារងតែងតែប្រើពាក្យ តំណាងអយ្យការ ព្រោះគេមិនធ្វើការងារក្នុងនាមផ្ទាល់ខ្លួននោះទេ ប៉ុន្តែក្នុងនាមជាអង្គការរបស់ខ្លួន។ ម្យ៉ាងទៀត ព្រះរាជអាជ្ញាម្នាក់ត្រូវទទួលបានសិទ្ធិឱ្យមកតំណាងតាមរយៈអង្គការអយ្យការ

[20] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៤ កថាខណ្ឌ ១

[21] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៥ កថាខណ្ឌ ៥

[22] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៥ កថាខណ្ឌ ៧

[23] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៥ កថាខណ្ឌ ៩

នៅក្នុងរឿងក្ដីព្រហ្មទណ្ឌមួយ។ មួយទៀត តំណាងអង្គការអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។[24] *ឧទាហរណ៍៖* ព្រះអាជ្ញារងម្នាក់ជាអ្នកចាប់ផ្ដើមចោទ បន្ទាប់មកទៀតអយ្យការអាចចាត់តាំងឱ្យព្រះរាជអាជ្ញារងម្នាក់ទៀត ធ្វើការជជែកបន្តចំពោះរឿងក្ដីដដែលនោះបាន នៅអំឡុងពេលសវនាការ។ ឬសូម្បីតែនៅក្នុងសវនាការនៃរឿងក្ដីតែមួយ ព្រះរាជអាជ្ញាម្នាក់ជាអ្នកផ្ដើមដំណើរនៃនីតិវិធី និងព្រះរាជអាជ្ញាម្នាក់ទៀតជាអ្នកធ្វើសេចក្ដីសន្និដ្ឋានក៏បានផងដែរ។ នៅក្នុងគោលការណ៍នេះចំពោះការបំពេញមុខងារតួនាទីភារកិច្ចនៃតំណាងអយ្យការនីមួយៗ គឺអាចជំនួសគ្នាទៅវិញទៅមកបាន នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជារួមមក ព្រះរាជអាជ្ញាទាំងអស់ដែលបានអនុវត្តមុខងារនៅក្នុងអង្គការអយ្យការអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ទាំងអស់ គឺនៅតែមានកាតព្វកិច្ចរួមគ្នា ក្នុងការបំពេញមុខងារដូចៗគ្នាផងដែរ។

**១.៣.១.៣. គោលការណ៍ឯករាជ្យរវាងអង្គការអយ្យការ និងតុលាការ**

ជាគោលការណ៍មានចែងនៅក្នុងរដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា អំណាចត្រូវបានបែងចែកជា បី ដាច់ដោយឡែកពីគ្នាដែលមាន អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ រវាងស្ថាប័នអយ្យការ គឺស្ថិតនៅក្រោមគោលការណ៍នៃឋានានុក្រមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅក្នុងអំណាចនីតិប្រតិបត្តិ ត្រូវតែឯករាជ្យពីអំណាចតុលាការផងដែរ។

ឯករាជ្យរវាងតុលាការមានន័យថា អយ្យការនៅអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ គឺមិនស្ថិតនៅក្រោមចំណុះឱ្យស្ថាប័នរបស់ខ្លួនណាមួយឡើយ ទោះបីជាស្ថិតក្នុងចំណោមតែមួយនឹងសាលាជម្រះក្ដីនោះក៏ដោយ។ ហេតុដូច្នេះ តុលាការ ឬប្រធានតុលាការ គ្មានសិទ្ធិអំណាចអ្វីមកធ្វើការត្រួតពិនិត្យទៅលើកិច្ចការងារ និងគ្មានសិទ្ធិស្ដីបន្ទោស មិនថាដោយផ្ទាល់ ឬដោយប្រយោល ក្នុងករណីដែលមានកំហុសខុសឆ្គង ហើយបានប្រព្រឹត្តដោយអយ្យការនៅពេលបានបំពេញអនុវត្តកាតព្វកិច្ច និងមុខងាររបស់ខ្លួនជាមួយតុលាការនោះទេ។[25] តុលាការមិនអាចបង្គាប់បញ្ជាឱ្យអយ្យការ ឬ ព្រះរាជអាជ្ញាត្រូវចោទប្រកាន់ក្នុងបទល្មើសនោះទេ ឬចង្អុលថាជននោះត្រូវតែចោទប្រកាន់តាមដែលខ្លួនយល់ឃើញនោះទេ។ ការហាមឃាត់នេះត្រូវអនុវត្ត ទាំងក្នុងរឿងព្រហ្មទណ្ឌ និងរឿងក្ដីផ្សេងទៀត។[26] ការធ្វើដូច្នេះជាការបំពានអំណាច ប៉ុន្តែតុលាការអាចរ៉ាយរ៉ាប់ជាសំងាត់ ពីការមិនសប្បាយចិត្តរបស់ខ្លួនទៅថ្នាក់លើរបស់អង្គការអយ្យការបាន។

[24] ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៥ ចំណុច ២ កថាខណ្ឌ ២

[25] ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៧

[26] ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៥ ចំណុច ៣ កថាខណ្ឌ ៤

មានទស្សនៈពីរចំពោះឯករាជ្យភាពនៃអង្គការអយ្យការ និងតុលាការ ដោយទស្សនៈឯករាជ្យភាពនោះរួមមាន **ឯករាជ្យភាពខាងស្ថាប័នផង (ក) និងឯករាជ្យក្នុងមុខងារផង (ខ)**។[27]

### ក. ឯករាជ្យភាពខាងស្ថាប័ន

ឯករាជ្យខាងស្ថាប័នមានន័យថា អង្គការអយ្យការមិនត្រូវស្ថិតនៅក្រោមចំណុះ ឬក្នុងជួរឋានានុក្រមនៃអំណាចណាមួយនៃរដ្ឋាភិបាលដែលមានដូចជា អំណាចនីតិប្រតិបត្តិ ឬអំណាចនីតិបញ្ញត្តិឡើយ គឺអំណាចទាំងបី ដាច់ដោយឡែកពីគ្នា[28]។ ឯករាជ្យក្នុងន័យនេះ គឺជាឯករាជ្យពីអំណាចដទៃទៀត ដែលមានរដ្ឋាភិបាល គឺអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ។ នៅក្នុងក្របខណ្ឌគតិយុត្ត ដោយយោងទៅតាមក្របខណ្ឌរដ្ឋធម្មនុញ្ញផងដែរនោះ ដូច្នេះអាចយល់បានថាឯករាជ្យភាពរបស់អយ្យការ គួរតែបានឯករាជ្យខាងស្ថាប័នផងដែរ។ *ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ*។[29] ជាលទ្ធផល ឯករាជ្យខាងស្ថាប័ននាំឱ្យអង្គការអយ្យការទទួលបាន នូវអំណាចមកចាត់ចែងស្ថាប័នរបស់ខ្លួនដោយខ្លួនឯង ដោយបានរាប់បញ្ចូលទាំងផ្នែកហិរញ្ញវត្ថុ រដ្ឋបាល និងមុខងារដទៃផ្សេងទៀត ដែលមាននៅក្នុងស្ថាប័នរបស់តុលាការ។ អ្នកគាំទ្រឯករាជ្យភាពខាងស្ថាប័នបានយល់ឃើញថា នៅក្នុងគោលការណ៍នេះ ព្រះរាជអាជ្ញាទទួលបានអត្ថប្រយោជន៍យ៉ាងសំខាន់ ក្នុងការបំពេញមុខងាររបស់ខ្លួន ដោយបានរួចផុតពីការបង្គាប់បញ្ជា រឿងនយោបាយ ជាពិសេសគឺនៅក្នុងរឿងណា ដែលជាប់ពាក់ព័ន្ធទៅនឹងបញ្ហានយោបាយ ឬផលប្រយោជន៍សង្គម និងបញ្ហាសេដ្ឋកិច្ចផងដែរ។ ព្រះរាជអាជ្ញាអាចចាត់ការ ឬមិនចាត់ការបណ្ដឹងរបស់ខ្លួន ទៅតាមមូលកភាពនៃរឿងក្ដី ដោយមិនអនុលោមទៅតាមបង្គាប់បញ្ជារបស់ក្រសួង ដែលជាអាណាព្យាបាលរបស់ខ្លួនឡើយ។

### ខ. ឯករាជ្យភាពក្នុងមុខងារ

ឯករាជ្យភាពក្នុងការបំពេញមុខងារមានន័យថា ដោយព្រះរាជអាជ្ញាបានបំពេញមុខងាររបស់ខ្លួន ដោយមានភាពឯករាជ្យ ពីស្ថាប័នតុលាការនៅពេលជម្រះក្ដីដែលខ្លួននៅអមទៅនឹងគូក្ដី។ ក្នុងន័យនេះ ព្រះរាជអាជ្ញាមិនធ្វើជាចៅក្រមជម្រះក្ដីចំពោះរឿងដែលខ្លួនចាត់ការប្ដឹងនោះទេ ហើយចៅក្រមក្នុងតុលាការមួយក៏មិនអាចតាំងខ្លួនជាដើមបណ្ដឹងព្រហ្មទណ្ឌបានទេ។ តុលាការនោះគ្មានសិទ្ធិចាប់កំហុសព្រះរាជអាជ្ញា ដែលបានចាត់ការក្នុងរឿងអ្វីមួយ ឬក៏បង្គាប់បញ្ជាលូកដៃចូលទៅក្នុងកិច្ចការផ្សេងៗរបស់ព្រះរាជអាជ្ញា នៅពេលបានបំពេញតួនាទីរបស់ខ្លួនឡើយ។ ក្នុងន័យនេះ ចង់មានន័យថា ក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារ

[27] សៀវភៅ លោក កុយ នាម និង ឡុងបញ្ញាវុឌ្ឍ, អង្គការអយ្យការ (ប្រវត្តិនិងការសិក្សាប្រៀបធៀប), ភ្នំពេញ, បោះពុម្ពលើកទី១, ២០០៦, ទំព័រទី ៧៧ ។

[28] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣ ,មាត្រា ៥១ ថ្មី កថាខណ្ឌ ៥

[29] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣ ,មាត្រា ១២៨ ថ្មី កថាខណ្ឌ ១

ក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួន យកការស៊ើបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។[30] នៅចំពោះមុខគូក្តី ព្រះរាជអាជ្ញាមិនចាំបាច់ត្រូវតែចាត់ការ ឬធ្វើការចោទប្រកាន់តាមបណ្តឹងរបស់ជនរងគ្រោះនោះទេ។ នៅក្នុងករណីដែលជនរងគ្រោះ ដកពាក្យបណ្តឹង ឬសុំសម្រុះសម្រួលជាមួយជនល្មើស ព្រះរាជអាជ្ញាក៏ឈប់ចោទប្រកាន់វិញបានភ្លាមបានដែរ។

ម្យ៉ាងវិញទៀត ទោះជាការបកស្រាយខាងលើនេះ បានផ្តល់ឯករាជ្យភាពទៅដល់អង្គការអយ្យការក៏ពិតមែន ប៉ុន្តែឯករាជ្យភាពនេះ មានតែចំពោះដៃគូតុលាការដែលបាននៅអមតែប៉ុណ្ណោះទេ។ ទោះជាយ៉ាងណា អង្គការអយ្យការនៅតែមិនមានភាពពេញលេញនៅក្នុងការបំពេញមុខងារក្នុងតុលាការរបស់ខ្លួន ដោយហេតុថាសមាជិកអង្គការអយ្យការ ត្រូវតែគោរពតាមបង្គាប់បញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលត្រូវជាដៃគូមួយនៃអំណាចនីតិប្រតិបត្តិ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានអំណាចលើសលប់ ដើម្បីធ្វើអន្តរាគមន៍ក្នុងសេរីភាពក្នុងការសម្រេចចិត្តរបស់ព្រះរាជអាជ្ញា។

**១.៣.១.៤. គោលការណ៍មិនអាចប្តឹងជិតចិត្ត**

ជាទូទៅ អង្គការអយ្យការតែងតែមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលស្ថិតក្នុងតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត គឺមិនត្រូវបានពាក់ព័ន្ធទៅនឹងការប្តឹងជិតចិត្តបានទេ ពីព្រោះថានៅពេលដែលព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ក្នុងបទល្មើសព្រហ្មទណ្ឌណាមួយ គឺក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋក៏ដូចជាផលប្រយោជន៍សង្គមផងដែរ។ ហេតុដូច្នេះ ព្រះរាជអាជ្ញាគឺមិនតំណាងឱ្យខ្លួនឯងនោះទេ។ ទោះបីជា ព្រះរាជអាជ្ញាមានការជាប់ពាក់ព័ន្ធជាមួយនឹងសាច់ញាតិ ឬផលប្រយោជន៍ក្នុងបណ្តឹងនោះក៏ដោយ។ មួយវិញទៀត ទោះបីជាមានការចោទប្រកាន់ពីព្រះរាជអាជ្ញាក៏ពិតមែន តែមិនមែនបានន័យថា បុគ្គលនោះជាជនត្រូវចោទនោះទេ ដរាបណាមិនទាន់ចេញសាលក្រមជាស្ថាពរពីតុលាការ។ ដូចនេះ ព្រះរាជអាជ្ញាមិនអាចក្លាយជាកម្មវត្ថុនៃការធ្វើបណ្តឹងជិតចិត្តបានទេ។

**១.៣.១.៥. គោលការណ៍នៃការមិនទទួលខុសត្រូវ**

ក្នុងនាមជាព្រះរាជអាជ្ញាដែលជាអ្នកតំណាងឱ្យរដ្ឋការដើរតួនាទីនៅក្នុងការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយណា ដែលខ្លួនគិតថាជាបទល្មើសព្រហ្មទណ្ឌដោយមិនទាន់មានភាពជាក់លាក់ច្បាស់។ ក្នុងករណីនេះ ចំពោះអង្គហេតុដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់អាចនឹងត្រូវបានច្រានចោលដោយចៅក្រមស៊ើបនៅដំណាក់កាលស៊ើបសួរ ឬនៅដំណាក់កាលជំនុំជម្រះ បើសិនអង្គហេតុនោះមិនមែនជាបទល្មើស ឬមិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីកំណត់ធាតុផ្សំ នៃបទល្មើស។ ហេតុនេះ ក្នុងករណីកើតមានឡើង ព្រះរាជ

[30] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៧៥ ចំណុច ៣

អាជ្ញាមិនទទួលខុសត្រូវរាល់ការខូចខាតទាំងឡាយ ដែលកើតចេញពីការសម្រេចទៅលើរឿងក្ដីរបស់ខ្លួន ដែលកំពុងតែទទួលខុសត្រូវនោះទេ ជាពិសេសចំពោះជនត្រូវចោទ ឬជនជាប់ចោទនៅក្នុងសំណុំរឿងនោះឡើយ។ ផ្ទុយមកវិញ ចំពោះគោលការណ៍នៃការមិនទទួលខុសត្រូវរបស់អង្គការអយ្យការនៅក្នុងការចោទប្រកាន់ គឺមិនមែនបានន័យថា ព្រះរាជអាជ្ញាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ នៅពេលដែលព្រះរាជអាជ្ញាបានប្រព្រឹត្តកំហុសធ្ងន់ ដែលកើតឡើងដោយចេញពីឆន្ទៈទុច្ចរិត នៅពេលបានបំពេញមុខងាររបស់ខ្លួន។ ហេតុនេះហើយ ក្នុងករណីដែលមានព្រះរាជអាជ្ញាបានប្រព្រឹត្តកំហុស ដែលជាបទល្មើសព្រហ្មទណ្ឌណាមួយនោះ គឺព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ដែលខ្លួនបានប្រព្រឹត្តិផងដែរ។

**១.៣.២. គោលការណ៍នៃភាពមិនលំអៀង**[31]

ភាពមិនលំអៀងនៃព្រះរាជអាជ្ញាបានន័យថាគឺជាការមិនប្រកាន់ឥរិយាបថលំអៀង ចំពោះជនជាប់ចោទដោយសារតែមូលហេតុផ្សេងៗមានដូចជា មូលហេតុភេទ នយោបាយ ជាតិសាសន៍ វប្បធម៌ ឋានៈសង្គម និងការរើសអើងផងដែរ[32]។ ដោយឈរលើទស្សនៈដែលថា ព្រះរាជអាជ្ញាជាអ្នកធ្វើឱ្យមានការគោរពច្បាប់ និងមានរបៀបរៀបរយនៅក្នុងពាសពេញផ្ទៃប្រទេស។ ព្រះរាជអាជ្ញាគ្មានគំនិតស្អប់ ឬ ស្រឡាញ់ជននេះ ឬជននោះ នោះទេ ដោយសារគេមានទស្សនៈផ្ទុយ ឬស្របនៅក្នុងខ្លួន។ ព្រះរាជអាជ្ញាត្រូវតែការពារផលប្រយោជន៍សាធារណៈ យ៉ាងយកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតមានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ[33]។

**១.៣.២.១. ឥរិយាបថរបស់ព្រះរាជអាជ្ញាចំពោះជនជាប់ចោទ**

យើងបានដឹងហើយថាព្រះរាជអាជ្ញាជាគូភាគីមួយ តទល់នឹងជនជាប់ចោទនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ។ ក្នុងឋានៈជាភាគីប្រឆាំងមិនមែនមានន័យថា ព្រះរាជអាជ្ញាជាបច្ចាមិត្តជាមួយជនជាប់ចោទនោះទេ។ ចំណែកឯភាគីរងគ្រោះ អាចមានមនោសញ្ចេតនាចំពោះជនជាប់ចោទ គឺខុសពីព្រះរាជអាជ្ញា ដោយសារគេទទួលរងនូវការខូចខាតពីបទល្មើស ប៉ុន្តែអ្វីដែលព្រះរាជអាជ្ញាខូចខាតនៅក្នុងរឿងព្រហ្មមួយគឺ ការរំលោភបំពានច្បាប់ និងការធ្វើឱ្យខូចផលប្រយោជន៍សាធារណៈ។ ចំពោះផលប្រយោជន៍របស់ព្រះរាជអាជ្ញានៅក្នុងរឿងក្ដីព្រហ្មទណ្ឌនោះគឺ ការ

[31] សៀវភៅ លោក កុយ នាម និង ឡុងបញ្ញាវុឌ្ឍ, អង្គការអយ្យការ (ប្រវត្តិនិងការសិក្សាប្រៀបធៀប), ភ្នំពេញ, បោះពុម្ពលើកទី១, ឆ្នាំ ២០០៦, ទំព័រទី ១៦៨ ។

[32] "គោលការណ៍ណែនាំស្ដីពីតួនាទីរបស់ព្រះអាជ្ញា" , អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, នៅថ្ងៃទី ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១៣ (ក)

[33] "គោលការណ៍ណែនាំស្ដីពីតួនាទីរបស់ព្រះរាជអាជ្ញា", អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី នៅថ្ងៃទី ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១៣ (ខ)

ទាមទារឱ្យមានការគោរពច្បាប់ និងជួសជុលការខូចខាតជូនដល់សង្គមមកវិញ។ ការសងសឹកជនជាប់ចោទរបស់ព្រះរាជអាជ្ញា គឺធ្វើយ៉ាងណាឱ្យតែជនជាប់ចោទបានជាប់ពន្ធនាគារ មិនមែនជាផលប្រយោជន៍របស់ព្រះអាជ្ញានោះទេ តែជាការរកយុត្តិធម៌សម្រាប់ជនរងគ្រោះ។ ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីរបស់ខ្លួនយ៉ាងយកចិត្តទុកដាក់ចំពោះជនសង្ស័យ ដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតមានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ។[34]

បទល្មើសព្រហ្មទណ្ឌមួយដែលបានកើតឡើង អាចមិនមែនជាស្នាដៃនៃជនដែលកំពុងស្ថិតនៅក្នុងការចោទប្រកាន់នោះទេ ដរាបណានៅមិនទាន់មានភស្តុតាង សាក្សី និងស្វែងរកការពិតច្បាស់លាស់នៅឡើយនោះ ។ នៅពេលដែលព្រះរាជអាជ្ញា ទទួលបាននូវភស្តុតាងប្រឆាំងចំពោះជនសង្ស័យដែលគេដឹងថា ឬមានជំនឿលើមូលដ្ឋានសមហេតុផលថា ភស្តុតាងដោយប្រើប្រាស់វិធីមិនស្របច្បាប់ ដែលអាចចាត់ទុកបានថា ជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងនឹងការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តអំពើកាចសាហាវដោយអមនុស្សធម៌ និងបន្ថោកបន្ទាប ឬការរំលោភបំពានសិទ្ធិមនុស្សដទៃទៀតនោះ ព្រះរាជអាជ្ញាត្រូវបដិសេធ មិនប្រើភស្តុតាងបែបនោះប្រឆាំងនឹងជនណាម្នាក់ឡើយ ក្រៅពីអ្នកដែលបានប្រើវិធីបែបនោះខ្លួនឯង ឬត្រូវជម្រាបដល់តុលាការតាមនោះ ហើយត្រូវចាត់គ្រប់វិធានការណ៍ចាំបាច់ទាំងអស់ ដើម្បីធានាអ្នកដែលទទួលខុសត្រូវ ចំពោះការប្រើប្រាស់វិធីបែបនោះ ត្រូវនាំខ្លួនមកកាន់តុលាការ។[35] ផលប្រយោជន៍របស់ព្រះរាជអាជ្ញា គឺទាមទារឱ្យចៅក្រមពិចារណាថា តើជនដែលកំពុងចោទប្រកាន់នោះពិតជាបានប្រព្រឹត្តបទល្មើសមែនឬយ៉ាងណា? ហើយបើបានប្រព្រឹត្តមែន តើត្រូវផ្តន្ទាទោសបែបណា ? ដូច្នេះ ព្រះរាជអាជ្ញាជាអ្នកត្រូវប្រកាន់ជំហរឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ ហើយឆាប់រហ័ស ធ្វើយ៉ាងណាឱ្យមានភាពសមរម្យនឹងទង្វើដែលបានប្រព្រឹត្ត និងជួយរកយុត្តិធម៌នៅក្នុងការកាត់ក្តី ដោយភាពសុចរិតទៀងត្រង់ឱ្យស្របតាមច្បាប់កំណត់ និងការពារសេចក្តីថ្លៃថ្នូរ ក៏ដូចជាជួយលើកកម្ពស់សិទ្ធិមនុស្ស[36] គឺមិនមែនកំណត់គោលដៅ យកចាញ់ យកឈ្នះ ដូចតួនាទីរបស់មេធាវីនោះទេ ព្រោះមេធាវីបម្រើផលប្រយោជន៍ជូនកូនក្តីរបស់គាត់។ រីឯព្រះរាជអាជ្ញា បម្រើផលប្រយោជន៍ជូនសាធារណៈ។[37]

---

[34] "គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា", អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១៣ (ខ)

[35] "គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះអាជ្ញា" , អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១៦

[36] "គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះអាជ្ញា", អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១២

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤

ថ្មីឡិតតែ ព្រះរាជអាជ្ញាជាគូក្តី គោលការណ៍សច្ចធារណ៍នៃនិរទោស (ត្រូវមានសិទ្ធិទទួលបានការសន្មតថាគ្មានទោស រហូតត្រូវបានបង្ហាញថាគ្មានពិរុទ្ធភាពតាមច្បាប់)[38] តែនៅតែត្រូវបានគោរពដោយតួអង្គទាំងអស់ រួមទាំងព្រះរាជអាជ្ញារងផងដែរ។ គោលការណ៍សច្ចារណ៍នៃនិរទោស ដែលជាមូលដ្ឋានគ្រឹះមួយក្នុងការពារសិទ្ធិមនុស្សដាក់បន្ទុកលើអយ្យការ ឱ្យផ្តល់ភស្តុតាងពីបទចោទរបស់ខ្លួន។

**១.៣.២.២. ការចោទប្រកាន់ក្នុងផលប្រយោជន៍ច្បាប់**

ព្រះរាជអាជ្ញា មិនត្រូវលំអៀងនៅក្នុងការចោទប្រកាន់ ឬការមិនចោទប្រកាន់ និងនៅក្នុងការស៊ើបអង្កេតរបស់ខ្លួនដោយលំអៀង បង្ហាញឱ្យឃើញថា ការចោទប្រកាន់នេះពុំមានមូលដ្ឋានច្បាស់លាស់នោះទេ។[39] ពិតមែនហើយ ព្រះរាជអាជ្ញាជាដើមបណ្តឹងអាជ្ញា ប៉ុន្តែព្រះរាជអាជ្ញាធ្វើបណ្តឹងអាជ្ញាដោយផ្អែកតាមផលប្រយោជន៍ច្បាប់។ បើសិនគេគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ទេនោះ ព្រះរាជអាជ្ញាត្រូវបញ្ឈប់ការចោទប្រកាន់នោះភ្លាម។ ហេតុដូច្នេះ លុះត្រាណាព្រះរាជអាជ្ញាជំនុំគំនិតគ្នាបុរេវិនិច្ឆ័យចេញ ព្រោះការបុរេវិនិច្ឆ័យធ្វើឱ្យមានការប៉ះពាល់ទៅដល់ការយល់ និងការវាយតម្លៃលើអង្គហេតុ និងការបកស្រាយ និងការអនុវត្តច្បាប់។ ការធ្វើបណ្តឹង គឺដើម្បីរិះខានជនជាប់ចោទ ឬដើម្បីគាបសង្កត់ជនជាប់ចោទ ក្នុងគោលបំណងផលប្រយោជន៍អ្វីមួយ គឺការប្រព្រឹត្តផ្ទុយពីក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

គោលការណ៍ណែនាំអំពីតួនាទីរបស់ព្រះរាជអាជ្ញានៅក្នុងអង្គការសហប្រជាជាតិនិងស្តង់ដានៃភាពទទួលខុសត្រូវវិជ្ជាជីវៈ និងសេចក្តីថ្លែងពីករណីយកិច្ច និងសិទ្ធិជាសារវន្តរបស់ព្រះរាជអាជ្ញា ទាមទារឱ្យព្រះរាជអាជ្ញាស្វែងរកភស្តុតាង ទាំងដាក់បន្ទុក និងដោះបន្ទុក ដោយមិនត្រូវមានគំនិត ដើម្បីធ្វើយ៉ាងណាឱ្យជនជាប់ចោទទទួលការផ្តន្ទាទោសប៉ុណ្ណោះទេ ព្រោះផលប្រយោជន៍របស់ព្រះរាជអាជ្ញា គឺធ្វើយ៉ាងណា ដើម្បីរកយុត្តិធម៌ និងការគោរពច្បាប់[40]។ ជាការពិតណាស់ នៅក្នុងប្រព័ន្ធដែលព្រះរាជអាជ្ញាមាននាទីជាអ្នកស៊ើបអង្កេត នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមិនមែនត្រឹមតែស្វែងរកភស្តុតាងដាក់បន្ទុកប៉ុណ្ណោះទេ តែគាត់រកមើលលទ្ធភាព ដែលអាចមានភស្តុតាងដោះបន្ទុកផងដែរ។ ព្រះរាជអាជ្ញា / រដ្ឋអាជ្ញា គឺគ្រាន់តែអាចធ្វើសេចក្តីសន្និដ្ឋានស្ថាពរ។ ចំពោះការស្នើសុំឱ្យលើកលែកការចោទប្រកាន់ដាក់ជូនទៅ ចៅក្រមស៊ើបអង្កេត បើគាត់យល់ថាមានភស្តុតាងដាក់បន្ទុកមិនគ្រប់គ្រាន់។

---

[38] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ២៣ មីនា ១៩៧៦, មាត្រា ១៤ ចំណុចទី ២

[39] "គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះអាជ្ញា", អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១៤

[40] "គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា",អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១៨

### ១.៣.២.៣ . ទំនាស់ផលប្រយោជន៍

នៅក្នុងការទទួលខុសត្រូវតួនាទីវិជ្ជាជីវៈ និងសេចក្ដីថ្លែងការណ៍ពីករណីយកិច្ច និងសិទ្ធិសារវន្តរបស់ព្រះរាជអាជ្ញាមិនបានចែងជាក់លាក់ពីទំនាក់ទំនងផលប្រយោជន៍ ឬវិសមិតភាពទេ។ នៅក្នុងករណីចាំបាច់ដោយមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ព្រះរាជអាជ្ញាអាចស្នើសុំនៅទំនេរគ្មានបៀវត្ស សម្រាប់រយៈពេលកំណត់ណាមួយ តាមពាក្យសុំរបស់សាមីខ្លួន។[41] មានន័យថា នៅពេលណារឿងក្ដីមួយត្រូវបានប្រគល់ឱ្យព្រះរាជអាជ្ញាណាម្នាក់ ស្ថានភាពរបស់ភាគីជាប់ចោទអាចបង្កឱ្យមានវិសមិតភាព នៃមុខងាររបស់ព្រះរាជអាជ្ញាបាន។ *ឧទាហរណ៍៖* ភាគីជាប់ចោទអាចជាមនុស្សជាប់សាច់ញាតិ មិត្តភក្តិ ឬ អ្នកដែលធ្លាប់មានផលប្រយោជន៍ជាប់ជាមួយព្រះរាជអាជ្ញា។ នៅក្នុងករណីបែបនេះ បើព្រះរាជអាជ្ញានោះទទួលយករឿងនោះ ដោយភាពមិនលំអៀង ឬភាពស្វាហាប់ ដើម្បីនាំជននោះទៅកាត់សេចក្ដី ដោយមិនត្រូវប៉ះពាល់ដល់ព្រះរាជអាជ្ញា។ ដូច្នេះ ដើម្បីចៀសវាងការណ៍នេះ វិធានការណ៍មួយដែលសមស្របគឺព្រះរាជអាជ្ញាប្រហែលជាត្រូវដកខ្លួនពីរឿងនេះ កាលណាគាត់ដឹងថាខ្លួនគាត់មានវិសមិតភាពនៅក្នុងរឿងក្ដីនេះ។

### ១.៣.២.៤. ការរើសអើងពូជសាសន៍ និងមតិនយោបាយ

ព្រះរាជអាជ្ញាក្នុងការដំណើរការរឿងក្ដីព្រហ្មទណ្ឌរបស់ខ្លួន ដើម្បីរក្សាភាពមិនលំអៀងរបស់ខ្លួន គួរបំបាត់បុរេនិច្ឆ័យទាក់ទងនឹងពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា និន្នាការនយោបាយ ពិការភាព អាយុ ស្ថានភាពគ្រួសារ ស្ថានភាពសេដ្ឋកិច្ច និងសង្គមឡើយ[42] លើកលែងតែការតម្រូវឱ្យតែបេក្ខជនសម្រាប់ការិយាល័យអយ្យការតែប៉ុណ្ណោះ ដែលត្រូវតែមានសញ្ជាតិនៃប្រទេសរបស់សាមីខ្លួន ដែលគេមិនត្រូវចាត់ទុកថាជាការរើសអើងឡើយ។ នេះជាគោលការណ៍ ដែលចែងនៅក្នុង "គោលការណ៍ណែនាំអំពីតួនាទីរបស់ព្រះរាជអាជ្ញាអង្គការសហប្រជាជាតិ" ទាក់ទងនឹងភាពមិនលំអៀងនៃព្រះរាជអាជ្ញា[43]។ បើជនជាប់ចោទជាមនុស្សមាននិន្នាការយ៉ាងណាក្ដី ក៏ព្រះរាជអាជ្ញាមិនត្រូវរិះរកមធ្យោបាយ ដើម្បីបន្ថែមការចោទប្រកាន់ឡើយ ដោយសារតែខ្លួនមានស្ថានភាពផ្ទាល់ខ្លួន និងទស្សនៈនយោបាយផ្ទុយ ឬស្របនឹងជននោះទេ។ ព្រះរាជអាជ្ញាត្រូវអនុវត្ត គោលការណ៍នៃភាពសន្ទានុម័ត ដែលបានពណ៌នាខាងលើ។ ចំពោះជនជាប់ចោទដែលមានពូជសាសន៍ ឬសាសនាផ្សេងពីព្រះរាជអាជ្ញា អ្នកទាំងនោះត្រូវទទួលបានការប្រព្រឹត្ត ដូចមនុស្សដទៃទៀតនៅក្នុងសង្គមដែរ។

---

[41] ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៥, ១៤ កក្កដា ២០១៤, មាត្រា ៩១

[42] "គោលការណ៍ណែនាំស្ដីពីតួនាទីរបស់ព្រះរាជអាជ្ញា", អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ២ (ក)

[43] "គោលការណ៍ណែនាំស្ដីពីតួនាទីរបស់ព្រះរាជអាជ្ញា", អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១៣ (ក)

**១.៣.២.៥ . ការថ្លែងការណ៍ជាសាធារណៈ**:

ការថ្លែងការណ៍ជាសាធារណៈ គឺជាការពិភាក្សាជាសាធារណៈពាក់ព័ន្ធនឹងសំណុំរឿងដែលកំពុងដំណើរការអាចនាំឱ្យប៉ះពាល់ដល់ដំណើរការស៊ើបអង្កេត និងជំនឿទុកចិត្តលើភាពមិនលំអៀងរបស់ខ្លួន។ ប៉ុន្តែការពិភាក្សាអំពីប្រធានបទច្បាប់ទូទៅជំរុញឱ្យមានការយល់ដឹងជាសាធារណៈ ពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់ និងការគ្រប់គ្រងយុត្តិធម៌។ នៅក្នុងករណីខ្លះការថ្លែងជាសាធារណៈ របស់ព្រះរាជអាជ្ញាអាចជាការឆ្លុះបញ្ចាំងនូវទស្សនៈស្ថាប័នអយ្យការ និងមុខតំណែងអយ្យការរបស់ខ្លួន។ ការថ្លែងទាំងនោះមានដូចជា រឿងដែលមានភាពចំរូងចំរាស់នយោបាយ រឿងដែលពាក់ព័ន្ធនឹងគណបក្សនយោបាយ រឿងដែលនាំឱ្យមានវិវាទ ឬ ការទិតៀនពីបុគ្គលិកអយ្យការដែលមានទស្សនៈផ្ទុយគ្នា រឿងដែលបង្ហាញពីភាពលំអៀង ឬ បុរេវិនិច្ឆ័យចំពោះរឿងក្ដីដែលខ្លួនកំពុងកាន់។[44]

**១.៣.២.៦. ចំណាត់ការនឹងការរំលោភអំណាចរបស់មន្ត្រីសាធារណៈ**:

នៅពេលដែលមានការរំលោភអំណាច ពីមន្ត្រីសាធារណៈ ជួនកាលព្រះរាជអាជ្ញាត្រូវប្រឈមមុខនឹងឥទ្ធិពល ដែលគាបសង្កត់មកលើខ្លួន ដែលជាការមួយធ្វើឱ្យព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តក្នុងការចោទប្រកាន់[45] និងការផ្ដល់រក្សាសុវត្ថិភាពចំពោះព្រះរាជអាជ្ញាអាចធ្វើឱ្យគេ បំពេញភារកិច្ចរបស់គេបានដោយជោគជ័យ[46]។ ដោយឡែក នៅពេលខ្លះទៀត ការរុញរាក្នុងការធ្វើការចោទប្រកាន់កើតចេញពីគំនិតអង្គនិយម ដែលមានន័យថាអ្នកឯករាជ្យ ជាមនុស្សនៅក្នុងអង្គរាជការដូចគ្នា។ គំនិតនេះផ្ទុយ ពីគោលការណ៍ស្មើភាពគ្នានៅចំពោះមុខច្បាប់[47]។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវប្រព្រឹត្តស្មើមុខគ្នា រវាងមនុស្សធម្មតា និងមន្ត្រីរាជការដោយត្រូវលុបបំបាត់ឱ្យអស់នូវគំនិត ដែលនាំឱ្យមានការអនុគ្រោះទៅរកអ្នករាជការគ្នាឯងនេះ។

នៅពេលណាបានដឹងឬទទួលបណ្ដឹងទាក់ទងនឹងមន្ត្រីសាធារណៈព្រះរាជអាជ្ញាត្រូវប្រតិបត្តិខ្លួនឱ្យស្របនឹងច្បាប់ ដោយយកចិត្តទុកដាក់លើការធ្វើបណ្ដឹងអាជ្ញា ចំពោះមន្ត្រីសាធារណៈដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋដទៃទៀត ដែលទទួល

[44] “គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា”, អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ២ (ក)

[45] “គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា”, អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ៤

[46] “គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា”, អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ៥

[47] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ២៣ មីនា ១៩៧៦, មាត្រា ១៤, ចំណុចទី ១

ស្គាល់ដោយច្បាប់ជាតិ និងច្បាប់និងអន្តរជាតិ ហើយការស៊ើបអង្កេតចំពោះបទល្មើសនេះ នៅទីណាដែលមានការអនុញ្ញាតដោយច្បាប់ ឬស្របទៅនឹងការអនុវត្តន៍តាមតំបន់។[48]

[48] "គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា", អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី, ២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំណុចទី ១៥

# ជំពូកទី២
# អង្គការអយ្យការនៅជំណាក់កាល
# ពាក្យបណ្ដឹង

# ជំពូកទី២
# អង្គការអយ្យការនៅដំណាក់កាលពាក្យបណ្ដឹង

## ២.១. អង្គការអយ្យការក្នុងទំនាក់ទំនងទូទៅ

### ២.១.១. ការទទួលពាក្យបណ្ដឹង

ព្រះរាជអាជ្ញា ទទួលពាក្យបណ្ដឹងទាមទារ ឬបរិហារពី៖

- នគរបាលយុត្តិធម៌
- ជនរងគ្រោះ។

**ក. បណ្ដឹងទាមទារ** គឺជាបណ្ដឹងដែលមានគោលបំណងឱ្យមានការជួសជុសនូវសំណងនៃការខូចខាត ដែលបណ្ដឹងមកពីអំពើ ឬសកម្មភាពដែលជាបទល្មើស ឱ្យដល់បុគ្គលដែលរងការខូចខាតទៅដល់ជនរងគ្រោះ។ ជាទូទៅសំណង ដែលភាគីអាចទាមទារបាននោះរួមមាន សំណងផ្នែកសម្ភារៈ ផ្លូវកាយ និងផ្លូវចិត្ត។

**ខ. បណ្ដឹងបរិហារ** គឺជាសេចក្ដីថ្លែងរបស់បុគ្គលណាម្នាក់ ដែលបានដឹងអំពីបទល្មើសប្រាប់ទៅដល់ស្ថាប័នដែលមានសមត្ថកិច្ច ពោលគឺបណ្ដឹងវែកមុខបទល្មើស ឬបកអាត្រាតពីបទល្មើស ដើម្បីឱ្យស្ថាប័នមានសមត្ថកិច្ចបានដឹង ក្នុងគោលបំណងធ្វើឱ្យការត្រួតពិនិត្យ និងស្វែងរកភស្តុតាងក្នុងបទល្មើស ព្រមទាំងបុគ្គលដែលប្រព្រឹត្តបទល្មើស និងបុគ្គលដែលជាប់ពាក់ព័ន្ធផ្សេងទៀត។

❖ គ្រប់ពាក្យបណ្ដឹងទាំងអស់ក្នុងបញ្ជីដោយមានខ្លឹមសារដូចតទៅ៖[49]

- **អត្តសញ្ញាណៈ** នៃអ្នកប្ដឹង
- **កាលបរិច្ឆេទៈ** ដែលអយ្យការបានទទួលពាក្យបណ្ដឹង
- **ប្រភេទនៃបណ្ដឹងៈ** បណ្ដឹងផ្ញើមកផ្ទាល់ចំពោះព្រះរាជអាជ្ញា ឬក៏បញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌
- **ប្រភេទនៃមូលហេតុរឿងៈ** ដែលបានប្ដឹង និងបានរាយការណ៍
- **ចំណាត់ការលើពាក្យប្ដឹងៈ** ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។

សម្រាប់បញ្ជីនៃពាក្យប្ដឹងនេះ ត្រូវបានកាន់កាប់ដោយលេខាធិការរបស់អយ្យការ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ព្រះអាជ្ញា។ ចំពោះបញ្ជីអាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់ ជាអាទិ៍ គឺ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។[50]

---

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥០ កថាខណ្ឌ ២

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥០ កថាខណ្ឌ ៤

❖ ម្យ៉ាងទៀត សៀវភៅទទួលបណ្តឹងព្រហ្មទណ្ឌ គឺសម្រាប់ចុះយកលេខ ថ្ងៃ ខែ ឆ្នាំ របស់សំណុំរឿងដែលស្ថាប័នអយ្យការបានទទួល រួមមានដូចខាងក្រោម៖

- ពាក្យបណ្តឹងពីជនរងគ្រោះ
- របាយការណ៍ពាក្យបណ្តឹងពីមន្ត្រីនគរបាលយុត្តិធម៌
- សំណុំរឿងដែលបានផ្ទេរមកពីសមត្ថកិច្ចផ្សេងៗ
- សំណុំរឿងដែលតុលាការជាន់ខ្ពស់ប្រគល់សមត្ថកិច្ចឱ្យ
- សំណុំរឿងដែលក្រសួងយុត្តិធម៌ប្រគល់សមត្ថកិច្ចឱ្យ។

**២.១.២. ទំនាក់ទំនងជាមួយមន្ត្រីនគរបាលយុត្តិធម៌**

តាមគោលការណ៍នៅក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមិនមែនថ្នាក់លើតាមឋានានុក្រមរបស់នគរបាលយុត្តិធម៌ទេ ប៉ុន្តែជាដៃគូសហការក្នុងការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ និងជួយសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងនគរបាលយុត្តិធម៌។ នៅក្នុង មាត្រា៣៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌក៏បានចែងពីអំណាចរបស់ព្រះរាជអាជ្ញា នៅក្នុងការដឹកនាំ និងសម្របសម្រួលជាមួយសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ ដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[51] ព្រះរាជអាជ្ញាជាអ្នកទទួលកំណត់ហេតុពីនគរបាលយុត្តិធម៌រាយការណ៍ ដើម្បីចាត់ការនៅក្នុងតុលាការពីបទល្មើសមួយ ដែលនគរបាលយុត្តិធម៌រាយការណ៍មកឱ្យខ្លួន។ បន្ថែមពីនេះទៀត ព្រះរាជអាជ្ញាក៏អាចចុះទៅកន្លែងស៊ើបអង្កេត និងធ្វើការណែនាំអំពីអ្វីដែលបានផ្តល់ផលប្រយោជន៍ដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារមន្ត្រីនគរបាល នៅក្នុងមាត្រាដែលបានចែងដោយប្រយោលថា "ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន"[52] ។ ការបញ្ជាដឹកនាំឱ្យមន្ត្រីនគរបាលយុត្តិធម៌សម្រាប់ផ្តល់ឱ្យមកខ្លួននូវព័ត៌មានចាំបាច់ទាំងឡាយ ដើម្បីបន្តសំណុំរឿងនាំជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ទៅតុលាការ។ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌។[53] ជាពិសេស ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ និងអាចពិនិត្យការអនុវត្តវិធានការណ៍ឃាត់ខ្លួន ព្រមទាំងការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួនផងដែរ។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧ កថាខណ្ឌ ១

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧

ដោយសារច្បាប់មិនបានចែងឱ្យជាក់លាក់ ពីទំនាក់ទំនងតាមឋានានុក្រម។ ដូច្នេះ ការត្អូញត្អែរនៅក្នុងកិច្ចសហការ រវាងនគរបាលយុត្តិធម៌ និងអយ្យការនៅតែមានមិនចេះចប់។ ថ្វីបើនគរបាលយុត្តិធម៌ទទួលខុសត្រូវចំពោះថ្នាក់លើតាមឋានានុក្រមរបស់ខ្លួន តែគេត្រូវគោរពគោលការណ៍ណែនាំរបស់ព្រះរាជអាជ្ញា ហើយទន្ទឹមគ្នានោះ ត្រូវរាយការណ៍ជាពត៌មានអំពីសកម្មភាពដែលអនុវត្តទៅថ្នាក់លើនៃនគរបាលរបស់ខ្លួន។ ប៉ុន្តែ ចំពោះដីកាចាប់ខ្លួន និងដីកាស្វែងរកចាប់ខ្លួន ព្រះរាជអាជ្ញាត្រូវបញ្ជូនទៅស្នងការខេត្ត-ក្រុង ឬប្រធានអង្គភាពចំណុះក្រសួងដែលពាក់ព័ន្ធត្រូវចាត់ការឱ្យអ្នកក្រោមបង្គាប់អនុវត្តមិនឱ្យលើសពីមួយអាទិត្យចាប់ពីថ្ងៃទទួលដីកានោះ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចរារាំងមន្ត្រីក្រោមបង្គាប់របស់ខ្លួនមិនឱ្យអនុវត្តដីកា និងសេចក្តីសម្រេចសាលាក្រមដែលព្រះរាជអាជ្ញាដាក់ឱ្យអនុវត្តបានទេ។ មន្ត្រីនគរបាលយុត្តិធម៌រួមមាន អភិបាលរងខេត្ត អភិបាលរងស្រុក-ខណ្ឌ មេឃុំ-សង្កាត់ ដែលត្រូវស្ថិតនៅការដឹកនាំសកម្មភាពនិងសម្របសម្រួល នៃព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាមានអំណាចទៅលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាមន្ត្រីរាជការនេះបំពេញមុខងាររបស់ខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌[54]។

### ២.១.៣. ទំនាក់ទំនងជាមួយចៅក្រមស៊ើបសួរ

នៅពេលដែលព្រះរាជអាជ្ញាទទួលបណ្តឹងទាមទារ ឬបណ្តឹងបរិហារ ឬកំណត់ហេតុមួយ តាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវចុះ ឬបង្គាប់ឱ្យក្រឡាបញ្ជីអយ្យការណាមួយ ឱ្យចុះពាក្យបណ្តឹងក្នុងបញ្ជី នៃពាក្យបណ្តឹងជាបន្ទាន់ ទោះបីជាបទល្មើសជាក់ស្តែងក្តី ឬមិនជាក់ស្តែងក្តី វាខុសគ្នាត្រង់ថា មានខ្លួនជនជាប់សង្ស័យ ឬគ្មាន។ បើសិនជាជាប់បទល្មើសជាក់ស្តែង ហើយមានខ្លួនជាជនជាប់សង្ស័យពិតប្រាកដមែន ព្រះរាជអាជ្ញាអាចសួរយកចម្លើយបាន ដោយគាត់អាចបង្គាប់ឱ្យក្រឡាបញ្ជីអយ្យការណាម្នាក់សួរនាំយកចម្លើយជំនួសខ្លួនបាន ជាបន្ទាប់ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដោយចុះលេខពិសេស ហើយបញ្ជូនទៅប្រធានតុលាការ ដើម្បីចាត់តាំងចៅក្រមស៊ើបសួរ។ ការស្នើសុំនេះ អាចធ្វើឡើងដោយពាក្យសុំដែលមានសំអាងហេតុរបស់ព្រះរាជអាជ្ញា ដែលធ្វើឡើងដោយការផ្តើមគំនិតផ្ទាល់ខ្លួន ឬ តាមរយៈពាក្យប្តឹងរបស់ភាគី។ ប្រសិនបើគ្មានជនសង្ស័យទេ ក្រោយពីទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌មកនោះ ព្រះរាជអាជ្ញាត្រូវធ្វើការស៊ើបអង្កេតបឋមរកវិមតិសង្ស័យតទៅទៀត ដើម្បីទទួលបាននូវតម្រុយចំណុចត្រង់ណាដែលសង្ស័យសម្រាប់ធ្វើការចោទប្រកាន់ដោយសាកសួរដើមបណ្តឹង ជនរងគ្រោះ ឬសាក្សី។ ការផ្តើមចោទប្រកាន់មិនទាន់ជាស្ថាពរ ហើយផ្តើមធ្វើការចោទប្រកាន់ដោយមានតម្រុយឱ្យទៅចៅក្រមស៊ើបសួរ។ កាលណាបានដឹងអំពើនោះ ដែលអាចជា

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨២

បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តធម៌ អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។[55] ដូច្នេះ នៅតាមសាលាដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្តឹង ដែលប្តឹងដោយផ្ទាល់មាត់ពីព្រះរាជអាជ្ញា ឬពីការបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌។

ចំណែកចៅក្រម មានសិទ្ធិអំណាចក្នុងការស៊ើបសួរតែអង្គហេតុដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ក្នុងករណី ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរទទួលបានអង្គហេតុថ្មីនោះ ការស៊ើបសួរទៅលើអង្គហេតុថ្មីនេះអាចប្រព្រឹត្តទៅបាន លុះត្រាតែមានដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញា។ តែប្រសិនប្រសិនអង្គហេតុថ្មីនោះ គ្រាន់តែជាស្ថានទម្ងន់ទោសនៃអង្គហេតុ ដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរពីមុននោះ ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរតាមផ្លូវច្បាប់ ដោយពុំចាំបាច់ជូនដំណឹងទៅតំណាងអយ្យការឡើយ។ ក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវតែមានចែងនូវ[56] សេចក្តីសង្ខេបនៃអង្គហេតុការកំណត់ឈ្មោះបទល្មើស ការបង្ហាញអត្ថបទដែលច្បាប់កំណត់ និងបង្ក្រាបបទល្មើស និងឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរប្រសិនបើអាចកំណត់បាន។

ក្នុងការសង្ខេបនូវអង្គហេតុ ត្រូវមានកំណត់នូវកាលនៃការប្រព្រឹត្តបទល្មើស ដើម្បីឱ្យចៅក្រមស៊ើបសួរអាចធ្វើការកំណត់អំពីអាជ្ញាយុកាលនៃបទល្មើស។ ក្នុងដីកានេះទៀតសោត ត្រូវចុះកាលបរិច្ឆេទនិងការហត្ថលេខានៃតំណាងអយ្យការ ដើម្បីបញ្ជាក់ពីឆន្ទៈក្នុងការចោទប្រកាន់។

## ២.២. អង្គការអយ្យការក្នុងការចោទប្រកាន់

ជាទូទៅនៅពេលដែលមានបទល្មើសមួយកើតឡើង ឬមានអំពើបំពារបំពានកើតមានឡើង គឺតែងតែឃើញមានការដាក់ពាក្យបណ្តឹងពីសំណាក់ជនរងគ្រោះ ឬក៏ក្រុមគ្រួសាររបស់ជនរងគ្រោះ ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ឬអង្គការអយ្យការ ដើម្បីទាមទាររកភាពយុត្តិធម៌ និងសំណងរដ្ឋប្បវេណី។ អង្គការអយ្យការ បានដើរតួនាទីយ៉ាងសំខាន់ ដើម្បីពិនិត្យនិងធ្វើការថ្លឹងថ្លែងចំពោះបទល្មើសទាំងអស់នោះ តើត្រូវតម្កល់រឿងទុកឥតចាត់ការ (មិនចោទប្រកាន់) ឬធ្វើការចោទប្រកាន់?

### ២.២.១. សេចក្តីសម្រេចក្នុងការចោទប្រកាន់

មុននឹងសម្រេចក្នុងការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹងទាមទារ និងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ដែលបាន

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១១១

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៤

បញ្ជូនមកជាមុនសិន[57]។ ក្នុងករណី ដែលបទល្មើសទាំងនោះបានប៉ះពាល់ធ្ងន់ធ្ងរទៅដល់សណ្តាប់ធ្នាប់សង្គម។ ហេតុដូច្នេះ ព្រះរាជអាជ្ញាអាចធ្វើកាចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់ព្រម ទាំងធានារ៉ាប់រងក្នុងការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ និងយកចិត្តទុកដាក់ទៅលើផ្សព្វផ្សាយ ក៏ដូចជាចេញដីកាបង្គាប់ឱ្យចាប់ខ្លួន[58]។ ក្នុងនាមជាអ្នកតំណាងឱ្យសង្គម និងជាម្ចាស់នៃបណ្តឹងអាជ្ញា អយ្យការត្រូវតែមានតំណាងរបស់ខ្លួនជានិច្ច នៅគ្រប់ពេលសវនាការរឿងព្រហ្មទណ្ឌ[59] ដើម្បីទាមទារឱ្យមានការអនុវត្តច្បាប់ដោយតុលាការ។ ហេតុនេះហើយ តើការមានមូលដ្ឋានអ្វីនៅក្នុងការចោទប្រកាន់? និងតើតំណាងអយ្យការមានជម្រើសនៃការចោទប្រកាន់បែបណា ?

**២.២.១.១. មូលដ្ឋាននៃការចោទប្រកាន់**

មូលដ្ឋានសម្រាប់ការចោទប្រកាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ តំណាងអង្គការអយ្យការជាស្ថាប័នចោទមួយ ត្រូវប្រតិបត្តិតាមតួនាទីប្រកបដោយភាពត្រឹមត្រូវតាមបញ្ញត្តិច្បាប់ប្រកបដោយយុត្តិធម៌។ ចំពោះសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការវិញ ជាការធានារ៉ាប់រងនៃសេចក្តីសម្រេចខាងព្រហ្មទណ្ឌ នៅចំពោះមុខតុលាការព្រហ្មទណ្ឌ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ត្រូវគោរពតាមគោលការណ៍នៃដែនអនុវត្តច្បាប់ព្រហ្មទណ្ឌ សម្រាប់ជាមូលដ្ឋាននៅក្នុងការចោទប្រកាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

➢ គោលការណ៍នៃដែនអនុវត្តច្បាប់សម្រាប់មូលដ្ឋានចោទប្រកាន់៖

១. វាយតម្លៃអំពីល្មើសបញ្ជាក់អត្ថបទច្បាប់ (កំណត់បទល្មើសតាមច្បាប់ព្រហ្មទណ្ឌ)

- ចង្អុលបង្ហាញ វាយតម្លៃអំពីសកម្មភាពនៃអំពើល្មើស
- កំណត់អង្គហេតុ (សេចក្តីសង្ខេបនៃអង្គហេតុ)[60] ឬធាតុផ្សំឱ្យបានត្រឹមត្រូវច្បាស់លាស់
- អនុវត្តតាមគោលការណ៍ឱ្យត្រឹមត្រូវនៃច្បាប់ព្រហ្មទណ្ឌ
- អនុវត្តតាមគោលការណ៍ត្រឹមត្រូវនៃការបកស្រាយច្បាប់ព្រហ្មទណ្ឌ
- អនុវត្តគោលការណ៍គ្មានប្រតិសកម្ម

២. ចង្អុលបង្ហាញភស្តុតាង ឬ សាក្សី ។

៣. ចង្អុលបង្ហាញជនប្រព្រឹត្តបទល្មើស ឬ ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវប្រកាសថា ជាអ្នកទទួលខុសត្រូវចំពោះបទល្មើស៖

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤០

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧

[59] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧ កថាខណ្ឌ ៤

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៤

– កំណត់ឈ្មោះ ឬអត្តសញ្ញាណ ឬសាវតាជាតិដែលបុគ្គលប្រព្រឹត្តបទល្មើសច្បាស់លាស់។

៤. កំណត់ទោស និង កំណត់ការអនុវត្តទោស (កំណត់ឈ្មោះបទល្មើស)[61]។

ដូចនេះ ព្រះរាជអាជ្ញាគឺជាអ្នកកាន់នៃច្បាប់រដ្ឋ ក្នុងការការពារផលប្រយោជន៍សិទ្ធិសេរីភាព ក៏ដូចជាការបង្ក្រាបបទល្មើស ប្រកបដោយចរិតលក្ខណៈគតិយុត្តិ ស្របតាមឆន្ទៈរបស់ច្បាប់។ តំណាងអយ្យការត្រូវតែប្រតិបត្តិតាម តួនាទី និងភារកិច្ច របស់ខ្លួន ដោយសម្អាងលើមូលដ្ឋានច្បាប់ច្បាស់លាស់សម្រាប់ការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ។ ក្នុងទិដ្ឋភាពសង្គមមនុស្សដែលឆ្លុះបញ្ចាំងឱ្យឃើញភាពត្រឹមត្រូវ យុត្តិធម៌ និងអាចទទួលយកបានទាំងជនរងគ្រោះ ទាំងការបង្ក្រាបបទល្មើស។

### ២.២.១.២. ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ

ការចោទប្រកាន់របស់តំណាងអយ្យការ ចំពោះបទល្មើសព្រហ្មទណ្ឌ គឺជាការធ្វើបណ្តឹងអាជ្ញារបស់តំណាងអយ្យការដែលជាម្ចាស់នៃបណ្តឹងអាជ្ញា។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌអាចធ្វើបានតាមរយៈ ការបើកការស៊ើបសួរ ការបញ្ជូនរឿងនាំទៅជំនុំជម្រះផ្ទាល់ និងតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[62]។

#### ក. ការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាជម្រើសមួយនៃការធ្វើបណ្តឹងអាជ្ញារបស់តំណាងអយ្យការ។ ការបើកការស៊ើបសួរត្រូវធ្វើឡើងតាមរយៈដីការបញ្ជូនរឿងឱ្យស៊ើបសួរ។ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ[63] ទោះបីជាបទល្មើសនោះជាបទឧក្រិដ្ឋជាក់ស្តែងក៏ដោយ។ ហេតុនេះ ព្រះរាជអាជ្ញាគ្មានជម្រើសណាផ្សេងក្រៅពីការចោទប្រកាន់លើបទល្មើសនេះទេ ត្រង់ចំណុចនេះស្តែងបង្ហាញឱ្យឃើញពីភាពដាច់ខាត នៃការចោទប្រកាន់របស់តំណាងអយ្យការ។ ភាពដាច់ខាតនេះមិនបានស្តែងឡើង ក្នុងករណីបទល្មើសជាបទមជ្ឈិមមិនស្តែង ឬ បទលហុទោ បានន័យថាតំណាងអយ្យការអាចធ្វើការចោទប្រកាន់នៃជម្រើសផ្សេងទៀត ក្រៅពីការស៊ើបសួរ។ ទោះជាយ៉ាងណា តំណាងអយ្យការនៅតែអាចធ្វើការចោទប្រកាន់តាមរយៈការស៊ើបសួរ។ ក្នុងករណីរឿងមិនអាចធ្វើការជនុំជម្រះបានដោយសារកត្តាផ្សេងៗដូចជា ក្នុងករណីតំណាងអយ្យការយល់ឃើញថា ភស្តុតាងដែលប្រមូលពុំមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធ្វើការជំនុំជម្រះ ឬតំណាងអយ្យការមិនស្គាល់នូវអត្តសញ្ញាណរបស់ចារី ដែលជាហេតុមិនអាចយកសំណុំរឿងទៅជំនុំជម្រះបាន ពីព្រោះចារីជាអញ្ញាតជន។ ដូចនេះ ព្រះរាជ

---

[61] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៣

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៤ កថាខណ្ឌទី ១

អាជ្ញាអាចនឹងបើកការស៊ើបសួរ ដើម្បីកំណត់ពីអត្តសញ្ញាណនៃចារីសិន ឬក៏ដើម្បីប្រមូលនូវភស្តុតាងបន្ថែមទៀត សម្រាប់ដំណើរការនីតិវិធី។

### ខ. ជំនុំជម្រះផ្ទាល់

ការជំនុំជម្រះផ្ទាល់អាចត្រូវបានបើកតាមរយៈ ដីកាកោះហៅបញ្ជូនទៅជំនុំជំម្រះផ្ទាល់។ ក្នុងករណីបទលហុជម្រើសនៃការចោទប្រកាន់ គឺមានតែទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។ ការជំនុំជម្រះផ្ទាល់ អាចអនុវត្តតែចំពោះសាលាជាន់ដំបូងទេ[64] ព្រោះមិនអាចប្រើនៅតុលាការជាន់ខ្ពស់ ដែលជាតុលាការទទួលបណ្តឹងតវ៉ាឡើយ ដោយសារការប្តឹងតវ៉ា គឺសុទ្ធសឹងតែត្រូវមានការស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងបន្ថែម ដើម្បីបំពេញនូវចំណុចខ្វះចន្លោះនៃកម្មវត្ថុបណ្តឹងតវ៉ានោះ ដែលផ្ទុយទៅនឹងនីតិវិធីការជំនុំជម្រះផ្ទាល់ ដែលជានីតិវិធីមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់រួចហើយ។

ការជំនុំជម្រះផ្ទាល់ គឺអាចអនុវត្តបានក្នុងករណី បទមជ្ឈិម ឬបទលហុ ដែលជាបទល្មើសមានលក្ខណៈស្រាល ហើយបទល្មើសនោះគឺត្រូវមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវមានកំណត់អត្តសញ្ញាណនៃជនជាប់ចោទ សេចក្តីសង្ខេបនៃអង្គហេតុ ឈ្មោះបទល្មើស និងអត្ថបទច្បាប់ដែលកំណត់ក៏ដូចជាបង្ក្រាបបទល្មើស ជាពិសេសមានការចង្អុលបង្ហាញប្រាប់ពីតុលាការដែលត្រូវជំនុំជំម្រះ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងពេលវេលានៃសវនាការ។ ម្យ៉ាងវិញទៀត ដីកានោះត្រូវមានបញ្ជាក់ថាជនជាប់ចោទនៅចំពោះមុខតុលាការ៖

- ១៥ ថ្ងៃ ប្រសិនជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- ២០ ថ្ងៃ ប្រសិនជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ ខែ ប្រសិនបើជាជាប់ចោទរស់នៅក្នុងរដ្ឋជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ ខែ ប្រសិនជនជាប់ចោទកន្លែងផ្សេង ក្រៅពីករណីខាងលើ។[65]

### គ. ការបង្ហាញខ្លួនភ្លាម

ជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ តាមរយៈការជំនុំជម្រះផ្ទាល់ គឺជានីតិវិធីឆាប់រហ័ស មានន័យថា ជនល្មើសអាចត្រូវយកទៅជំនុំជម្រះភ្លាម ក្រោយការឃាត់ខ្លួន។ នីតិវិធីនេះមិនអាចយកមកអនុវត្តចំពោះបទឧក្រិដ្ឋដែលជាកម្មវត្ថុនៃការស៊ើបសួរ និងបទលហុដែលជាកម្មវត្ថុនៃការជំនុំជម្រះផ្ទាល់បានឡើយ។

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៦ កថាខណ្ឌទី ១

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៥៧

❖ ដើម្បីអនុវត្តនូវនីតិវិធីនេះបានត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម[66]៖

- បទល្មើសនោះត្រូវតែជាបទមជ្ឈិមជាក់ស្តែង តាមបញ្ញត្តិមាត្រា៨៦ ឬមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- បទល្មើនោះត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារយ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ
- នីតិវិធីនេះអនុវត្តចំពោះតែចារីជានីតិជន
- ជាពិសេសរឿងក្តីនោះត្រូវមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន។

ពាក្យថា "គ្រប់គ្រាន់ជំនុំជម្រះបាន" មានន័យថាមានភស្តុតាងគ្រប់គ្រាន់ធួនល្មមដែលអាចបំពេញគ្រប់សញ្ញាណនៃធាតុផ្សំបទល្មើស ដែលប្រព្រឹត្តដោយជនជាប់ចោទហើយមានលក្ខណៈអាចជឿជាក់បាន ថាជនជាប់ចោទ ពិតជាចារីបានប្រព្រឹត្តបទល្មើសពិតប្រាកដមែន។

ជានីតិវិធីជាក់ស្តែងក្រោយពីការឃាត់ខ្លួន ជនល្មើសនឹងត្រូវបានបញ្ជូនទៅបង្ហាញខ្លួន នៅចំពោះមុខតំណាងអយ្យការ ដើម្បីធ្វើការសាកសួរអំពីអត្តសញ្ញាណប្រាប់ពីការចោទប្រកាន់ប្រាប់ពីបញ្ញត្តិច្បាប់ដែលត្រូវចោទ និងប្រាប់ពីសិទ្ធិមួយចំនួនដែលនោះត្រូវដឹង ហើយតំណាងអយ្យការត្រូវទទួលចម្លើយរបស់ជននោះ ប្រសិនបើគាត់ចង់និយាយ គឺត្រូវធ្វើកំណត់ហេតុអំពីការបង្គាប់ឱ្យចូលខ្លួនភ្លាម[67]។ ជាពិសេស តំណាងអយ្យការត្រូវឱ្យជនជាប់ចោទដឹងថារឿងក្តីនេះ អាចនឹងត្រូវយកទៅជំនុំជម្រះនៅថ្ងៃនេះភ្លាមតែម្តង ហើយតើជនជាប់ចោទត្រូវការមេធាវីតាមការចាត់តាំង ឬការជ្រើសរើសមេធាវីដោយខ្លួនឯង។ ការបង្ហាញខ្លួននេះនឹងត្រូវអនុវត្តតាមរយៈការធ្វើកំណត់ហេតុស្តីពីការចូលខ្លួនភ្លាម។

### ២.២.២ ការតម្កល់រឿងទុកឥតចាត់ការ

ទោះបីជាអយ្យការ មានតួនាទីក្នុងការចោទប្រកាន់អំពើបទល្មើសក៏ពិតមែន ក៏ពុំមានន័យថាគ្រប់បទល្មើសដែលបានកើតឡើងហើយត្រូវបានចោទប្រកាន់ជាដរាបនោះឡើយ។ ដោយសារតែអំពើខ្លះ ព្រះរាជអាជ្ញាមិនអាចមានសិទ្ធិចោទប្រកាន់ ឬធ្វើការចោទប្រកាន់ដោយមិនទទួលបានផលប្រយោជន៍ សម្រាប់សង្គម និងដោយសារមូលហេតុទៅតាមផ្លូវច្បាប់ដទៃផ្សេងទៀត។ បន្ថែមពីនេះទៀតបទល្មើសខ្លះ មិនបានបណ្តាលឱ្យមានផលប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈសម្រាប់សង្គមអ្វីឡើយ គឺគ្រាន់តែជាអំពើដែលនាំឱ្យមានត្រឹមតែព្យសនកម្មបន្តិចបន្តួចតែប៉ុណ្ណោះ។ នៅពេលដែលព្រះរាជអាជ្ញាទទួលពាក្យបណ្តឹងពីជនរងគ្រោះដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ក៏ខ្លួននៅតែមានឆន្ទានុសិទ្ធិគ្រប់គ្រាន់ផងដែរ នៅក្នុងការសម្រេចចិត្តចោទ

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៧

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤៨ កថាខណ្ឌទី ១

ប្រកាន់ ឬមិនគួរចោទប្រកាន់ទៅលើបទល្មើសនោះ។ ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្ដឹង និងពាក្យប្ដឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬ ដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក[68]។

ស្របតាមការថ្លឹងថ្លែងនៅក្នុងតួនាទីវិជ្ជាជីវៈ និងតាមសតិសម្បជញ្ញៈរបស់ខ្លួនអយ្យការគួរធ្វើការពិចារណាទាក់ទងនឹងអំពើល្មើសនោះ ហើយប្រសិនបើមិនគួរចោទប្រកាន់ គឺអយ្យការនឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ តំណាងអយ្យការអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ចំពោះអំពើដែលមិនមែនជាបទល្មើសផង និងអំពើដែលជាបទល្មើសផងដែរ។ ដើម្បីឱ្យកាន់តែច្បាស់យើងមានជាចំណោទបញ្ហាទាំងនេះ តើអ្វីទៅអ្វីទៅជាអត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ? តើមានមូលហេតុអ្វីខ្លះដែលនាំឱ្យតម្កល់រឿងទុកឥតចាត់ការ? តើមានសមត្ថកិច្ចណាខ្លះនៅក្នុងការតម្កល់រឿងទុកឥតចាត់ការនេះ? តើមាននីតិវិធី និងអានុភាពបែបណានៃការតម្កល់រឿងទុកឥតចាត់ការ?

**២.២.២.១. អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ**

នៅក្នុងដំណើររឿងក្ដីព្រហ្មទណ្ឌ ដើម្បីឱ្យស្របតាមនីតិវិធីនៃដំណើររឿងក្ដីព្រហ្មទណ្ឌ ត្រូវបានបែងចែកជាបួនដំណាក់កាលធំៗគឺៈ

- ដំណាក់កាលស៊ើបអង្កេត (ធ្វើឡើងដោយនគរបាលយុត្តិធម៌)
- ដំណាក់កាលចោទប្រកាន់ (ធ្វើឡើងដោយតំណាងអយ្យការ)
- ដំណាក់កាលស៊ើបសួរ (ធ្វើឡើងដោយចៅក្រមស៊ើបសួរ)
- និងដំណាក់កាលជំនុំជម្រះ (ជាតួនាទីចៅក្រមជំនុំជម្រះ)។

នៅដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នអយ្យការ (ជាម្ចាស់នៃបណ្ដឹងអាជ្ញា) ដែលអាចសម្រេចចោទប្រកាន់ និងបញ្ជូនរឿងទៅយុត្តាធិការស៊ើបអង្កេត និងយុត្តាធិការជនុំជម្រះ ដើម្បីធ្វើចំណាត់ការបន្ត។ ក្រៅពីធ្វើការចោទប្រកាន់ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា៤០ កថាខណ្ឌទី ២ ក៏បានផ្ដល់អំណាចមួយទៀតទៅដល់អយ្យការគឺ ការតម្កល់រឿងទុកឥតចាត់ការដែលបានបញ្ញត្តិថា ព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតការ រួចធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ។[69] តាមខ្លឹមសារនេះផងដែរ មានន័យថាព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ផង និងតម្កល់រឿងទុកឥតចាត់ការបានផងដែរ ចំពោះបទល្មើសព្រហ្មទណ្ឌ។

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤០ កថាខណ្ឌ ១

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤០ កថាខណ្ឌទី ២

**២.២.២.២. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**

មូលហេតុដែលនាំឱ្យ តំណាងអយ្យការជ្រើសយកនីតិវិធីនេះមកប្រើ គឺសំដៅដល់គ្រប់មូលហេតុដែលតំណាងអយ្យការសម្រេចដោយឆន្ទានុសិទ្ធិ ថាមិនប្រើនីតិវិធីចោទប្រកាន់។ ការតម្កល់រឿងទុកឥតចាត់ការ គឺមានមូលហេតុផ្សេងៗគ្នា ដែលតំណាងអយ្យការប្រើនីតិវិធីក្នុងការអនុវត្តមានដូចតទៅៈ

**ក. គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់**

គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ គឺចង់សំដៅទៅលើការដែលមានមូលហេតុនៃអត្តសញ្ញាណរបស់ចារី ឬពុំមានបន្ទុកគ្រប់គ្រាន់ ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ចារី ហើយការស្រាវជ្រាវបន្ថែមដែលអាចនឹងធ្វើហាក់បីដូចជា គ្មានប្រយោជន៍ និងគ្មានប្រសិទ្ធិភាព និងការអវត្តមានរបស់ជនល្មើស ឬ បទល្មើសមិនមានលក្ខណៈគ្រប់គ្រាន់ជាអាទិ៍ ធាតុផ្សំនៃសំណុំរឿងមិនអនុញ្ញាតឱ្យកំណត់ពីធាតុផ្សំបទល្មើសដែលគេរាយការណ៍មក។ *ឧទាហរណ៍ៈ* នៅក្នុងរឿងក្តីព្រហ្មទណ្ឌមួយបានកើតឡើង ដែលមានការលួចកង់របស់អ្នកជិតខាង ហើយបានបាត់រហូត និងពុំបានដឹងពីភិនភាគរបស់ចារី ឬពុំមានភស្តុតាងមកបញ្ជាក់ ហើយមានការស្រាវជ្រាវពីក្រុមអ្នកជំនាញ ដោយពុំបានដឹងថាពីមូលហេតុនៃការបាត់នោះទេ។ ហេតុដូច្នេះ ការដាក់បន្ទុកក្នុងការលួចគឺគ្មានប្រយោជន៍ឡើយ។ ក្នុងន័យនេះ គឺតំណាងអយ្យការអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបានដោយត្រូវសំណងតាម គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ទៅលើបទល្មើសនោះ។

គោលការណ៍នេះមានចំណុចបន្ថែម ក្នុងការតម្កល់រឿងទុកឥតចាត់ការ ដោយយកគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់មានដូចតទៅៈ

❖ **អំពើមិនមែនជាបទល្មើស**

ការកំណត់នៃអំពើដែលមិនមែនជាបទល្មើស គឺសំដៅទៅលើការប្រព្រឹត្តអំពើណាមួយហើយគ្មានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ នោះគឺអំពើដែលមិនមែនជាបទល្មើស ឬក៏ជាការប្រព្រឹត្តទៅហើយគ្មានច្បាប់ចែង។ ក្នុងច្បាប់បានបញ្ញាតិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កចលាចលដល់សង្គម គឺជាបទល្មើស។ បទល្មើស ចង់សំដៅទៅលើអំពើ ឬបាតុភាពអសកម្មផ្សេងៗនៅក្នុងជីវភាពរស់នៅ ដោយបានបំពានធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងរបៀបរៀបរយ នៅក្នុងពាសពេញផ្ទៃប្រទេស។ ពោលអំពើទាំងឡាយណា ដែលបានបំពានដល់ច្បាប់ចូលជាធរមាន ឬអំពើនោះបានប្រព្រឹត្តផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ គឺចាត់ទុកជាបទល្មើសព្រហ្មទណ្ឌហើយ។ ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនេះ គឺមានបំណងដាក់ទណ្ឌកម្មទៅជនណា ដែលបានប្រព្រឹត្តកំហុសខុសឆ្គងមាន ផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈយ៉ាងធ្ងន់ធ្ងរ ដើម្បីឱ្យមានការរាង

ចាលលែងហ៊ានប្រព្រឹត្តម្តងទៀតនៅលើកក្រោយ និងជួយបញ្ចៀសហានិភ័យ ដែលអាចកើតឡើងមាននៅក្នុងសង្គម។ ដោយយោងតាមមាត្រា ២ នៃក្រមព្រហ្មទណ្ឌ បទល្មើស គឺចង់សំដៅទៅដល់អំពើខ្លះរបស់រូបវន្តបុគ្គល និងនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស។[70]

**ឧទាហរណ៍៖** លោក ក ជាបុរសពោះម៉ាយម្នាក់ បានរំលោភសត្វគោរបស់ លោក ខ។ នៅពេលដែលធ្វើសកម្មភាព លោក ខ ក៏បានប្រទះឃើញនូវទង្វើមិនសមរម្យបែបនេះទើប លោក ខ ក៏បានប្តឹងទៅនគរបាលយុត្តិធម៌ ក៏ប៉ុន្តែដោយគ្មានច្បាប់ចែងពីបទល្មើសរំលោភសត្វនោះទេ។ ដូច្នេះ លោក ក ពុំត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ហើយអយ្យការអាចតម្កល់រឿងទុកឥតចាត់ការបាន។

❖ **ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់**

ដើម្បីចាត់ទុកអំពើមួយជាបទល្មើសព្រហ្មទណ្ឌ ចាំបាច់ត្រូវតែមានធាតុផ្សំនៃបទល្មើស ៣ ដែលជាទូទៅមានដូចជា៖

– ធាតុនីត្យានុកូល (មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ)[71]

– ធាតុសត្យានុម័ត

– ធាតុអត្តនោម័ត (មាត្រា ៤ នៃក្រមព្រហ្មទណ្ឌ)។[72]

ដូចនេះ ប្រសិនបើកង្វះនូវធាតុផ្សំណាមួយ តំណាងអយ្យការនឹងធ្វើសេចក្តីសម្រេចដោយ តម្កល់រឿងទុកឥតចាត់ការ។ *ឧទាហរណ៍៖* លោក ក បានប្តឹង លោក ខ ថាបានលួចទូរស័ព្ទរបស់ខ្លួន ប៉ុន្តែពុំមានភស្តុតាងណាក្នុងការមកបញ្ជាក់ពី អំពីអំពើទុច្ចរិតដែលជាធាតុផ្សំនៃបទល្មើសថា លោក ខ បានលួចទូរស័ព្ទរបស់ លោក ក ឡើយ។

❖ **មិនអាចកំណត់អត្តសញ្ញាណជនល្មើសបាន**

ការមិនអាចកំណត់ពីអត្តសញ្ញាណនៃជនល្មើសបាន គឺចង់សំដៅទៅដល់ការដែលមិនស្គាល់ពី ភិនភាគមុខមាត់ រូបរាង កម្ពស់ សម្បុរ របស់ចោរ ហើយមិនបានដឹងពីទីកន្លែងស្នាក់នៅផ្ទាល់របស់ចោរផងដែរ។ ផ្ទុយមកវិញការដែល មិនអាចកំណត់អត្តសញ្ញាណជនល្មើសបានមិនដាច់ខាតត្រូវតែ តម្កល់រឿងទុកឥតចាត់ការឡើយ ពីព្រោះអយ្យការមានជម្រើសក្នុងការបើកការឱ្យស៊ើបសួរ ដែលប្តឹងទៅចៅក្រមស៊ើបសួរ។ *ឧទាហរណ៍៖* លោក ក បានប្តឹងពីជនដែលមិនស្គាល់មុខ ពីបទឆបោក ប៉ុន្តែទោះបីជាស្វែងរកយ៉ាងណា ក៏ពុំអាចដឹងពីអត្តសញ្ញាណនៃជនល្មើសនោះឡើយ។ ស្របតាមន័យនេះតំណាងអយ្យការអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។

---

[70] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២

[71] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣

[72] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤

❖ **បុគ្គលដែលមានអភ័យឯកសិទ្ធិ**

ចំពោះជនដែលមានអភ័យឯកសិទ្ធិពុំអាចធ្វើការចោទប្រកាន់បានឡើយ។ បើជននោះលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ និងទ្រព្យសម្បត្តិសហាព័ទ្ធរបស់ខ្លួន គឺមិនអាចផ្តន្ទាទោសព្រហ្មទណ្ឌបានទេ ចំពោះជនដែលបានប្រព្រឹត្តបទល្មើសលួចនោះ (អំពើលួចទ្រព្យសម្បត្តិ)[73]។ *ឧទាហរណ៍៖* លោក ក បានសុំលុយម្តាយ ប៉ុន្តែ ម្តាយមិនឱ្យហើយ លោក ក ក៏សម្រេចចិត្តលួចលុយម្តាយរបស់ខ្លួនទៅ នៅពេលដែលម្តាយគាត់កំពុងតែលក់ដូរ។ ដូច្នេះ លោក ក មានអភ័យឯកសិទ្ធិគ្រួសារ ពុំបានមានការចោទប្រកាន់បានឡើយ។

❖ **អនីតិជនដែលមានអាយុតិចជាង១៤ឆ្នាំ**

បុគ្គលដែលមិនទទួលខុលត្រូវព្រហ្មទណ្ឌ គឺជាបុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺអាយុ ១៨ឆ្នាំ ឡើងទៅ[74] ប៉ុន្តែក៏មានការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់អនីតិជនគឺចាប់ពីអាយុ ១៤ ឆ្នាំ ឡើងទៅផងដែរ[75]។ ដូចនេះ អនីតិជនដែលមានអាយុក្រោយ ១៤ ឆ្នាំ គឺមិនទទួលខុសត្រូវនោះទេ។

❖ **ការរលត់នៃបណ្តឹងអាជ្ញា**

ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា មួយចំនួននៅមានការយល់ច្រឡំថា បណ្តឹងអាជ្ញានឹងត្រូវបានបញ្ចប់ ឬរលត់ នៅពេលដែលជនត្រូវបានសន្មតថាបានប្រព្រឹត្តបទល្មើស និងសងសំណងជម្ងឺចិត្តទៅដល់ភាគីដែលជាជនរងគ្រោះ ហើយភាគីជនរងគ្រោះក៏បានដកពាក្យបណ្តឹង (បណ្តឹងរដ្ឋប្បវេណី)។ តាមគោលការណ៍ ច្បាប់ ទោះបីជាសំណងជម្ងឺចិត្តត្រូវបានផ្តល់ជូនភាគីជនរងគ្រោះ និងមានការសម្របសម្រួល ឬក៏ដកពាក្យបណ្តឹងពីសំណាក់ភាគីជនរងគ្រោះហើយក៏ពិតមែន ក៏បណ្តឹងអាជ្ញានៅតែមិនរលត់ឡើយ។ ការដកបណ្តឹងរដ្ឋប្បវេណីរបស់ភាគីរងគ្រោះ គឺគ្រាន់តែជាការបញ្ចប់នូវការទាមទារ ខាងផ្នែកសំណងរដ្ឋប្បវេណីរបស់ភាគីជនរងគ្រោះតែប៉ុណ្ណោះ គឺមិនមែនជាកត្តាដែលអាចនាំឱ្យបណ្តឹងអាជ្ញារលត់នោះទេ។ ដោយយោងតាមមាត្រា ៧ មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការរំលត់បណ្តឹងអាជ្ញា គឺមានមូលហេតុដូចខាងក្រោមនេះ៖

**១. មរណភាពនៃជនល្មើស**

ក្នុងករណីដែលជនល្មើស ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ត្រូវបានទទួលមរណភាព ដែលកំពុងស្ថិតក្នុងបណ្តឹងអាជ្ញា ឬស្លាប់មុនពេលប្រកាសសេចក្តីសម្រេចជាស្ថាពរក្នុងការផ្តន្ទាទោសជនល្មើស នោះ

[73] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៥៥

[74] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៨

[75] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩

នាំឱ្យបណ្តឹងអាជ្ញាដែលកំពុងតែមានលើជននោះត្រូវបានរលត់ ហើយដំណើរការទាំងឡាយនៃនីតិវិធីនឹងត្រូវបិទ ហើយបញ្ចប់។ ហេតុដូច្នេះមានន័យថា ព្រះរាជអាជ្ញាមិនអាចចោទប្រកាន់ និងអនុវត្តទោសចំពោះមនុស្សដែលបានទទួលមរណភាពរួចទៅហើយឡើយ។ ម៉្យាងវិញទៀតក្នុងករណីនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឱ្យមានការជួសជុលព្យសនកម្ម ពីសិទ្ធិវ័ន្តនៃជនជាប់ចោទបានហើយតុលាការព្រហ្មទណ្ឌនៅតែបន្តមានសមត្ថកិច្ចលើបណ្តឹងរដ្ឋប្បវេណីនោះផងដែរ ដើម្បីជាថ្នូរនៃជនរងគ្រោះ។

### ២. ការផុតអាជ្ញាយុកាល

អាជ្ញាយុកាល គឺជាពេលវេលាកំណត់មួយ ដែលមាននៅក្នុងច្បាប់ បានកំណត់ពីរយៈពេលដែលអាចធ្វើ ឬចាប់ផ្តើមធ្វើបណ្តឹងអាជ្ញាបាន។ ប្រសិនបើសកម្មភាពល្មើសមួយត្រូវបានកើតឡើង ដែលនាំឱ្យមានគិតអំពីអាជ្ញាយុកាលនៃបទល្មើសត្រូវបានចាប់ផ្តើម ហើយដល់រយៈពេលកំណត់នៅតែមានបណ្តឹងអាជ្ញាណាមួយត្រូវបានកើតឡើងដែលពាក់ព័ន្ធនឹងសកម្មភាពនោះ នាំឱ្យបណ្តឹងអាជ្ញាត្រូវបានរលត់ ដោយសារមូលហេតុនៃការផុតអាជ្ញាយុកាលនៃបទល្មើស។

- អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានរយៈពេលខុសៗគ្នា តាមប្រភេទបទល្មើសនីមួយៗរយៈពេល៖
- ១៥ (ដប់ប្រាំ)ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ)ឆ្នាំ ចំពោះបទមជ្ឈិម
- និង ១ (មួយ)ឆ្នាំ ចំពោះបទលហុ ។[76]

ចំពោះបទល្មើស បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម គឺមិនអាចផុតអាជ្ញាយុកាលបានទេ។[77] ដូចគ្នាទៅនឹង ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដែលជាអំពើនីត្យានុកូលគឺត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ ឆ្នាំបន្ទាប់ពីពេលដែលជនរងគ្រោះ បានដឹងអាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬអំឡុងពេល ១០ ឆ្នាំ បានកន្លងហួសទៅ បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង។ ដោយឈរលើគោលការណ៍ការបែងចែកបណ្តឹងទាំងពីរជាបណ្តឹងផ្សេងពីគ្នា នោះការផុតអាជ្ញាយុកាលនៃបណ្តឹងណាមួយ មិនមែនជាឧបសគ្គសម្រាប់ការធ្វើបណ្តឹងមួយទៀតឡើយ។

### ៣. ការលើកលែងទោសទូទៅ

ការលើកលែងទោសទូទៅ ខុសពីកាលពីលើកលែងទោស ដោយជារាជានុសិទ្ធិរបស់ព្រះមហាក្សត្រដែលមានចែងនៅក្នុងច្បាប់ដែលជាទូទៅធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងឱកាសព្រះរាជពិធីបុណ្យធំៗ។ បណ្តឹងជាមួយអាច

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩

នឹងត្រូវរលត់តាមរយៈការលើកលែងទោសនេះ ជាទូទៅ ការលើកលែងទោសនេះសំដៅទៅលើការធ្វើច្បាប់ដែលអនុម័តដោយរដ្ឋសភា ក្នុងគោលបំណងសម្រាប់លើកលែងទោស ឬ លុបចោលនូវប្រភេទបទល្មើសណាមួយនាំឱ្យបណ្តឹងអាជ្ញា ដែលកំពុងតែដំណើរការនៅក្នុងនីតិវិធីនឹងត្រូវរលត់។

**៤. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ**

បណ្តឹងអាជ្ញាណាមួយត្រូវបានធ្វើឡើង តាមរយៈនៃការចោទប្រកាន់របស់អយ្យការ ក្នុងបទល្មើសព្រហ្មទណ្ឌណាមួយ ប៉ុន្តែដោយហេតុថា បទល្មើសដែលត្រូវបានចោទប្រកាន់នោះ ត្រូវបាននិរាករណ៍ដោយមានច្បាប់ព្រហ្មទណ្ឌថ្មី ។ ហេតុនេះហើយ បណ្តឹងអាជ្ញាដែលធ្វើឡើង ដោយឈរលើមូលដ្ឋាននៃបទល្មើស ដែលមានចែងនៅក្នុងច្បាប់នឹងត្រូវរលត់។

**៥. អាជ្ញាអស់ជំនុំ**

កាលណាអង្គហេតុនៃបទល្មើសណាមួយត្រូវបានកើតឡើង ហើយត្រូវបានចោទប្រកាន់ដោយអយ្យការ និងមានការជំនុំជម្រះសេចក្តីរហូតដល់មាន សាលក្រម ឬ សាលដីកា។ ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។[78] ដូចនេះមានន័យថាក្រោយសេចក្តីសម្រេចជាស្ថាពររួចហើយ ទោះបីជាមានលេចឡើងនូវភស្តុតាងថ្មី ដែលអាចបញ្ជាក់ថាពិតជាមានបទល្មើសបានប្រព្រឹត្តមែនក៏ដោយ ក៏បណ្តឹងអាជ្ញាមិនអាចដាក់ឱ្យដំណើរការបានដែរ ព្រោះវាមានអាជ្ញាអស់ជំនុំហើយ។

- មូលហេតុផ្សេងទៀត នៃការរលត់បណ្តឹងអាជ្ញា៖

ក្រៅពីមូលហេតុខាងលើ នៅមានមូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា ដែលនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៨ ក៏បានកំណត់បន្ថែមអំពីមូលហេតុទាំងនោះមានដូចខាងក្រោម៖

- ការសម្របសម្រួលជាមួយរដ្ឋ
- ការដកពាក្យបណ្តឹង
- ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល។[79]

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨

### ៦. ការសម្របសម្រួលជាមួយរដ្ឋ

ការសម្របសម្រួលជាមួយរដ្ឋ គឺជាមួយហេតុអាចធ្វើឱ្យបណ្តឹងផុតរលត់បានដែរ តាមរយៈការបង់ប្រាក់ពិន័យអន្តរកាលជូនរដ្ឋ។ *ឧទាហរណ៍៖* ពិន័យមានការបំពារបំពាន ឬ ល្មើសអំពីល្មើសចរាចរណ៍ផ្លូវគោកជាដើម។ ជាគោលការណ៍ ការសម្របសម្រួលជាមួយរដ្ឋ គឺមិនអាចធ្វើទៅបានឡើយចំពោះបទល្មើសព្រហ្មទណ្ឌ។ ប៉ុន្តែច្បាប់ពិសេស អាចអនុញ្ញាតឱ្យរលត់បណ្តឹងអាជ្ញាបានផងដែរ។ ដែលការរលត់បណ្តឹងអាជ្ញានេះ ពុំអាចធ្វើឱ្យបណ្តឹងផ្នែករដ្ឋប្បវេណីរលត់បាននោះទេ[80]។

### ៧. ការដកពាក្យបណ្តឹង

ការដកពាក្យបណ្តឹង អាចធ្វើឱ្យបណ្តឹងអាជ្ញាផុតរលត់បានផងដែរ ប្រសិនបើពាក្យប្តឹងជនរងគ្រោះនោះគឺជាលក្ខខណ្ឌដែលចាំបាច់មួយក្នុងការដាក់ឱ្យបណ្តឹងអាជ្ញាមានចលនា។ ដូច្នេះ មានន័យថាក្នុងបទល្មើសមួយចំនួន ព្រះរាជអាជ្ញាមិនអាចធ្វើបណ្តឹងអាជ្ញាឱ្យមានចលនា ដោយគ្មានពាក្យប្តឹងរបស់ជនរងគ្រោះឡើយ ដូចជាបទបរិហារកេរ្តិ៍ និងបទជេប្រមាថ[81]។ ក្នុងករណីនេះ ការដកពាក្យប្តឹងពីជនរងគ្រោះក៏អាចធ្វើឱ្យបណ្តឹងអាជ្ញាផុតរលត់ផងដែរព្រោះជនរងគ្រោះ គឺជាអ្នកទទួលរងគ្រោះរងខ្លាំងបំផុតក្នុងទំនាក់ទំនងបទល្មើសនេះទើបច្បាប់ព្រហ្មទណ្ឌបានកំណត់សិទ្ធិអំណាចឱ្យជនរងគ្រោះជាអ្នកសម្រេចពីការធ្វើបណ្តឹងអាជ្ញានេះ។

### ៨. ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល[82]

ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល គឺអាចធ្វើឱ្យបណ្តឹងអាជ្ញាផុតរលត់បានលុះត្រាតែមានការ ទទួលស្គាល់ដោយជនសង្ស័យជាមុនសិន អំពីអំពើនៃការចូលរួមប្រព្រឹត្តបទល្មើសរបស់ខ្លួន ហើយត្រូវមានការព្រមព្រៀងធ្វើឱ្យរលត់បណ្តឹងអាជ្ញា។

## ខ. គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

### ១. អត្ថន័យ

គោលការណ៍កាលានុវត្តភាពនៃចោទប្រកាន់ គឺជាការតម្កល់រឿងទុកឥតចាត់ការ ដែលអាចធ្វើបានទោះបីជាមានបទល្មើស និងអ្នកប្រព្រឹត្តត្រូវបានស្គាល់មុខក៏ដោយ ពីព្រោះតំណាងអយ្យការយល់ថាការតម្កល់រឿងទុកឥតចាត់ការនេះ បានត្រូវតាមកាលៈទេសៈនៃព្យសនកម្មដែលកើតមានដោយសារបទល្មើស ឬភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ ហើយមានលក្ខណៈធ្ងន់ធ្ងរ ឬដោយសារបុគ្គលិកលក្ខណៈរបស់ចារី ឬអត្តចរិត

[80] នីតិវិធីព្រហ្មទណ្ឌ, ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត, ឆ្នាំ ២០១៦-២០១៧, ទំព័រទី ៦

[81] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣០៩

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១

របស់ជនរងគ្រោះ[83]។ *ឧទាហរណ៍៖* មានបទល្មើសមួយ ដែលអនីតិជនបានលួចបេះផ្លែស្វាយរបស់អ្នកជិតខាងខ្លួន ដើម្បីតម្រូវការក្រពះ នៃភាពស្រេកឃ្លានរបស់ខ្លួន ហើយក្មេងនោះគឺបានកំព្រាឪពុកម្តាយគ្មានអ្នកចិញ្ចឹមដូចគេនោះទេ។ បន្ថែមពីនេះទៀត ក្មេងនោះមានចរិតស្លូតបូត សុភាពរាបសា ហើយចេះគោរពចាស់ទុំ និងមានភាពស្មោះត្រង់ មិនដែលមានទង្វើទុច្ចរិតបែបនេះទេ ពីមុនមកនោះទេ។ ក្នុងន័យនេះ តំណាងអយ្យការអាចលើកយកគោលការណ៍កាលានុវត្តភាពនៃការការចោទប្រកាន់ ដើម្បីតម្កល់រឿងទុកឥតចាត់ការបាន ដោយមានសំអាងហេតុ និងសំអាងច្បាប់ច្បាស់លាស់[84]។

គោលការណ៍នេះមានចំណុចបន្ថែម ដែលនិយាយពីការតម្កល់រឿងទុកឥតចាត់ការ ដែលលើកយកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់មកបកស្រាយបន្ថែម ដូចខាងក្រោម៖

### ២. លក្ខណៈវិនិច្ឆ័យ

#### ❖ ព្យសនកម្មតិចតួច

យើងបានដឹងហើយថា ការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ គឺមិនមែនចេះតែធ្វើការចោទប្រកាន់នោះទេ ពីព្រោះអំពើមួយចំនួនទាមទារឱ្យព្រះរាជអាជ្ញាមានការថ្លឹងថ្លែង ចំពោះបទល្មើសនោះ។ ការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញានឹងពិចារណាដល់ចរិតគ្រោះថ្នាក់របស់អំពើនៃបទល្មើស និងព្យសនកម្មដែលអំពើនោះហុចផលឱ្យទៅដល់ជនរងគ្រោះ ហើយអំពើនោះក៏មិនបណ្តាលឱ្យសង្គមចលាចល ឬខូចខាតធ្ងន់ធ្ងរផងដែរ។ ក្នុងគោលបំណងសម្រេច តម្កល់រឿងទុកឥតចាត់ការ គឺដើម្បីឱ្យមានភាពល្អប្រសើរឡើងទៅដល់សង្គម។

#### ❖ ការចោទប្រកាន់មិនបានផ្តល់ផលប្រយោជន៍

ការចោទប្រកាន់មិនបានផ្តល់ផលប្រយោជន៍ គឺជនល្មើសមានការដឹងខុសត្រូវពីការប្រព្រឹត្តរបស់ខ្លួន ហើយបានធ្វើការសងការខូចខាតចំពោះទង្វើរបស់ខ្លួន។ ហេតុនេះ ប្រសិនបើជនរងគ្រោះមានការអាក់អន់ស្រពន់ចិត្តបន្តចង់ប្តឹងទៅដល់ជនបង្កហេតុ នោះតំណាងអយ្យការពុំធ្វើការចោទប្រកាន់បានទេ ពីព្រោះការចោទប្រកាន់នេះគ្មានហុចផលទៅដល់អ្នកដែលប្រព្រឹត្តបទល្មើស ហើយមានការដឹងខុសត្រូវនូវកំហុសរបស់ខ្លួន ដូចនេះគឺគ្មានប្រយោជន៍ចំពោះជនដឹងខុសត្រូវឡើយ។

មូលហេតុដែលនាំឱ្យការចោទប្រកាន់ដោយមិនទទួលបានផលប្រយោជន៍ គឺអាចបណ្តាលមកពីកត្តាផ្សេងៗមានដូចជា៖ កត្តាចំណាត់ការ កត្តាចារី កត្តាជនរងគ្រោះ និងកត្តាព្យសនកម្ម ជាអាទិ៍។

[83] សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយសហប្រតិបត្តិការបារាំងគំរោងទ្រទ្រង់នីតិរដ្ឋ, ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៦, ទំព័រទី ៣៣

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ ,កថាខណ្ឌទី២

- **កត្តាចំណាត់ការ៖** ក្នុងស្ថានភាពខ្លះការចោទប្រកាន់ហាក់មិនបានផល ដោយសារការស៊ើបអង្កេតមិនបានផល អូសបន្លាយពេលវេលាយូរ ជាអាទិ៍។
- **កត្តាចារី៖** ចារីបានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពមួយចាំបាច់ ចារីមានអាកប្បកិរិយាទទួលស្គាល់ពីកំហុស និងបញ្ជាក់បន្ទុកគ្រួសារ។ល។
- **កត្តាជនរងគ្រោះ៖** ការបោះបង់ពាក្យបណ្តឹង ការមិនអើពើនឹងអំពើល្មើស នៃការខកខានក្នុងដំណើរការនីតិវិធី។ល។
- **កត្តាព្យសនកម្ម៖** ព្យសនកម្មមានលក្ខណៈតិចតួច ព្យសនកម្មដែលកើតចេញពីអំពើដែលបានប៉ះប៉ូវ។

ក្រៅពីកត្តាខាងលើ នៅមានមូលហេតុជាក់ស្តែងជាច្រើនទៀត ដែលធ្វើឱ្យការចោទប្រកាន់ដោយមិនបានផ្តល់នូវផលប្រយោជន៍ ដែលនាំឱ្យព្រះរាជអាជ្ញាថ្លឹងថ្លែងលើការសម្រេចតម្កល់រឿងទុកឥតចាត់ការ។

*ឧទាហរណ៍៖* លោក ក បានបើកម៉ូតូកៀរកង់ លោក ខ ដែលកំពុងតែជិះលើដងផ្លូវ បណ្តាលឱ្យមានរបួសបន្តិចបន្តួច។ បន្ទាប់មកទៀត លោក ក បាននាំជនរងគ្រោះទៅមន្ទីរពេទ្យ ហើយបានចេញថ្លៃព្យាបាលទាំងអស់ និងបានជូនជនរងគ្រោះ ទៅដល់ផ្ទះរបស់ខ្លួនដោយសុវត្ថិភាពផងដែរ។ ដូច្នេះតំណាងអយ្យការអាចតម្កល់រឿងនេះទុកឥតចាត់ការបាន ដោយសារតែជនដែលបង្កហេតុ បានដឹងពីកំហុសរបស់ខ្លួន និងមានទំនួលខុសត្រូវទៅដល់ជនរងគ្រោះទៀតផង។

### ២.២.២.៣. អាជ្ញាធរដែលមានសមត្ថកិច្ចតម្កល់រឿងទុកឥតចាត់ការ

បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចែងថាអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិកាជំនុំជម្រះ។[85] ដោយហេតុថាមានបញ្ញត្តិបានបញ្ជាក់ខាងលើនេះ អាចទាញជារួមបានថា អាជ្ញាធរដែលមានសមត្ថកិច្ចតម្កល់រឿងទុកឥតចាត់ការរួមមាន៖

- ព្រះរាជអាជ្ញា និង
- ព្រះរាជអាជ្ញារង។

### ២.២.២.៤. នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

#### ក. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

- នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ គឺអាចធ្វើបែងចែកជា ៣ ដំណាក់កាល៖

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤ កថាខណ្ឌ ២

**១. ការស្រាវជ្រាវ៖** មុននឹងសម្រេចធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យស្រាវជ្រាវបន្ថែម។[86]

**២. ការសម្រេចតម្កល់រឿងទុកឥតចាត់ការ៖** បន្ទាប់បានស្រាវជ្រាវចេញសព្វគ្រប់ ហើយយល់ឃើញថាត្រូវតម្កល់រឿងទុកឥតចាត់ការតំណាងអយ្យការនឹងធ្វើការសម្រេចដោយចេញ ដីកាមួយដែលមានឈ្មោះថា ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

**៣. ការជូនដំណឹង៖** បន្ទាប់ពីចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវជូនដំណឹងទៅអ្នកដែលបានប្តឹង អំពីសេចក្តីសម្រេចនេះ ឱ្យបានឆាប់បំផុត យ៉ាងយូរ ២ ខែ គិតចាប់ពីថ្ងៃដែលពាក្យប្តឹងចុះក្នុងបញ្ជី។[87]

### ខ. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

នៅពេលដែលមានការតម្កល់រឿងទុកឥតចាត់ការ គឺពុំមានបង្កើតអានុភាពអាជ្ញាអស់ជំនុំទេ។[88] តាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលតុលាការបានសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយជននោះមិនអាចត្រូវបានចោទប្រកាន់បានទៀតទេ នៅចំពោះអំពើដដែលនោះ ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។ ដូចនេះ ការតម្កល់រឿងទុកឥតចាត់ការ គឺពុំបង្កើតអាជ្ញាជំនុំនោះទេ មានន័យថាតំណាងអយ្យការ អាចធ្វើការចោទប្រកាន់ឡើងវិញនៅពេលក្រោយបាន ទោះបីបានធ្វើការតម្កល់រឿងទុកឥតចាត់ការរួចហើយក៏ដោយ។

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១១២

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ កថាខណ្ឌ ១

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១ កថាខណ្ឌ ២ និង ៣

# ជំពូកទី៣
# អយ្យការក្នុងកិច្ចដំណើរការស៊ើបអង្កេត ស៊ើបសួរ
# និងជំនុំជម្រះ

# ជំពូកទី៣
# អយ្យការក្នុងកិច្ចដំណើរការស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ

## ៣.១. ការដឹកនាំការស៊ើបអង្កេតរបស់ស្ថាប័នអយ្យការ

ការស៊ើបអង្កេតគឺជា ដំណាក់កាលមួយបន្ទាប់ពីបទល្មើសមួយបានកើតឡើង ក្នុងគោលបំណងដើម្បីស្វែងរកនូវភស្តុតាងពាក់ព័ន្ធផ្សេងៗ ក្នុងការកំណត់ជនល្មើស ក៏ដូចជាស្វែងរកពីពិរុទ្ធភាព ប្រកបដោយចំណេះដឹងផ្នែកច្បាប់ វិជ្ជាជីវៈ និងជំនាញ។ ម៉្យាងវិញទៀត ការស៊ើបអង្កេត ក៏ជាមូលដ្ឋានដ៏ចម្បងសម្រាប់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងពិចារណាអំពីចំណាត់ការ ឬចំណាប់ផ្ដើមនៃបណ្ដឹងអាជ្ញារបស់ខ្លួនប្រឆាំងទៅបុគ្គលដែលប្រព្រឹត្តបទល្មើស។ ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ ប្រសិនបើកើតមានការបំពានលើការសម្ងាត់នៃបទល្មើសនឹងត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ប៉ុន្តែប្រសិនបើមានព័ត៌មានមិនពិតណាមួយពីបទល្មើស ព្រះរាជអាជ្ញា អាចធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈបាន[៨១]។

តួនាទីរបស់ព្រះរាជអាជ្ញា នៅដំណាក់កាលស៊ើបអង្កេត គឺចង្អុលបង្ហាញឱ្យនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតស្រាវជ្រាវ ការអនុញ្ញាតឱ្យធ្វើការឆែកឆេរ ការអនុញ្ញាតឱ្យធ្វើការឃាត់ខ្លួន ការដឹកនាំការឆែកឆេរ និងការឱ្យយោបល់នានា នៅពេលដែលនគរបាលយុត្តិធម៌សុំយោបល់ពីព្រះរាជអាជ្ញា។ កាស៊ើបអង្កេតមាន ការស៊ើបអង្កេតករណីជាក់ស្ដែង និងការស៊ើបអង្កេតបឋម ដែលអាស្រ័យទៅនឹងបទល្មើសដែលបានកើតឡើង និងត្រូវគោរពតាមដំណាក់កាល៤គឺ ដំណាក់កាលស្វែងរក រកឃើញ ស្រាវជ្រាវ និងដំណាក់កាលកសាងសំណុំរឿង។

### ៣.១.១ ការស៊ើបអង្កេតករណីជាក់ស្ដែង

ការស៊ើបអង្កេតជាក់ស្ដែងជា គឺធ្វើឡើងចំពោះបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្ដែងតែប៉ុណ្ណោះ។ អ្វីជាបទល្មើសជាក់ស្ដែង?

អនុលោមតាមមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា «បទល្មើសដែលចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែងគឺៈ

- បទល្មើសដែលកំពុងប្រព្រឹត្ត
- បទល្មើសដែលប្រព្រឹត្តរួចភ្លាម។

ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែងកាលណា នៅក្រោយពេលមានបទល្មើសរួចបន្តិចមកៈ

[៨១] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៨៣

– ជនដែលគេសង្ស័យ ត្រូវសាធារណជនស្រែកដេញប្រភាប់ចាប់ប្រកីងបុគ្គលដែលគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឱ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។[90]

នៅក្នុងករណីបទល្មើសជាក់ស្តែងនេះ ជនណាក៏ដោយក៏អាចធ្វើការចាប់ខ្លួនជនល្មើស ដើម្បីធ្វើការបញ្ជូនខ្លួនទៅមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត។ ចំពោះថេរវេលានៃការស៊ើបអង្កេតជាក់ស្តែងគឺមិនឱ្យលើសពីរយៈពេល ៧ថ្ងៃ នោះទេគិតចាប់ពីថ្ងៃដែលប្រព្រឹត្តបទល្មើស ប្រសិនបើការស៊ើបអង្កេតមិនបញ្ចប់ក្នុងរយៈពេលកំណត់នេះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ពីព្រះរាជអាជ្ញា[91]។

**៣.១.១.១. ការចុះទៅកន្លែងកើតហេតុ**

តួនាទីព្រះរាជអាជ្ញានៅក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងជាទូទៅគឺ ដឹកនាំការស៊ើបអង្កេត ដោយប្រគល់អំណាចដែលខ្លួនមានទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌នៅក្នុងប្រតិបត្តិការនេះ ប៉ុន្តែជាអញ្ញត្រកម្ម នៅក្នុងមាត្រា ៨៩ កថាខណ្ឌ ៣ បញ្ញត្តិថា «ប្រសិនបើយល់ថាមានប្រយោជន៍ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត»[92]។ ជាទូទៅ ព្រះរាជាអាជ្ញាចុះទៅកន្លែងកើតហេតុចំពោះតែករណីបទឧក្រិដ្ឋធ្ងន់ធ្ងរតែប៉ុណ្ណោះ ដើម្បីដឹកនាំកិច្ចនីតិវិធី ក៏ដូចជាជួយសម្របសម្រួលដល់ មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។

**៣.១.១.២. ការឆែកឆេរ**

ការឆែកឆេរគឺជា សិទ្ធិក្នុងការស្រាវជ្រាវអំពីធាតុនៃវត្ថុតាងអំពីការប្រព្រឹត្តបទល្មើសណាមួយ។ ម្យ៉ាងវិញទៀត ការឆែកឆេរក៏ជាមូលដ្ឋានក្នុងការប្រមូលភស្តុតាងដែលអាចជាវត្ថុ ឬឯកសារដោយមានការធ្វើជាបញ្ជីសារពើភ័ណ្ឌ និងបិទស្លាកបោះត្រាលើវត្ថុតាង។[93] ការឆែកឆេរក្នុងករណីបទល្មើសជាក់ស្តែង មានលក្ខណៈបង្ខិតបង្ខំខ្លាំង ដោយអាចធ្វើទៅបានដោយមិនចាំបាច់មានការព្រមព្រាង ពីបុគ្គលដែលកាន់កាប់ទីកន្លែងនោះទេ។ យោងតាមមាត្រា ៩១នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយត្រូវទទួលបានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា បើទោះបីជាតាមរយៈការអនុញ្ញាតដោយផ្ទាល់មាត់ក្តី។ ការឆែកឆេរត្រូវធ្វើឡើងនៅមុខម្ចាស់ទីតាំង ឬសាក្សីពីររូបដែលមិនមែនជានគរបាល ឬកងកម្លាំងប្រដាប់អាវុធដែលចូលរួម

[90] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៨៦
[91] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១០៦
[92] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៨៩ កថាខណ្ឌ ៣
[93] អត្ថបទសំខាន់ៗទាក់ទងនឹងផ្នែកព្រហ្មទណ្ឌ, ចក សម្បត្តិ, ទំព័រ

ប្រតិបត្តិការស៊ើបអង្កេតនោះបើកន្លែងដែលត្រូវធ្វើការឆែកឆេរនោះពុំមានម្ចាស់។[94] ជាទូទៅការឆែកឆេរត្រូវធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែករណីការឆែកឆេរធ្វើឡើងនៅការិយាល័យមេធាវី មន្ត្រីនគរបាលយុត្តិធម៌ពុំអាចធ្វើបានឡើយ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះដែលអាចធ្វើបាន។ ចំពោះអគារសារព័ត៌មាន មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ប៉ុន្តែត្រូវធ្វើឡើងនៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដើម្បីធានាការពារកុំឱ្យការឆែកឆេរនេះប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់មុខរបរសារព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ(មាត្រា ៩១ កថាខណ្ឌទី៤ និងទី៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ជាទូទៅពេលវេលានៃការឆែកឆេរក្នុងករណីបទល្មើសជាក់ស្តែងគឺអាចធ្វើឡើងក្រៅពីម៉ោង ០៦ព្រឹក ដល់ ១៨បាន ក៏មានករណីផ្សេងទៀតដូចជា ករណីមានសម្រែកឱ្យគេជួយពីក្នុងទីកន្លែង ករណីឆែកឆេរនៅកន្លែងដែលម៉ោងបើកចំហរដល់សាធារណជន និងករណីឆែកឆេរនៅគ្រប់កន្លែងផលិត រក្សាទុក ចែកចាយ ជួញដូរ និងប្រើប្រាស់គ្រឿងញៀន ។

ចំពោះវត្ថុតាងដែលប្រមូលបានបន្ទាប់ពីការឆែកឆេរ គឺត្រូវបិទស្លាកបោះត្រា ដោយមន្ត្រីនគរបាលយុត្តិធម៌ ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានទៅកាន់ម្ចាស់កាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់មើល រួមទាំងហត្ថលេខាផងដែរ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាមានសមត្ថកិច្ចក្នុងការប្រគល់វត្ថុនោះទៅម្ចាស់កាន់កាប់ទីកន្លែងវិញ ប្រសិនបើវាមិនមានផលប្រយោជន៍ក្នុងការសម្តែងការពិត ឬវត្ថុនោះមិនអាចបង្ករគ្រោះថ្នាក់ដល់មនុស្ស ឬទ្រព្យសម្បត្តិទេនោះ[95]។

### ៣.១.១.៣. ការស្តាប់ចម្លើយ

ការស្តាប់ចម្លើយគឺ ជាដំណាក់កាលមួយក្នុងការឈានទៅដល់នូវ ការទទួលបានព័ត៌មានពាក់ព័ន្ធផ្សេងៗនឹងរឿងក្តី ពីបុគ្គលពាក់ព័ន្ធដែលអាចជា ជនរងគ្រោះ ឬក៏ជាសាក្សីជាដើម។ ការស្តាប់ចម្លើយនេះនឹងអាចផ្តល់ជាតម្រុយ ឬពត៌មានសំខាន់ៗ ក្នុងការកំណត់នូវជនសង្ស័យដែលបានចូលរួមប្រព្រឹត្តបទល្មើស។ បុគ្គលទាំងឡាយណា ដែលមានប្រយោជន៍ក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងបទល្មើសនឹងត្រូវកោះហៅមកផ្តល់ចម្លើយដោយមន្ត្រីនគរបាលយុត្តិធម៌ ប្រសិនបើមានការរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីចេញបញ្ជាឱ្យចូលខ្លួន ដោយអាចមានការប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ។ ការបញ្ជាឱ្យចូលខ្លួននេះត្រូវមានអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងហត្ថលេខាព្រះរាជអាជ្ញា ព្រមទាំងមានបោះត្រាផង (មាត្រា ៩៤ កថាខណ្ឌទី២នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៩១

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១១៩, កថាខណ្ឌទី១ និងទី២

### ៣.១.១.៤. ការឃាត់ខ្លួន និងការបញ្ជូនខ្លួន

សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨ កថាខណ្ឌទី ៣ បញ្ញត្តិថា ការចោទប្រកាន់ ការចាប់ខ្លួន ឬការចាប់ខ្លួនជនណាមួយនឹងអាចធ្វើទៅបាន លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។[96] ម្យ៉ាងវិញទៀត រដ្ឋធម្មនុញ្ញកម្ពុជាក៏បានទទួលស្គាល់នូវសន្ធិសញ្ញាអន្តរជាតិមួយចំនួនទាក់ទងនឹងសិទ្ធិមនុស្សមាន សេចក្តីថ្លែងការណ៍ជាសាកលស្តីពី សិទ្ធិមនុស្ស មាត្រា ៩ ចែងថា គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន តាមអំពើចិត្តឡើយ។[97] ចំណែកឯ កតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ចែងថា «ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មាននរណាម្នាក់ ត្រូវដកហូតសិទ្ធិសេរីភាពឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់»។[98]

ការឃាត់ខ្លួនជាវិធានការបង្ខំ ដែលអាចប៉ះពាល់នូវសិទ្ធសេរីភាពមួយចំនួន ក្នុងការឃាត់ខ្លួនជនសង្ស័យដែលចូលរួមក្នុងការប្រព្រឹត្តបទល្មើសដោយមន្ត្រីនគរបាលយុត្តិធម៌ ឬក៏បុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុប៉ុន្តែប្រកែកមិនព្រមផ្តល់ព័ត៌មាន ក្រោមការយល់ព្រមពីព្រះរាជអាជ្ញាជាលាយលក្ខណ៍អក្សរ។ ព្រះរាជអាជ្ញាមានអំណាចត្រួតពិនិត្យលើការឃាត់ខ្លួន ដឹកនាំសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌ ការស្នើឱ្យមានការឃាត់ខ្លួន ហើយនៅពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍តាមគ្រប់មធ្យោបាយទាំងអស់ជូនព្រះរាជអាជ្ញា។[99] ទាក់ទងទៅនឹងបុគ្គលដែលឃាត់ខ្លួន នៅពេលផុតរយៈពេលឃាត់ខ្លួន ជននោះអាចត្រូវបានបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬដោះលែងឱ្យមានសេរីភាព តាមរយៈសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា។[100] ក្នុងការបញ្ជូនខ្លួនទាក់ទងនឹងករណីជាក់ស្តែង ត្រូវធ្វើឡើងជាមួយនឹងការបញ្ជូនកំណត់ហេតុ និងវត្ថុតាងទៅព្រះរាជអាជ្ញា ក្រោយបញ្ចប់ការស៊ើបអង្កេត។

### ៣.១.២. ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋមគឺជា នីតិវិធីក្នុងការស្វែងរកភស្តុតាង ដើម្បីដោះបន្ទុក ឬដាក់បន្ទុក ដោយពុំមានការកំណត់រយៈពេលជាក់លាក់ដូចការស៊ើបអង្កេតជាក់ស្តែងនោះទេ។ ការបើកការស៊ើបអង្កេតបឋម ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយឯកឯងបាន ឬតាមការស្នើសុំ

---

[96] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា ៣

[97] សេចក្តីថ្លែងការណ៍ជាសាកលស្តីពី សិទ្ធិមនុស្ស១៩៤៨

[98] កតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ១៩៧៦

[99] ចក សម្បត្តិ, អត្ថន័យសាកល្បងពន្យល់ស្តីពី ការឃាត់ខ្លួន, ទំព័រ ៥

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១០៣

របស់ព្រះរាជអាជ្ញា។[101] នីតិវិធីនៃការស៊ើបអង្កេតបឋម ត្រូវយកមកអនុវត្តដូចគ្នាចំពោះចំណុចមួយចំនួននៅក្នុងការស៊ើបអង្កេតករណីជាក់ស្តែងមានដូចជា កំណត់ហេតុលើការស្រាវជ្រាវ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា ការឃាត់ខ្លួន...។

#### ៣.១.២.១. ការឆែកឆេរ

បើទោះបីជាអំណាចនៃការស៊ើបអង្កេតបឋម មិនមានលក្ខណៈធំធេងដូចការស៊ើបអង្កេតករណីជាក់ស្តែងក៏ដោយ ក៏ការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌នៅតែអាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង[102] បានប៉ុន្តែត្រូវមានការអនុញ្ញាតពីអ្នកកាន់កាប់ទីកន្លែង។ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងមិនយល់ព្រមឱ្យធ្វើការឆែកឆេរ ឬអវត្តមាន តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ប្រធានតុលាការអាចធ្វើឱ្យមានការឆែកឆេរបាន ហើយការឆែកឆេរត្រូវធ្វើឡើងក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញា នៅមុខអ្នកកាន់កាប់ទីកន្លែង ឬមុខសាក្សីពីររូប ដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងប្រតិបត្តិការនៃការឆែកឆេរនោះ។ ចំពោះម៉ោងនីត្យានុកូលនៃការឆែកឆេរក្នុងករណីនៃការស៊ើបអង្កេតបឋមនេះ មិនអាចប្រព្រឹត្តមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចឡើយ។

#### ៣.១.២.២. ការបញ្ជាឱ្យចូលខ្លួន

មន្ត្រីនគរបាលយុត្តិធម៌ អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ។[103] ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងទៅព្រះរាជអាជ្ញាក្នុងការបញ្ជាឱ្យចូលខ្លួន ឬការប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំ ដោយធ្វើការចុះអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាលើវត្ថុតាងផងដែរ អនុលោមតាមមាត្រា ៩៦។

### ៣.២. ការចូលរួមរបស់អយ្យការក្នុងដំណើរការកិច្ចស៊ើបសួរ

ការស៊ើបសួរគឺជា ដំណាក់កាលដែលត្រូវបានធ្វើឡើងដោយតុលាការ ក្នុងការស៊ើបសួរបុគ្គលណាម្នាក់ដែលត្រូវបានដឹកនាំនីតិវិធីដោយចៅក្រមស៊ើបសួរ ដោយផ្អែកលើដីការបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។[104] ក្នុងន័យនេះ ព្រះរាជអាជ្ញា គឺជាអ្នកបើកការស៊ើបសួរ ករណីបទឧក្រិដ្ឋ តាមរយៈដីការបញ្ជូនរឿងឱ្យ

---

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១១១

[102] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១១៣

[103] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១១៤

[104] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៤

ស៊ើបសួរដែលផ្តល់ជូនចៅក្រមស៊ើបសួរ និងនឹងអាចត្រូវបានបើកប្រឆាំងនឹងបុគ្គលណាម្នាក់ ឬច្រើននាក់ដោយចង្អុលប្រាប់អត្តសញ្ញាណ ឬប្រឆាំងអញ្ញាតជន[105]។ ការស៊ើបសួរនេះត្រូវបានធ្វើឡើងក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ និងស្មុគស្មាញ ដូចជាករណីបទឧក្រិដ្ឋ ដែលត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌបានតម្រូវឱ្យមានការស៊ើបសួរជាចាំបាច់ រីឯបទមជ្ឈិម ឬលហុ មិនតម្រូវនោះទេ។ គោលការណ៍នៃការរក្សាការសម្ងាត់វិជ្ជាជីវៈ ក៏ត្រូវបានយកមកអនុវត្តនៅក្នុងនីតិវិធីនៃការស៊ើបសួរនេះដែរ ដោយបុគ្គលទាំងឡាយដែលបានចូលរួមក្នុងកិច្ចដំណើរការកិច្ចនីតិវិធីត្រូវតែរក្សាការសង្ងាត់ បើពុំនោះទេនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។[106]

### ៣.២.១. នីតិវិធីបើកការស៊ើបសួរ

ការបើកកការស៊ើបសួរអាចត្រូវបានបើកតាមពីររបៀបគឺ តាមរយៈដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

#### ៣.២.១.១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជា ដីកាចង្អុលបង្ហាញបុគ្គលដែលត្រូវបើកការស៊ើបសួរករណីបទឧក្រិដ្ឋ ឬមជ្ឈិម ធ្វើឡើងដោយព្រះរាជអាជ្ញាដើម្បីដាក់ជូនចៅក្រមស៊ើបសួរ ដោយមានសរសេរពីះ

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើកំណត់បាន( ក្នុងករណីមិនអាចកំណត់បានអាចបើកការស៊ើបសួរប្រឆាំងនឹងអញ្ញាតជន ពោលគឺជនមិនស្គាល់)[107]

ដោយមានការចុះកាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។[108]

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញានោះទេ។[109] បុគ្គលណាដែលត្រូវបានចង្អុលបង្ហាញនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ នឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ចៅក្រមស៊ើបសួរ រីឯបុគ្គលដែលពុំត្រូវបានចង្អុលបង្ហាញក្នុងដីកាបញ្ជូនខ្លួនឱ្យ

---

[105] សៀវភៅមគ្គុទេសក៍ស្តីពី នីតិវិធីព្រហ្មទណ្ឌនៅតុលាការកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, សីហា ២០១៣, ទំព័រទី១១, https://cchrcambodia.org/admin/media/report/report/khmer/2013_08_26_tmp_Procedure_Handbook_August_2013_khm.pdf

[106] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២១

[107] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, លោករុន ពណ្ណារិទ្ធ និងអ្នកស្រី ចាំងស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ, ទំព័រទី២៨

[108] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៤

[109] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៤, កថាខណ្ឌទី៣

ស៊ើបសួរក៏ដោយ ប្រសិនបើមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ក៏ត្រូវស្ថិតក្រោមការត្រួតពិនិត្យដែរ ដែលស្ថិតក្រោមឋានៈជាចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត[110]។ ម្យ៉ាងវិញទៀត នៅក្នុងដំណាក់កាលនៃការស៊ើបសួរនេះ ចៅក្រមស៊ើបសួរត្រូវតែស៊ើបសួរតែអង្គហេតុប៉ណ្ណោះ ករណីមានអង្គហេតុថ្មីលេចឡើង ចៅក្រមស៊ើបសួរអាចស៊ើបសួរបន្ថែមបាន តាមរយៈដីការសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិនបើអង្គហេតុថ្មីនេះគ្រាន់តែជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង នោះចៅក្រមស៊ើបសួរមិនចាំបាច់ស្នើសុំដីការឱ្យស៊ើបសួរបន្ថែមនោះទេ។[111]

**៣.២.១.២. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺ ជាវិធានមួយក្នុងការអនុញ្ញាតឱ្យជនរងគ្រោះក្នុងការទាមទារសំណងរដ្ឋប្បវេណី ដោយហេតុថា ជនរងគ្រោះជាបុគ្គលដែលទទួលរងព្យសនកម្មដោយផ្ទាល់ពីបទល្មើស មានព្យសនកម្មសម្ភារៈ រូបកាយ ឬផ្លូវចិត្តជាដើម។ របៀបក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមាន៖

- **ការតាំងខ្លួនតាមផ្លូវបណ្តឹង៖** ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់បណ្តឹងឱ្យមានចលនាតាមរយៈការប្តឹងមកចៅក្រមស៊ើបសួរក្នុងនាមជាជនរងគ្រោះដោយមេធាវី។ ចៅក្រមស៊ើបសួរដោយមានការកត់សម្គាល់នូវការដាក់ពាក្យប្តឹងនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា ហើយចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ប្រឆាំងនឹងអញ្ញាតជន ឬបុគ្គលច្រើននាក់។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងន័យនេះ ការបញ្ជូនរឿងឱ្យស៊ើបសួរ មិនមែនជាកាតព្វកិច្ចឱ្យចៅក្រមស៊ើបសួរត្រូវតែសម្រេចតាមការស្នើសុំរបស់ព្រះរាជអាជ្ញានោះទេ ក្នុងករណីចៅក្រមស៊ើបសួរសម្រេចក្នុងការស៊ើបសួរ ត្រូវចេញដីកាមានសំអាងហេតុ និងត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាជាបន្ទាន់។[112]
- **ការតាំងខ្លួនតាមផ្លូវអន្តរាគមន៍៖** បន្ទាប់ពីការស៊ើបសួរបានបើក ជនណាដែលបានប្រកាសខ្លួនជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា ហើយ

[110] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៦

[111] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១២៥

[112] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៩

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[113]

### ៣.២.២. ការចូលរួមក្នុងវិធានការណ៍និរន្តរាយ

វិធានការណ៍នេះ ត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌនៃការស៊ើបសួរ ធ្វើយ៉ាងណាដើម្បីធានាការស៊ើបសួរឱ្យបានល្អ និងប្រកបដោយប្រសិទ្ធភាព។ នៅក្នុងការបំពេញភារកិច្ចរបស់ចៅក្រមស៊ើបសួរ គឺដើម្បីស្វែងរកការពិត ច្បាប់បានប្រគល់អំណាចមួយចំនួនដែលមានលក្ខណៈបង្ខំ ដូច្នេះចំពោះបុគ្គលដែលមិនធ្វើការឆ្លើយតបនឹងដីកាកោះហៅធម្មតារបស់ចៅក្រមស៊ើបសួរ ដែលដីកាទាំងនោះរួមមាន ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន។[114] ប៉ុន្តែ ទាក់ទងនឹងដីកាមួយចំនួនទាមទារឱ្យមានការចូលរួមពីព្រះរាជអាជ្ញក្នុងដំណើរការនីតិវិធី ដូចជាការត្រួតពិនិត្យ ឬផ្តល់ជាយោបល់ជាដើម។

#### ៣.២.២.១. ការបង្គាប់ឱ្យចាប់ខ្លួន

ការបង្គាប់ឱ្យចាប់ខ្លួនគឺជា ការបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួន ជនជាប់ចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព ក៏ដូចជាការបញ្ជាដល់ប្រធានពន្ធនាគារដើម្បីនាំខ្លួនបុគ្គលនោះទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន តាមរយៈដីកាបង្គាប់ឱ្យចាប់ខ្លួន ដែលជាទូទៅត្រូវបានចេញដោយចៅក្រមស៊ើបសួរ[115]។ ម្យ៉ាងវិញទៀត ដីកាបង្គាប់ឱ្យចាប់ខ្លួនធ្វើឡើងក្នុងករណីៈ

- បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម
- បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីណា ឬនៅក្រៅដែនដីកម្ពុជា។[116]

មានន័យថា ការអនុវត្តដីកានេះគឺបន្ទាប់ពីមានរបាយការណ៍ថា ដីកាបង្គាប់ឱ្យនាំខ្លួនមិនបានជោគជ័យ ហើយនឹងបានដឹងថា បុគ្គលដែលត្រូវនាំខ្លួននោះ ត្រូវបានរត់គេចខ្លួន ឬអាចនឹងគេចខ្លួន។

ជាគោលការណ៍ មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងទៅព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញា ត្រួតពិនិត្យ និងផ្តល់ជាយោបល់ ហើយព្រះរាជអាជ្ញាជាអ្នកធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។[117] បើទោះបីជាដីកានេះត្រូវបានត្រួតពិនិត្យ និងផ្តល់ជាយោបល់ដោយព្រះរាជអាជ្ញាក៏ដោយ ក៏ចៅក្រមស៊ើបសួរមិនមានកាតព្វកិច្ចត្រូវតែទទួលយកយោបល់នោះទេ ចៅក្រមស៊ើបសួរនៅតែចេញដីកានោះ

---

[113] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ១៣៧

[114] ស៊ាង សំភាស់, វិធានការនិរន្តរាយ, https://drive.google.com/file/d/1GCnLgQTAGLxzMlf_foQZYVzf-1n9JfeW/view

[115] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩៥

[116] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩៦ កថាខណ្ឌទី២

[117] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា១៩៧

បាន បើទោះបីជាមានការជំទាស់ពីព្រះរាជអាជ្ញាក៏ដោយ។ មានន័យថា យោបល់ទាំងនោះមានតម្លៃត្រឹមតែជាមូលវិចារណ៍ សម្រាប់ចៅក្រមស៊ើបសួរក្នុងការពិចារណាតាមផ្លូវច្បាប់តែប៉ុណ្ណោះ ពោលគឺវាជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ តាមការយល់ឃើញរបស់ខ្លួន។[118]

ប្រសិនបើបុគ្គលដែលត្រូវបានចាប់ខ្លួន តាមដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ មិនបានបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួស នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន បុគ្គលនោះនឹងត្រូវបានព្រះរាជអាជ្ញានាំទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ និងធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ ដែលត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។[119]

**៣.២.២.២. ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្ន ជានីតិវិធីមួយដែលត្រូវបានធ្វើឡើងដើម្បីធានានូវសណ្តាប់ធ្នាប់សាធារណៈ ឬបង្កាកុំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរជាងមុន បើទោះបីជាមានការប៉ះពាល់នូវសិទ្ធិបុគ្គលក៏ដោយ ផ្អែកតាមមាត្រា ២០៣ នៃក្រមនីតិវិធី «ជាគោលការណ៍ជនជាប់ចោទត្រូវតែមានសេរីភាព»[120]។ ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពី បទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់បានផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ ដោយភ្ជាប់ជាមួយនឹងមូលហេតុមួយចំនួនដែលច្បាប់បានកំណត់៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតមានជាថ្មី
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនជាប់ចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាទុកភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស[121]។

[118] ប្រធានសាលាឧទ្ធរណ៍ សេង ស៊ីវុត្ថា, នីតិវិធីព្រហ្មទណ្ឌខ្មែរ, សម្រាប់ថ្នាក់ឧត្តមសិក្សា, ទំព័រទី៨៥

[119] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២០១ កថាខណ្ឌទី៣ និងទី៤

[120] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២០៣

[121] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២០៥

**ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន(មាត្រា២០៨-២០៩៖ នីតិជន)**

| នីតិជន | រយៈពេល | ការពន្យាពេល |
|---|---|---|
| បទឧក្រិដ្ឋ | មិនលើស៦ខែ | ៦ខែ ចំនួន ២ដង |
| បទមជ្ឈិម | មិនលើស៤ខែ | ២ខែ ចំនួន ១ដង |
| | មិនលើសពីពាក់កណ្ដាលនៃអប្បបរមាដែលច្បាប់កំណត់ | |
| ឧក្រិដ្ឋកម្មអន្តរជាតិ | ១ឆ្នាំ | ១ឆ្នាំ ចំនួន ២ដង |

**ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន(មាត្រា២១៣-២១៤៖ អនីតិជន)**

| អនីតិជន | អាយុ | រយៈពេល | ការពន្យាពេល |
|---|---|---|---|
| បទឧក្រិដ្ឋ | ១៤≤X<១៦ | ៤ខែ | មិនអាច |
| | ១៦≤X<១៨ | ៦ខែ | |
| បទមជ្ឈិម | ១៤≤X<១៦ | ២ខែ | មិនអាច |
| | ១៦≤X<១៨ | ៤ខែ | |
| | ថេរវេលាមិនត្រូវលើសពី ១/២អប្បបរមានៃទោសដែលច្បាប់អនីតិជន | | |

ការសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន គឺត្រូវធ្វើឡើងតាមគំនិតផ្ដួចផ្ដើមរបស់ចៅក្រមស៊ើបសួរ ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលត្រូវជូនដំណឹងដល់ជនត្រូវចោទ។ បើកាលណាចៅក្រមស៊ើបសួរបានចេញដីកាមានសំអាងហេតុ ក្នុងការឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងដល់ជនជាប់ចោទ[122]។ តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលសុំឱ្យឃុំខ្លួនជនជាប់ចោទ ចៅក្រមស៊ើបសួរក៏អាចបដិសេធមិនព្រមឃុំខ្លួនបានដែរ ដែលត្រូវធ្វើឡើងក្នុងរយៈពេល ៥ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ដោយមិនចាំបាច់មានសំអាងហេតុទេ។ ករណីចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥ថ្ងៃ នោះព្រះរាជអាជ្ញាអាចធ្វើពាក្យបណ្ដឹងប្ដឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ។[123]

ចៅក្រមស៊ើបសួរអាចធ្វើការដោះលែងជនជាប់ចោទបាន ប្រសិនបើមិនមានការប៉ះពាល់ដល់នីតិវិធីនៃការស៊ើបសួរ។ ម្យ៉ាងវិញទៀត ការដោះលែងឱ្យនៅក្រៅឃុំនេះមិនមែនជាការដោះលែងជាស្ថាពរនោះទេ គឺវាគ្រាន់តែ

[122] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២០៦

[123] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២០៧

ជាការដោះលែងបណ្តោះអាសន្ន ដែលជនជាប់ចោទនៅតែមានកាតព្វកិច្ចក្នុងការបង្ហាញខ្លួននៅចំពោះមុខតុលាការតាមការកោះហៅ។ ការដោះលែងឱ្យនៅក្រៅឃុំអាចត្រូវបានធ្វើឡើងតាម៣យ៉ាង៖

- **ការបង្គាប់ដោយចៅក្រមស៊ើបសួរ៖** អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាត្រួតពិនិត្យយ៉ាងយូរក្នុងរយៈពេល ៥ថ្ងៃ។[124]
- **តាមរយៈបណ្តឹងរបស់ព្រះរាជអាជ្ញា៖** អាចសុំឱ្យដោះលែងជនជាប់ចោទនៅគ្រប់ពេលវេលា ហើយចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល៥ថ្ងៃ បើពុំនោះទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈសភាស៊ើបសួរ រីឯដីកាសម្រេចមិនព្រមដោះលែងត្រូវមានសម្អាងហេតុ។[125]
- **តាមរយៈបណ្តឹងរបស់ជនត្រូវចោទ៖** អាចដាក់ពាក្យសុំដោះលែងឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ទៅចៅក្រមស៊ើបសួរ រួចបញ្ជូនបន្តទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងត្រួតពិនិត្យ ហើយចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល៥ថ្ងៃ បន្ទាប់ពីបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជនជាប់ចោទអាចដាក់ពាក្យសុំម្តងទៀត បន្ទាប់ពីរយៈពេល១ខែនៃការបដិសេធការដោះលែងឱ្យនៅក្រៅឃុំទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ។[126]

រាល់ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ និងដីកាមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែជូនដំណឹងទៅព្រះរាជអាជ្ញា ប៉ុន្តែទាក់ទងនឹងការមិនព្រមដោះលែង ជនត្រូវចោទ ឬព្រះរាជអាជ្ញាអាចដាក់ពាក្យបណ្តឹងទៅសភាស៊ើបសួរ ក្នុងការប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។

#### ៣.២.២.៣. ការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើព្យសនកម្មដែលកើតពីអំពើល្មើសនោះមានលក្ខណៈតិចតួច ហើយមានមូលហេតុស្របច្បាប់ដែលមិនធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃការស៊ើបសួរទេនោះ តុលាការអាចដាក់ជននោះស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការនៅគ្រប់ពេលវេលាទាំងអស់។ ការត្រួតពិនិត្យតាមផ្លូវតុលាការជាផ្នែកមួយនៃវិធានការនិរន្តរាយដែលត្រូវបានធ្វើឡើងដើម្បីធានា និងសម្រួលដល់ដំណើរការនៃកិច្ចស៊ើបសួរ មានន័យថាក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទអាចត្រូវបាននៅក្រៅឃុំ( ការត្រួតពិនិត្យតាមផ្លូវតុលាការ) តាមការយល់ឃើញរបស់តុលាការ កាលណាយល់ថាអំពើនោះមិនប៉ះពាល់ដល់នីតិវិធីរបស់ខ្លួន។

---

[124] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២១៥

[125] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២១៦

[126] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២១៧

ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ឱ្យជនត្រូវចោទដែលនៅក្រៅឃុំគោរពនូវកាតព្វកិច្ចមួយ ឬច្រើនដូចជាៈ

- ❖ មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ
- ❖ មិនត្រូវផ្លាស់ប្តូរទីលំនៅដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ
- ❖ មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ
- ❖ ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ❖ ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ❖ ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ
- ❖ មិនត្រូវបើកបររថយន្ត
- ❖ មិនត្រូវទទួល ឬជួបបុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ❖ ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នោះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ
- ❖ មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ ត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់
- ❖ ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ
- ❖ មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។[127]

ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ តាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមរយៈសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា តាមរយៈដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយមានភ្ជាប់នូវកាតព្វកិច្ចទៅលើជនត្រូវចោទ។ កាលបើដីកាបង្គាប់ឱ្យដាក់ស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការរបស់ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងជនត្រូវចោទក្នុងរយៈពេលយ៉ាងខ្លី ហើយបើកាលណាចៅក្រមស៊ើបសួរ បានទទួលសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឱ្យដាក់ស្ថិតក្រោមការត្រួត

[127] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២២៣

ពិនិត្យតាមផ្លូវតុលាការ ហើយខ្លួនបដិសេធនឹងសេចក្ដីសន្និដ្ឋាននេះ ចៅក្រមស៊ើបសួរត្រូវធ្វើដីកាបដិសេធក្នុងរយៈពេល៥ថ្ងៃ បើមិនសម្រេចទេ ព្រះរាជអាជ្ញាអាចដាក់ពាក្យបណ្ដឹងទៅសភាស៊ើបសួរដើម្បីសម្រេចជំនួស។[128]

ចំពោះការកែប្រែ ការលុបចោលកាតព្វកិច្ច ឬការបញ្ចូលកាតព្វកិច្ចថ្មី នៃការត្រួតពិនិត្យតាមផ្លូវតុលាការអាចធ្វើទៅបានតាមរយៈការកែប្រែដោយឯកឯងដោយចៅក្រមស៊ើបសួរ[129] តាមរយៈបណ្ដឹងសុំកែប្រែដោយព្រះរាជអាជ្ញា[130] និងតាមពាក្យសុំកែប្រែដោយជនត្រូវចោទ[131]។

### ៣.២.៣. ការបិទ និងមោឃភាពការស៊ើបសួរ

#### ៣.២.៣.១. ការបិទការស៊ើបសួរ

ការបិទការស៊ើបសួរ គឺត្រូវបានធ្វើឡើងនៅពេលណាដែលចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់ មានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការជម្រះ ដោយធ្វើការជូនដំណឹងទៅដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី ប៉ុន្តែព្រះរាជអាជ្ញា និងជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យមានការស៊ើបសួរថ្មីទៀត បើយល់ឃើញថាចាំបាច់។ យ៉ាងយូរក្នុងរយៈពេល២ថ្ងៃ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ហើយត្រូវបញ្ជូនត្រឡប់មកចៅក្រមស៊ើបសួរវិញនូវសំណុំរឿង ភ្ជាប់នឹងដីកាសន្និដ្ឋានស្ថាពរ ក្នុងរយៈពេល១៥ថ្ងៃ( ករណីជនត្រូវចោទជាប់ឃុំខ្លួន) និង៣០ថ្ងៃ(ករណីនៅក្រៅឃុំ)។ ទាក់ទងទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា អាចថា ព្រះរាជអាជ្ញាយល់ស្របដូចចៅក្រមស៊ើបសួរដែរក្នុងការបិទការស៊ើបសួរ ដោយមានលាយលក្ខណ៍ជាអក្សររួមនឹងសំអាងហេតុ ឬក៏ព្រះរាជអាជ្ញាមិនយល់ស្របក្នុងការបិទការស៊ើបសួរ ដោយសារមើលឃើញនៅមានភាពខ្វះចន្លោះណាមួយនៃកិច្ចស៊ើបសួរ នោះព្រះរាជអាជ្ញាអាចស្នើសុំឱ្យបំពេញកិច្ចនោះភ្លាម។ ជាចុងក្រោយ បន្ទាប់ពីមានសេចក្ដីសម្រេចបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាចបិទការស៊ើបសួរជាស្ថាពរ តាមរយៈ ការចេញនូវដីកាដំណោះស្រាយ។

ដីកាដំណោះស្រាយគឺជា ការបិទនូវការស៊ើបសួរ ព្រមទាំងដកហូតនូវសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរផងដែរ ដែលតាមរយៈដីកានេះ អាចជាដីកាបញ្ជូនទៅជំនុំជម្រះ( ទាំងមូល ឬមួយផ្នែក) ឬដីកាលើកលែងការចោទប្រកាន់(ទាំងមូល ឬមួយផ្នែក)។

[128] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២២៦

[129] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២២៧

[130] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២២៨

[131] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២២៩

- **ដីកាបញ្ជូនទៅជំនុំជម្រះ៖** ប្រសិនបើចៅក្រមយល់ឃើញថា អំពើនោះជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ នោះចៅក្រមនឹងចេញដីកាបញ្ជូនទៅជំនុំជម្រះ ដើម្បីនាំជនជាប់ចោទទៅមុខតុលាការជំនុំជម្រះ[132]
- **ដីកាលើកលែងការចោទប្រកាន់៖** កាលបើអំពើនោះ
  - អំពើមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ
  - ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
  - គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ
  - ករណីបណ្ដឹងអាជ្ញាររលត់[133]។

***សម្គាល់៖** ករណីអនីតិជន តម្រូវឱ្យចៅក្រមត្រូវតែចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ករណីនីតិវិធីបង្វែទទួលបានជោគជ័យ[134] និងត្រូវលើកលែងឱ្យរួចផុតពីការចោទប្រកាន់តែម្ដងករណីរកឃើញថា អនីតិជនមានអាយុក្រោម១៤ឆ្នាំ[135]។

ប្រសិនបើ ដីកា ឬសាលដីកាលើកលែងការចោទប្រកាន់បានចូលជាស្ថាពរ ហើយមានការលេចឡើងនូវបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញ តាមការផ្ដើមគំនិតរបស់ព្រះរាជអាជ្ញា[136]។ ដូច្នេះ ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ផ្អែកលើ៖

- **អង្គហេតុ៖** មានអានុភាពស្ថាពរបណ្ដោះអាសន្ន និងមិនដាច់ខាត ករណីមាត្រា ២៥២ និងមាត្រា ២៦៥ និង
- **អង្គច្បាប់៖** មានអានុភាពស្ថាពរអចិន្ត្រៃយ៍ និងដាច់ខាត។[137]

**៣.២.៣.២. មោឃភាពនៃកិច្ចស៊ើបសួរ**

មោឃភាពនៃកិច្ចស៊ើបសួរ នាំឱ្យមានការស៊ើបសួរថ្មី ហើយពាក្យប្ដឹងសុំមោឃកម្ម មិនអាចធ្វើឡើងក្រោយដីកាដំណោះស្រាយដែលចូលជាស្ថាពរឡើយ អនុទ្បោមតាមមាត្រា ២៥៦ គ្មានមោឃភាពណាមួយនៃ

---

[132] នីតិវិធីមុនការជំនុំជម្រះ និងការជំនុំជម្រះ, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ខែសីហា ២០១៣, https://cchrcambodia.org/admin/media/report/report/khmer/2013_08_26_tmp_Procedure_Handbook_August_2013_khm.pdf

[133] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៤៧ថ្មី

[134] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦, មាត្រា ៣៨ កថាខណ្ឌទី៣

[135] ច្បាប់ស្ដីពីកិច្ចការពារអនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦ មាត្រា ៣៩ កថាខណ្ឌទី២

[136] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៥១និងមាត្រា ២៦៥

[137] សមាគមសាលាត្រាជូ, ចក សម្បត្តិ, ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, ស្លាយទី១៣៥

នីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ[138]។ ម្យ៉ាងវិញទៀត ចំពោះមោឃកម្មនៃនីតិវិធី មានតែសភាស៊ើបសួរតែប៉ុណ្ណោះ ដែលមានសមត្ថកិច្ច ក្នុងការត្រួតពិនិត្យលិខិតនៃនីតិវិធីតាមរយៈបណ្តឹងពីចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញា ឬជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី បើខ្លួនយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព[139]។

មូលហេតុដែលនាំឱ្យមានមោឃភាពនៃនីតិវិធី កាលណាវិធាន និងទម្រង់នៃបទប្បញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរមានលក្ខណៈផ្ទុយពីអ្វីដែលច្បាប់បានបញ្ញត្តិមានមាត្រា ១២២(ការបើកការស៊ើបសួរ) មាត្រា ១២៣ (សមត្ថកិច្ច) មាត្រា ១២៤ កថាខណ្ឌទី ៣(ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) មាត្រា ១២៥ កថាខណ្ឌទី ១ និងទី២ (វិសាលភាពនៃការប្តឹង) និងមាត្រា ១២៨ (ជំនួយរបស់ក្រឡាបញ្ជី)។ ក៏នាំឱ្យមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យប៉ះពាល់ផលប្រយោជន៍របស់ភាគី ដែលទទួលរងការបំពាន។[140]

## ៣.៣. អយ្យការក្នុងដំណើរការជំនុំជម្រះ

ការជំនុំជម្រះ គឺជាដំណាក់កាលនៃការពិភាក្សាដេញដោលគ្នា ដែលជាទូទៅត្រូវបានធ្វើឡើងជាសាធារណៈឬជាការសង្ងាត់ប្រសិនបើតុលាការយល់ឃើញថាសាធារណភាពអាចបង្កឱ្យមានភាពវឹកវរចលាចល ដែលអាចប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់។[141]

### ៣.៣.១. មុនពេលជំនុំជម្រះ

ការជំនុំជម្រះអាចត្រូវបានធ្វើឡើងតាមរយៈ៖

- **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ៖** គឺបន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាក្នុងបទឧក្រិដ្ឋ ឬមជ្ឈិម ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរទៅដល់បុគ្គលដែលបានចង្អុលបង្ហាញនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ឬបុគ្គលផ្សេងទៀត ដែលអាចផ្តល់ជាចម្លើយក្នុងការស្វែងរកការពិតដែលអាចជា ជនរងគ្រោះ សាក្សីជាដើម។ ដូច្នេះ បន្ទាប់ពីការស៊ើបសួរត្រូវបានបិទ បុគ្គលដែលត្រូវបានចោទពីបទឧក្រិដ្ឋ ឬមជ្ឈិម នឹងត្រូវបានបញ្ជូនទៅជំនុំជម្រះបន្តដោយតុលាការ។
- **ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់៖** គឺជាការបញ្ជាឱ្យជនជាប់ចោទចូលបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ដោយព្រះរាជអាជ្ញា ក្នុងបទមជ្ឈិម ដែលមិនតម្រូវឱ្យមានការស៊ើបសួរទេ។ ដីកា

[138] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៥៦

[139] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៥៣

[140] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៥២

[141] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៣១៦

កោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវមាន អត្តសញ្ញាណជនជាប់ចោទ អង្គហេតុ ឈ្មោះបទល្មើស និង អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។[142]

- **នីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម៖** ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការ កាលណា បទល្មើសនោះជាបទល្មើសជាក់ស្ដែង ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ឆ្នាំ និងយ៉ាងច្រើន៥ឆ្នាំ ជនជាប់ចោទជានីតិជន និងរឿងក្ដីមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបាន។

ដូច្នេះ ជារួមការជំនុំជម្រះនឹងត្រូវបានបើកតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ឬសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរបញ្ជូនទៅជំនុំជម្រះ។ នៅក្នុងកិច្ចនៃដំណើរការនីតិវិធីមុនជំនុំជម្រះ ព្រះរាជអាជ្ញាមានតួនាទីក្នុងការធានាពីវត្តមាន និងសម្របសម្រួលការបង្ហាញខ្លួនរបស់ជនជាប់ចោទ ភាគីពាក់ព័ន្ធ( អាចជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អ្នកធានារ៉ាប់រង ឬអាជ្ញាធរផ្សេងៗជាដើម) មុនសវនាមកដល់ ដោយដីកាកោះហៅដោយធ្វើឡើងដោយព្រះរាជអាជ្ញា( កាលបរិច្ឆេទ និងហត្ថលេខា)។

***នីតិវិធីនៃការបង្ហាញខ្លួនភ្លាម៖** ករណីតុលាការបានទទួលបណ្ដឹងតាមរយៈកំណត់ហេតុស្ដីពីការបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន
- ឱ្យដំណឹងជននោះអំពីរឿងហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។[143]

*ទាក់ទងទៅនឹងបច្ចេកទេសរបស់តំណាងអយ្យការ គឺត្រូវត្រួតពិនិត្យ និងអនុវត្តកិច្ចមួយចំនួនដូចជា ការរៀបចំឯកសារសំណុំរឿង ក្នុងការពិភាក្សានៅចំពោះមុខតុលាការ ក្នុងការដាក់បន្ទុក ដែលជាមូលដ្ឋាននៃការចោទប្រកាន់ ឬដើម្បីការពារដល់ការចោទប្រកាន់របស់ខ្លួន។[144]

[142] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៦

[143] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៣០៤

[144] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, អង្គអយ្យការ, កម្រងសារណា, ផៃ ចេងសេង, ឆ្នាំ២០១៧

### ៣.៣.២. នៅពេលសវនាការ

ព្រះរាជអាជ្ញាជាភាគីម្ខាងនៅក្នុងសវនាការរឿងក្តីព្រហ្មទណ្ឌ ជាម្ចាស់នៃបណ្តឹងអាជ្ញា ការពារផលប្រយោជន៍សាធារណៈដែលតម្រូវឱ្យមានវត្តមានជាដាច់ខាត ប៉ុន្តែនៅក្នុងសវនាការលើបណ្តឹងរដ្ឋប្បវេណី មិនតម្រូវឱ្យមានវត្តមាននោះទេ។ មុខងារចៅក្រម និងព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងនោះគឺ មានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ។[145]

នៅពេលពិភាក្សាដេញដោល ព្រះរាជអាជ្ញា អាចត្រូវបានអនុញ្ញាតឱ្យចោទជាសំណួរទៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងសាក្សីជាដើម ប៉ុន្តែត្រូវទទួលការអនុញ្ញាតពីប្រធានសវនាការ។ លើសពីនេះ ព្រះរាជអាជ្ញាអាចជំទាស់នឹងការស្តាប់ចម្លើយសាក្សី បើខ្លួនយល់ឃើញថា ចម្លើយនេះគ្មានប្រយោជន៍ដល់ការសម្តែងការពិត ក្នុងករណីមានការតវ៉ា ការសម្រេចថាស្តាប់ ឬមិនស្តាប់ចម្លើយសាក្សីគឺស្ថិតលើការសម្រេចចិត្តរបស់ប្រធានសវនាការ។

ក្រោយបញ្ចប់ការពិភាក្សាដេញដោល ព្រះរាជអាជ្ញាត្រូវបានប្រធានតុលាការផ្តល់សិទ្ធិក្នុងការនិយាយជាបន្តបន្ទាប់ ដោយធ្វើការសន្និដ្ឋានប្តឹងសុំ ដោយផ្ទាល់មាត់ដែលខ្លួនយល់ឃើញថា សមស្របទៅនឹងប្រយោជន៍ល្អនៃយុត្តិធម៌[146]។ ក្រោយតុលាការថយខ្លួនចូលបន្ទប់ពិភាក្សាដើម្បីពិភាក្សា គ្មានបណ្តឹងសុំណាមួយត្រូវដាក់ជូនតុលាការទៀតឡើយ ហើយព្រះរាជអាជ្ញា មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការពិភាក្សាសម្រេចនេះទេ[147]។

[145] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ២៨៨

[146] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៣៣៦

[147] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៣៣៧ កថាខណ្ឌទី២

# ជំពូកទី៤

# អយ្យការក្នុងការអនុវត្តទោស

# ជំពូកទី៤
# អយ្យការក្នុងការអនុវត្តទោស

នៅក្រោយសវនាការត្រូវបានបញ្ចប់ តុលាការនឹងធ្វើការចេញនូវសេចក្តីសម្រេច ដោយមានការចេញនូវដីកាឱ្យដំណឹងជាមុនសិន។ ដីកាឱ្យដំណឹងគឺជាលិខិតដែលឱ្យដំណឹងពីសេចក្តីសម្រេចរបស់តុលាការ ដែលបញ្ញត្តិច្បាប់តម្រូវឱ្យមានការជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដើម្បីឱ្យភាគីពាក់ព័ន្ធបានដំណឹងអំពីសេចក្តីសម្រេចនោះ ដែលដីកានេះត្រូវបានធ្វើឡើងដោយគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា។[148]ការជូនដំណឹងដែលធ្វើឡើងដោយព្រះរាជអាជ្ញា ជូនដល់ភាគីពាក់ព័ន្ធ ព្រះរាជអាជ្ញាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការឱ្យដល់ភាគីពាក់ព័ន្ធ ព្រមទាំងចុះពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង ហើយគូភាគីពាក់ព័ន្ធត្រូវចុះហត្ថលេខានៅលើនោះផងដែរ។[149]

នៅក្នុងការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវបានធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់អយ្យការ[150] ហើយការអនុវត្តទោសនឹងត្រូវបានធ្វើឡើងនៅពេលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ[151] និងអាចស្នើសុំកងកម្លាំងសាធារណៈបានដើម្បីធានារ៉ាប់រងការអនុវត្តទោស។

## ៤.១. វិធានទាក់ទងការឃុំខ្លួន

- ការគណនាថេរវេលានៃការដាក់ពន្ធនាគារគឺៈ
- ១ថ្ងៃ មានថិរវេលា ២៤ម៉ោង
- ១ខែ មានថេរវេលា ៣០ថ្ងៃ
- លើសពី ១ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី១ ទៅលេខរៀងនៃថ្ងៃក្នុងខែមួយទៀត
- ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនោក្នុងចន្លោះពីម៉ោង ៦ព្រឹក ដល់១៨ល្ងាច។

ថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោស ដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុប នៃទោស។ ដូច្នេះ ជាគោលការណ៍មុននឹងមានការឃុំខ្លួនរបស់បុគ្គលណាម្នាក់ ដាច់ខាតត្រូវតែមានលិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

[148] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៨២
[149] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៨៤
[150] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៩៦ កថាខណ្ឌទី១
[151] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៤៩៧ កថាខណ្ឌទី១

### ៤.១.១. ការគ្រប់គ្រងពន្ធនាគារ

គោលដៅជាសារវន្តនៃការគ្រប់គ្រងជនជាប់ឃុំគឺ ការអប់រំ កែប្រែ និងស្តានីតិសម្បទាររបស់ជនជាប់ឃុំ ដែលជាស្នូលនៃក្របខណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ រីឯការដាក់ពិន័យលើជនជាប់ចោទ គឺធ្វើឡើងក្នុងកម្រិតអប្បបរមាដែលចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ប៉ុណ្ណោះ។[152] ទាក់ទងទៅនឹងការបែងចែកទណ្ឌិតនៅតាមពន្ធនាគារ និងមណ្ឌលឃុំខ្លួននានា គឺត្រូវបានចេញដោយប្រកាសរបស់ក្រសួងគ្រប់គ្រងពន្ធនាគារ។ ជាងនេះទៅទៀត នៅគ្រប់ពន្ធនាគារ និងមណ្ឌលឃុំខ្លួនត្រូវមានបញ្ជីមួយដែលទាក់ទងនឹងអត្តសញ្ញាណរបស់បុគ្គលឃុំខ្លួន កាលបរិច្ឆេទឃុំខ្លួន និងដោះលែង[153]។ បញ្ជីនេះត្រូវបានត្រួតពិនិត្យជារឿយៗដោយអយ្យការ ហើយទំព័រនីមួយត្រូវតែចុះទិដ្ឋាការដោយអយ្យការ។ ម្យ៉ាងវិញទៀត មុននឹងជនជាប់ឃុំត្រូវបានយកចីលក្នុងពន្ធនាគារ ត្រូវមានការត្រួតពិនិត្យ និងគោរពបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារដូចជា ហាមមិនឱ្យមានគ្រឿងស្រវឹង វត្ថុដែលហាមឃាត់ដែលអាចគំរាមគំហែងដល់សន្តិសុខពន្ធនាគារនោះទេ។ ដូច្នេះករណីមានអំពើ ឬឧប្បត្តិហេតុដែលប៉ះពាល់ដល់សុវត្ថិភាព និងសន្តិសុខពន្ធនាគារ ប្រធានពន្ធនាគារត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា អភិបាលខេត្ត រាជធានី និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ។[154]

### ៤.១.២. ការធ្វើអធិការកិច្ចពន្ធនាគារ

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំ។[155] តាមរយៈយន្តការបង្ការថ្នាក់ជាតិ ត្រូវបានអនុញ្ញាតឱ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានា បានគ្រប់ពេលវេលា និងធ្វើការសម្ភាសសម្ងាត់ជាមួយជនជាប់ឃុំ ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍ក្នុងការកែលម្អ សំដៅការបង្ការទារុណកម្ម អំពើឃោរឃៅ ឬអមនុស្សធម៌។[156] គ្រប់ឧប្បត្តិហេតុធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ដូចជាករណីដែលអ្នកទោសរត់ចេញពីពន្ធនាគារ នោះព្រះរាជអាជ្ញាចេញបញ្ជាស្វែងរកចាប់ខ្លួន និងចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តបញ្ជាស្វែងរកចាប់ខ្លួន ដោយអនុឡោមមាត្រា ១៩៦ និងមាត្រាបន្តបន្ទាប់នៃក្រមនេះ។[157]

---

[152] ច្បាប់ស្តីពី ពន្ធនាគារ, លេខ នស/រកម/១២១១/០២៤, ២១ ធ្នូ ២០១១, មាត្រា ៤២

[153] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥០៥

[154] ច្បាប់ស្តីពី ពន្ធនាគារ, ២១ ធ្នូ ២០១១, មាត្រា ៤៨

[155] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥០៩

[156] ច្បាប់ស្តីពី ពន្ធនាគារ, លេខ នស/រកម/១២១១/០២៤, ២១ ធ្នូ ២០១១, មាត្រា ៥៤ កថាខណ្ឌទី២

[157] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥១១

## ៤.២. ការដោះលែងដោយមានលក្ខខណ្ឌ

❖ ជាទូទៅអ្នកទោសត្រូវបានដោះលែង កាលណា៖

– នៅពេលផុតកំណត់ទោស

– នៅពេលអនុញ្ញាតឱ្យដាក់ប្រាក់ធានាឱ្យនៅក្រៅឃុំ ដោះលែងដោយមានលក្ខខណ្ឌដោះលែងបណ្តោះអាសន្ន

– នៅពេលលើកលែងការចោទប្រកាន់

– នៅពេលនិរទេសខ្លួនទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច ដោយមានការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់តុលាការមមានសមត្ថកិច្ច។

– នៅពេលលើកលែងទោសដោយព្រះមហាក្សត្រចំពោះទោសដែលនៅសេសសល់។[158]

ការដោះលែងដោយមានលក្ខខណ្ឌនៅទីនេះ គឺត្រូវគោរពនូវលក្ខខណ្ឌដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ដែលលក្ខខណ្ឌនោះមាន៖

❖ **លក្ខខណ្ឌទាក់ទងនឹងគំនិតមាយាទ៖** ករណីដែលទណ្ឌិតទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនឱ្យទៅរស់នៅក្នុងសង្គមវិញបាន។

❖ **លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចរាល់៖** អាចត្រូវបានផ្តល់ឱ្យទណ្ឌិតដែលទទួលរងទោសជាប់ពន្ធនាគារចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះតិចជាង ឬស្មើ១ឆ្នាំ និងចំនួន២/៣នៃទោស ក្នុងករណីផ្សេងទៀត។ ទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌប្រសិនបើទណ្ឌិតបានទទួលជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ឆ្នាំរួចមកហើយ។

បន្ទាប់ពីទទួលបានពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ពីប្រធានតុលាការដំបូងនៃទីកន្លែងឃុំខ្លួន គណៈកម្មការជាតិត្រូវបញ្ចេញជាយោបល់របស់ខ្លួនក្នុងរយៈពេលខ្លី ដោយមានសំអាងហេតុ ទៅប្រធានសាលាដំបូងវិញភ្លាម។ ទាក់ទងនឹងសេចក្តីសម្រេចរបស់ប្រធានតុលាការដំបូង អាចនឹងត្រូវបានតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល៥ថ្ងៃ ហើយបណ្តឹងតវ៉ានេះអាចធ្វើបានដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញានៃតុលាការសាមីតែប៉ុណ្ណោះ។[159] ម៉្យាងវិញទៀត ករណីដែលទណ្ឌិតមិនបានគោរពតាមលក្ខខណ្ឌ

[158] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ, លេខ២១៧ របស់ក្រសួងមហាផ្ទៃ, ប្រការទី៤ ចំណុចទី៤(ក)

[159] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥១៦

ដែលកំណត់ដោយដីការទេនោះ សេចក្តីសម្រេចនោះអាចនឹងត្រូវបានដកហូត ហើយព្រះរាជអាជ្ញា អាចបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតដែលបានដោះលែងនោះបាន។[160]

## ៤.៣. ការបង្ខំរូបកាយ

ការបង្ខំរូបកាយគឺជានីតិវិធីមួយដែលត្រូវអនុវត្តលើបុគ្គលដែលត្រូវបានតុលាការផ្តន្ទាទោសហើយ ប៉ុន្តែមិនព្រមបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង ជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី។[161] កាលបើផុតរយៈកាលនៃការបង់ប្រាក់នោះហើយ ឱ្យដំណឹងថាប្រសិនបើមិនបង់ទេនោះ សាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ ដែលរយៈពេលនេះមិនអាចតិចជាង១០ថ្ងៃនោះទេ។ លុះផុតរយៈពេលកំណត់នេះទៀត ទណ្ឌិតមិនបានបង់ប្រាក់ ព្រះរាជអាជ្ញានឹងចេញបញ្ជាឱ្យបង្ខំ និងឃុំខ្លួន។[162]

[160] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥១៩

[161] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥២៣

[162] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧, មាត្រា ៥២៦

# សេចក្ដីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវនូវប្រធានបទ «តួនាទីអយ្យការនៅក្នុងដំណើរការនីតិព្រហ្មទណ្ឌនៃសាលាដំបូងរាជធានី-ខេត្ត» រួចមក យើងពិនិត្យឃើញថា អយ្យការគឺមានតួនាទីសំខាន់ណាស់ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ព្រោះមានតែអយ្យការទេ ដែលមានសិទ្ធិចោទប្រកាន់ ឬជាម្ចាស់បណ្ដឹងអាជ្ញា ក្នុងបទល្មើសព្រហ្មទណ្ឌមួយ និងជាតួអង្គដ៏សំខាន់ក្នុងការធ្វើយ៉ាងណា រកឱ្យឃើញពីពិរុទ្ធភាពរបស់ជនល្មើស និងជួយការពារផលប្រយោជន៍សាធារណៈដល់សង្គមជាដើម។ ជាពិសេសស្ថាប័នមួយនេះ ក៏ត្រូវបានច្បាប់រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សិទ្ធិអំណាចសំរាប់ ធ្វើការចោទប្រកាន់នៅក្នុងរឿងក្ដីព្រហ្មទណ្ឌឱ្យស្របទៅតាមនីតិវិធីនៃច្បាប់ និងមានតម្លាភាព។ បន្ថែមពីនេះទៀត ដើម្បីឱ្យកិច្ចចោទប្រកាន់ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌមួយមានភាព សុក្រឹត្យ និងអព្យាក្រឹត្យ ឱ្យស្របតាមច្បាប់ ព្រះរាជអាជ្ញាត្រូវដើរតួនាទីយ៉ាងចាំបាច់ក្នុងការកិច្ចធានារាល់ការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ដោយត្រូវឈរលើមូលដ្ឋានច្បាប់ជាក់លាក់ និងត្រូវតែអនុវត្តតាមគោលការណ៍ណែនាំស្ដីពី តួនាទីរបស់ព្រះរាជអាជ្ញា។

តាមរយៈកិច្ចការស្រាវជ្រាវនេះ យើងក៏សង្កេតឃើញថា អយ្យការត្រូវបានប្រគល់អំណាចយ៉ាងធំធេង ក្នុងការចូលរួមនៅគ្រប់ដំណាក់កាលនីតិវិធីព្រហ្មទណ្ឌចាប់តាំងពីការកើតមាននូវបទល្មើស រហូតដល់ការអនុវត្តទោស ដោយធ្វើការប្រមូលនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុក សម្រាប់ជាមូលដ្ឋាននៃការចោទប្រកាន់ ដែលជាតួនាទីចម្បងរបស់ព្រះរាជអាជ្ញា។ នៅក្នុងការបំពេញតួនាទីរបស់ខ្លួន ព្រះរាជអាជ្ញា ត្រូវប្រកាន់ខ្ជាប់នូវសុក្រឹត្យ ក៏ជាគោរពតាមវិជ្ជាជីវៈ ដែលកាតព្វកិច្ចដ៏សំខាន់បំផុតរបស់ គឺស្វែងរកភាពយុត្តិធម៌ជូនជនរងគ្រោះ យ៉ាងម៉ត់ចត់ និងយកចិត្តទុកដាក់ដោយសុចរិត និងត្រឹមត្រូវ។ ហេតុនេះ យើងសង្កេតឃើញថា នៅក្នុងដំណើរការដោះស្រាយតាមនីតិវិធីរបស់អង្គការអយ្យការ ទៅលើបញ្ហារឿងក្ដីព្រហ្មទណ្ឌ គឺមានគោលដៅតែមួយគត់ ធ្វើយ៉ាងណាចាប់ជនល្មើស និងជនឧក្រិដ្ឋ ហើយផ្ដល់ភាពយុត្តិធម៌ដល់ជនរងគ្រោះ ឱ្យបានសមស្របតាមច្បាប់។

សរុបជារួមមក តួនាទី និងភារកិច្ចរបស់ អង្គការអយ្យការនៅក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌ គឺពិតជាមានសារសំខាន់ណាស់ សម្រាប់ប្រព័ន្ធតុលាការនៅប្រទេសកម្ពុជារបស់យើង។ ហេតុដូច្នេះ ដាច់ខាតគឺតម្រូវឱ្យព្រះរាជអាជ្ញាមាន ចំណេះដឹងជ្រៅជ្រះ មានសមត្ថភាពខ្ពស់, មានបទពិសោធន៍ច្រើនឆ្នាំ ទាំងផ្នែកនីតិសាស្ត្រ រួមទាំងផ្នែកសង្គម និងក្នុងនាមជាព្រះរាជអាជ្ញាគប្បីត្រូវប្រកាន់ភ្ជាប់នូវ ភាពយុត្តិធម៌ វែកញែក រកភាពត្រឹមត្រូវប្រកបដោយមនសិកា ដោយគោរពតាមក្រមសីលធម៌របស់ខ្លួន និងមិនលំអៀង ដើម្បីធានាបាននូវប្រសិទ្ធិភាព និងតម្លាភាព ជូនដល់សាធារណៈជន និងជួយឱ្យសង្គមជាតិទាំងមូលទទួលបាន អធិបតេយ្យភាពក៏ដូចជាមានរបៀបរៀបរយផងដែរ។

# អនុសាសន៍

តួនាទីអង្គការអយ្យការនៅក្នុងដំណើរការអនុវត្តនៃរឿងក្តីព្រហ្មទណ្ឌ គឺពិតជាបានដើរតួនាទីដ៏មានសារៈសំខាន់ណាស់នៅក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ឱ្យមានភាពត្រឹមត្រូវ និងកាន់តែមានតម្លាភាព នៅក្នុងប្រព័ន្ធយុត្តិធម៌តុលាការនៃព្រះរាជាណាចក្រកម្ពុជា។ តែទោះជាយ៉ាងណា ដើម្បីឱ្យកាន់តែមានប្រសិទ្ធិភាពនូវរាល់សកម្មភាពទាំងអស់នោះត្រូវមានដូចខាងក្រោម៖

១. ផ្តល់ការអប់រំ និងជួយផ្សព្វផ្សាយទៅដល់មន្ត្រីទាំងឡាយដែលកំពុងតែអនុវត្តច្បាប់ ទាក់ទងទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗ ឱ្យមានចំណេះដឹងទូលំទូលាយហើយមានប្រសិទ្ធិភាព និងត្រឹមត្រូវទៅតាមច្បាប់កំណត់ និងមានចែងនៅក្នុងក្រម និងច្បាប់ផ្សេងៗ។ ជាពិសេស គឺផ្តល់នូវគំនូដ៏សំខាន់ នៅក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ បានផ្តល់នូវគំរូទៅកាន់មន្ត្រីផ្សេងៗ ក៏ដូចជាធ្វើឱ្យប្រជាពលរដ្ឋ គោរពស្រលាញ់ និងមានភាពជឿជាក់លើប្រព័ន្ធយុត្តិធម៌របស់តុលាការ។

២. ជួយបង្កើនធនធានមនុស្ស ដែលមានចំណេះ ជំនាញ ពិតប្រាកដ នៅក្នុងប្រព័ន្ធតុលាការមានដូចជាចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីនគរបាលយុត្តិធម៌ ដែលការជ្រើសរើស តាមរយៈការប្រឡងប្រកួតប្រជែង និងបណ្តុះបណ្តាល ត្រូវប្រកបតាមក្រមសីលធម៌វិជ្ជាជីវៈ ពីព្រោះថានៅពេលដែលបានអនុវត្តនៅក្នុងប្រព័ន្ធដំណើរការនីតិវិធីនៃតុលាការ ចៀសវាងការយឺតយ៉ាវ និងចំណុចខ្វះខាត នូវធនធានមនុស្ស ដែលមានជំនាញវិជ្ជាជីវៈ នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ។

៣. ជាការជួយលើកទឹកចិត្ត ទៅដល់មន្ត្រីដែលធ្វើការនៅក្នុងប្រព័ន្ធយុត្តិធម៌ តាមរយៈការតំឡើងប្រាក់បៀវត្ស ឱ្យបានសមរម្យឱ្យបានសមមាត្រទៅនឹងការបំពេញតួនាទីភារកិច្ចរបស់ពួកគាត់ និងដោយគិតពីជីវភាពនៃការរស់នៅរបស់គាត់ផងដែរ ដើម្បីចៀសវាងកុំមានអំពើពុករលួយកើតមានឡើង នៅក្នុងប្រព័ន្ធតុលាការ ដោយសារមូលហេតុកង្វះខាតក្នុងការផ្គត់ផ្គង់ជីវភាព និងការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ដោយមិនបាលផ្តល់ប្រាក់បៀវត្សគ្រប់គ្រាន់ ក៏ជាបញ្ហាមួយដែលប៉ះពាល់ទៅដល់ប្រព័ន្ធយុត្តិធម៌ផងដែរ។

៤. សូមសំណូមពរឱ្យមានការត្រួតពិនិត្យឡើងវិញឱ្យបានល្អិតល្អន់ពីអនុវត្តន៍ តួនាទី និងការបំពេញភារកិច្ចរបស់អង្គការអយ្យការ នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ។ តើកិច្ចដំណើរការរបស់អយ្យការ បានដំណើរការស្របតាមក្រមនីតិវិធី ក៏ដូចជាច្បាប់ផ្សេងៗហើយ ឬនៅ? មួយទៀត សំណូមពរបង្កើតឱ្យមានអង្គការ ឬស្ថាប័នដើម្បីតាមដាន និងធ្វើការត្រួតពិនិត្យ ក៏ដូចជាធ្វើការវាយតម្លៃចំពោះប្រព័ន្ធនៃភាពយុត្តិធម៌របស់តុលាការ ថាបានអនុវត្តបានកម្រិតណា? តើដំណើរការនៃនីតិវិធី នៅក្នុងការជំនុំជម្រះប្រព្រឹត្តទៅប្រកបកដោយភាពត្រឹមត្រូវ និងប្រសិទ្ធិហើយឬនៅ?

# ឯកសារយោង

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តិជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩។

៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ២០០៧

៤. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤។

៥. ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ ។

៦. ច្បាប់ស្តីពីពន្ធនាគារ លេខ នស/រកម/១២១១/០២៤, ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ ។

៧. ច្បាប់ស្តីពីកិច្ចការពារអនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦។

៨. សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយសហប្រតិបត្តិការបារាំងគំរោងទ្រទ្រង់នីតិរដ្ឋ, ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៦ ។

៩. ក្រសួងមហាផ្ទៃស្តីពីគ្រប់គ្រងពន្ធធនាគារ ប្រកាសលេខ, ២១៧ អនក្រ. ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ ។

## II. លិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ

១. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៦។

២. គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី ៨ ស្តីអំពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា ប្រទេសគុយបា ចុះនៅថ្ងៃទី ២៧ ខែសីហា ដល់ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ១៩៩០។

៣. សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨។

## III. ឯកសារជាសៀវភៅ

១). លោក **កុយ នាម** និង **ឡុងបញ្ញាវុឌ្ឍ**, សៀវភៅ អង្គការអយ្យការ (ប្រវត្តិនិងការសិក្សាប្រៀបធៀប), ភ្នំពេញ, បោះពុម្ពលើកទី១, ឆ្នាំ២០០៦។

២). **លោករុន ពណ្ណារិទ្ធ** និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, នីតិវិធីព្រហ្មទណ្ឌ, ឆ្នាំសិក្សា២០២២។

៣. សៀវភៅមគ្គុទេសក៍ស្តីពី នីតិវិធីព្រហ្មទណ្ឌនៅតុលាការកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, សីហា ២០១៣ ។

៤. **សេង ស៊ីវុត្ថា**,ប្រធានសាលាឧទ្ធរណ៍ សៀវភៅ នីតិវិធីព្រហ្មទណ្ឌខ្មែរ, សម្រាប់ថ្នាក់ឧត្តមសិក្សា។

៥. កម្រងសារណា ផៃ ចេងសេង, អង្គការអេយ្យការ, ឆ្នាំ២០១៧។

៦. **ចក សម្បត្តិ**, អត្ថបទខ្លីសាកល្បងពន្យល់ស្តីពី ការឃាត់ខ្លួន

៧. សមាគមសាលាត្រាជូ, **ចក សម្បត្តិ**, ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

៨. **ចក សម្បត្តិ**, អត្ថបទសំខាន់ៗទាក់ទងនឹងផ្នែកព្រហ្មទណ្ឌ

IV. **ឯកសារតាម** Internet

- នីតិវិធីមុនការជំនុំជម្រះ និងការជំនុំជម្រះ, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ខែសីហា ឆ្នាំ២០១៣ https://cchrcambodia.org/admin/media/report/report/khmer/2013_08_26_tmp_Procedure_Handbook_August_2013_khm.pdf (ចូលទស្សនាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២)
- **ស៊ាងសំភាស់**,វិធានការនិរន្តរាយ https://drive.google.com/file/d/1GCnLgQTAGLxzMlf_foQZYVzf-1n9JfeW/view (ចូលទស្សនាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២)

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១៖**

- ដីកាកោះ

**ឧបសម្ព័ន្ធ២៖**

- ដីកាបញ្ជាឱ្យចូលខ្លួន

**ឧបសម្ព័ន្ធ៣៖**

- ដីកាឆែកឆេរលំនៅឋាន

**ឧបសម្ព័ន្ធ៤៖**

- កំណត់ហេតុទទួលវត្ថុចាប់យក

**ឧបសម្ព័ន្ធ៥៖**

- កំណត់ហេតុសួរចម្លើយ

**ឧបសម្ព័ន្ធ៦៖**

- ដីកាបង្គាប់ឱ្យចាប់ខ្លួន

**ឧបសម្ព័ន្ធ៧៖**

- កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

**ឧបសម្ព័ន្ធ៨៖**

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**ឧបសម្ព័ន្ធ៩៖**

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

**ឧបសម្ព័ន្ធ១០៖**

- ដីកាសម្រេច

**ឧបសម្ព័ន្ធ១១៖**

- ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្តោះអាសន្ន

**ឧបសម្ព័ន្ធ១២៖**

- ដីកាបង្គាប់ឱ្យឃុំខ្លួន

**ឧបសម្ព័ន្ធ១៣៖**

- ដីកាផ្ទេរសមត្ថកិច្ច

**ឧបសម្ព័ន្ធ១៤៖**

- ដីកាបង្គាប់ឱ្យដោះលែង

**ឧបសម្ព័ន្ធ១៥៖**

- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

**ឧបសម្ព័ន្ធ១៦៖**

- ដីកាសន្និដ្ឋានស្ថាពរ

**ឧបសម្ព័ន្ធ១៧៖**

- លិខិតជូនដំណឹង

**ឧបសម្ព័ន្ធ១៨៖**

- ដីកាតម្កល់រឿងទុកឥតចាត់ការ

**ឧបសម្ព័ន្ធ១៩៖**

- សេចក្តីសុំប្តឹងតវ៉ា

**ឧបសម្ព័ន្ធ២០៖**

- សេចក្តីចម្លងបណ្តឹងតវ៉ា

ឧបសម្ព័ន្ធ១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ..............
ចុះថ្ងៃទី ......... ខែ ......... ឆ្នាំ .........

## ដីកាកោះ

យើង ........................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញឈ្មោះ ..........................................................................................................

ទីលំនៅសព្វថ្ងៃ ..................... ផ្លូវ ................... ភូមិ ............................. សង្កាត់ .................................

ខណ្ឌ .......................................... រាជធានីភ្នំពេញ។

អោយចូលទៅកាន់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

នៅថ្ងៃទី ................ ខែ ................ ឆ្នាំ ................ វេលាម៉ោង ....................................................

ដើម្បី ..........................................................................................................................

ពីដំណើររឿង ..................................................................................................................

..................................................................................................................................

សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះ អោយបានទាន់ពេលវេលា និងយក លិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ

តំណាងអយ្យការ

ឧបសម្ព័ន្ធ២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យ្យការអម
ៈបូងរាជធានីភ្នំពេញ
................ អ.យ

## ដីកាបញ្ជាឱ្យចូលខ្លួន[១]

យើង .................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ ..........................................................................................

.......................................................................................................... ។

-បានឃើញមាត្រា ៣៧[២] , ៩៤[៣] និងមាត្រា ១១៤[៤] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាម ព្រះរាជក្រមលេខ : នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

បញ្ជា

នាម-គោត្តនាម ........................ ហៅ ................ ភេទ □ប្រុស-□ស្រី អាយុ ....... ឆ្នាំ

ជាតិ .................. របររកស៊ី ..........................................................

ទីកន្លែងកំណើត ............ ឃុំ-សង្កាត់ ............ ស្រុក-ខណ្ឌ ............ ខេត្ត-រាជធានី ............

ទីលំនៅបច្ចុប្បន្ន ..........................................................................

ទោសពីមុន ......... ឪពុកឈ្មោះ ................ "□រ-□ស" ម្តាយឈ្មោះ ................ "□រ-□ស"

ប្តី ឬ ប្រពន្ធឈ្មោះ ................ "□រ-□ស" មានកូន .......... ឬ □នៅលីវ - □អនីតិជន ឬ □នីតិជន ។

ឱ្យចូលបង្ហាញខ្លួននៅ ..................................................................

ឱ្យបានមុនថ្ងៃទី ........................... នៅវេលារាល់ម៉ោងធ្វើការ ដើម្បីសាកសួរលើបណ្តឹងព្រហ្មទណ្ឌ ពីបទ :

.......................................................................................................... ។

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ

តំណាងអយ្យការ

---

១ ដីកានេះអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំង សាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួនបាន

២ អំណាចរបស់ព្រះរាជអាជ្ញា

៣ ករណីស៊ើបអង្កេតជាក់ស្តែង

៤ ករណីស៊ើបអង្កេតបឋម

ឧបសម្ព័ន្ធ៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

ដំបូងរាជធានីភ្នំពេញ

........................ អ.យ

## ដីកាឆែកឆេរលំនៅដ្ឋាន

យើង ........................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

-បានឃើញ ..............................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

### យល់ឃើញថា :

ដើម្បីរុករកវត្ថុតាង និងបង្ក្រាបបទល្មើសទាក់ទិនករណីខាងលើ ..................................................

..............................................................................................................................

............................................................................... ធ្វើការឆែកឆេរលំនៅដ្ឋានខាងលើ ។

### ហេតុដូច្នេះសំរេច :

-ឆែកឆេរលំនៅដ្ឋានផ្ទះលេខ .............. ផ្លូវ ........... ភូមិ .................... សង្កាត់ .................. ខណ្ឌ .................... រាជធានីភ្នំពេញ ។

រាជធានីភ្នំពេញ ; ថ្ងៃទី ......... ខែ .......... ឆ្នាំ

តំណាងអយ្យការ

ឧបសម្ព័ន្ធ៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ:...............................អយណ

## កំណត់ហេតុទទួលវត្ថុចាប់យក

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែឧសភា ថ្ងៃទីសាមសិប វេលាម៉ោងដប់បួន និងសូន្យនាទី ។

យើង [redacted] ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញជា អ្នកទទួល ។

លោក [redacted] ជាមន្ត្រីនគរបាលយុត្តិធម៌ ខណ្ឌចំការមន ជាអ្នកប្រគល់។

បានពិនិត្យកិនភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ............ ចុះថ្ងៃទី...... ខែ..............ឆ្នាំ២០១៦ ឃើញមានដូចខាងក្រោម :

-ប្រដាប់ផ្ទុកទិន្នន័យរូបភាព (Flash) ចំនួន ០១ ។

យើងធ្វើកំណត់ហេតុនេះទុកជាភស្តុតាដើម្បីសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ............... ចុះថ្ងៃទី........ខែ................ឆ្នាំ២០១៦ តាមផ្លូវច្បាប់តទៅ ។

បញ្ចប់កំណត់ហេតុនេះនៅវេលាម៉ោងដប់បួន និងដប់ប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដូចខាងលើ។

| | | |
|---|---|---|
| ជនសង្ស័យ | អ្នកប្រគល់ | អ្នកទទួល |

**បានឃើញ**

រាជធានីភ្នំពេញ ,ថ្ងៃទី........ខែ...........ឆ្នាំ ២០១៦

**ជ.ព្រះរាជអាជ្ញា**

ឧបសម្ព័ន្ធ៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ ...........
ចុះថ្ងៃទី....... ខែ............ ឆ្នាំ២០១៦

## <u>កំណត់ហេតុសួរចម្លើយ</u>

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែមិថុនា ថ្ងៃទីពីរ វេលាម៉ោងដប់បួន និងសូន្យនាទី។

យើង [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ដោយមានលោក [redacted] ជាក្រឡាបញ្ជីអមផងបានសួរកត់យកចម្លើយឈ្មោះ **កកកកកក** ជាដើមបណ្តឹង។

**សួរ-ឆ្លើយ** : នាងខ្ញុំឈ្មោះ **កកកកកក** អាយុ ៤១ ឆ្នាំ មុខរបរ មេផ្ទះ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៤៨១ ផ្លូវលេខវ៉ាដា ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ **ខខខខខ** (ស) ម្តាយឈ្មោះ **គគគគគគ** (ស) ប្តីឈ្មោះ **ឃឃឃឃ** (រ) មានកូនចំនួន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន។

**សួរ-ឆ្លើយ** : កាលពីថ្ងៃខែមិនចាំ ក្នុងឆ្នាំ២០១៥ វេលាម៉ោងប្រហែល ១១ ថ្ងៃត្រង់ ឈ្មោះ **ឃឃឃឃ** ជាប្តី ឈ្មោះ **ងងងង** និងឈ្មោះ **ចចចចច** ជាឪពុកម្តាយក្មេក ឈ្មោះ **ឆឆឆឆ** និងឈ្មោះ **ជជជជ** ត្រូវជាបងថ្លៃ បានព្រួតគ្នាប្រើអំពើហិង្សាវាយដំលើនាងខ្ញុំ បណ្តាលឲ្យមានរបួសយ៉ាងធ្ងន់ធ្ងរ និងគម្រាមកំហែងមកលើរូបនាងខ្ញុំជាញឹកញាប់ ថែមទាំងបក្សពួកខាងលើបណ្តេញនាងខ្ញុំចេញពីផ្ទះ ដែលកំពុងរស់នៅសព្វថ្ងៃ។ ឈ្មោះ **ឆឆឆឆ** និងឈ្មោះ **ជជជជ** បានលួងលោមនាងខ្ញុំថា ទៅធ្វើការដកដំឡូងនៅពេជនិល ដោយបានប្រាក់មួយថ្ងៃ ៣០,០០០ រៀល។ នៅពេលទៅដល់ពេជនិល ពួកគាត់បានដាក់ច្រវ៉ាក់ជើងនាងខ្ញុំ ដោយចោទថានាងខ្ញុំឆ្កួត ហើយយកគ្រួមកស្រោចទឹក និងធ្វើទារុណកម្មរាល់ថ្ងៃ ទោះនាងខ្ញុំអង្វរយ៉ាងណា ក៏គេមិនព្រមដោះច្រវ៉ាក់ដែរ។ ក្រោយមកបងប្រុសនិងបងស្រីរបស់នាងខ្ញុំ មកនាងខ្ញុំត្រលប់មកផ្ទះវិញ។

**សួរ-ឆ្លើយ** : សព្វថ្ងៃបក្សពួកខាងលើ បានបណ្តេញនាងខ្ញុំចេញពីផ្ទះ ដោយផ្ទះខាងលើជាទ្រព្យសម្បត្តិរបស់នាងខ្ញុំដែរ។

**សួរ-ឆ្លើយ** : ភស្តុតាងមាន រូបថតចំនួន ១០សន្លឹក ដែលបង្ហាញពីស្លាកស្នាមរបួស និងការបង្ខាំងទុក។

**សំណូមពរ** : សុំឲ្យតុលាការផ្តន្ទាទោសឈ្មោះ **ឃឃឃឃ**, ឈ្មោះ **ងងងង**, ឈ្មោះ **ចចចចច**, ឈ្មោះ **ឆឆឆឆ**, និងឈ្មោះ **ជជជជ** តាមច្បាប់ និងសុំទាមទារសំណងជំងឺចិត្ត ១០,០០០ ដុល្លារអាមេរិក។

ឈប់សួរសាមីខ្លួន បានអានឆ្លើយថាត្រឹមត្រូវ ហើយសុខចិត្ត ផ្តិតមេដៃជាមួយយើង។

**អ្នកឆ្លើយ** **ក្រឡាបញ្ជី** **ព្រះរាជអាជ្ញារង**

ឧបសម្ព័ន្ធ៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
ជំនុំជម្រះសាលាដំបូងរាជធានីភ្នំពេញ
.................... អ.យ

## ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង .................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសាលដីកាលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ .......... របស់ .................... ។

-បានឃើញពាក្យសុំអនុវត្តសាលដីកា ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ .......... របស់ .................... ។

-បានឃើញមាត្រា ៤៩៦ , ៥២៣ , ៥៣០ , ៥៣៣ និង មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ក្រោយពីបានពិនិត្យសព្វគ្រប់ ឃើញថា :

១- នាម-គោត្តនាម .................... ហៅ .................... ភេទ ☐ប្រុស-☐ស្រី អាយុ .......... ឆ្នាំ
ជាតិ .................... របររកស៊ី ....................
ទីកន្លែងកំណើត .................... ឃុំ-សង្កាត់ .................... ស្រុក-ខណ្ឌ .................... ខេត្ត-ក្រុង ....................
ទីលំនៅបច្ចុប្បន្ន ....................
ទោសពីមុន .......... ឪពុកឈ្មោះ .................... "☐រ-☐ស" ម្តាយឈ្មោះ .................... "☐រ-☐ស"
ប្តី ឬ ប្រពន្ធឈ្មោះ .................... "☐រ-☐ស" មានកូន .......... ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

២- នាម-គោត្តនាម .................... ហៅ .................... ភេទ ☐ប្រុស-☐ស្រី អាយុ .......... ឆ្នាំ
ជាតិ .................... របររកស៊ី ....................
ទីកន្លែងកំណើត .................... ឃុំ-សង្កាត់ .................... ស្រុក-ខណ្ឌ .................... ខេត្ត-ក្រុង ....................
ទីលំនៅបច្ចុប្បន្ន ....................
ទោសពីមុន .......... ឪពុកឈ្មោះ .................... "☐រ-☐ស" ម្តាយឈ្មោះ .................... "☐រ-☐ស"
ប្តី ឬ ប្រពន្ធឈ្មោះ .................... "☐រ-☐ស" មានកូន .......... ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

ជាប់ចោទពីបទ ....................
ប្រព្រឹត្តនៅ ....................
កាលពីថ្ងៃទី .......... ខែ .......... ឆ្នាំ .......... តាមបញ្ញត្តិមាត្រា ....................
នៃច្បាប់ .................... ។

-ឈ្មោះ .................... និងឈ្មោះ .................... ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ .......... ឆ្នាំ និងរួមគ្នាសងសំណងជម្ងឺចិត្តចំនួន .................... ទៅឱ្យដើមបណ្តឹងឈ្មោះ .................... តែរហូតមកដល់ពេលនេះជនជាប់ចោទទាំង ២នាក់ បានគេចវេសពុំព្រមសងសំណងជម្ងឺចិត្តទៅ ដើមបណ្តឹងទេ ។

# ហេតុដូច្នេះសម្រេច

បង្គាប់មកមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួន

១- នាម-គោត្តនាម ............................ ហៅ .................... ភេទ □ប្រុស-□ស្រី អាយុ ......... ឆ្នាំ
ជាតិ ..................... របររកស៊ី ..................................................................
ទីកន្លែងកំណើត ............... ឃុំ-សង្កាត់ ............... ស្រុក-ខណ្ឌ ............... ខេត្ត-ក្រុង ...............
ទីលំនៅបច្ចុប្បន្ន ..................................................................................
ទោសពីមុន ........... ឪពុកឈ្មោះ ..................... "□រ-□ស" ម្ដាយឈ្មោះ ..................... "□រ-□ស"
ប្ដី ឬ ប្រពន្ធឈ្មោះ ..................... "□រ-□ស" មានកូន ........... ឬ □នៅលីវ - □អនីតិជន ឬ □នីតិជន។

២- នាម-គោត្តនាម ............................ ហៅ .................... ភេទ □ប្រុស-□ស្រី អាយុ ......... ឆ្នាំ
ជាតិ ..................... របររកស៊ី ..................................................................
ទីកន្លែងកំណើត ............... ឃុំ-សង្កាត់ ............... ស្រុក-ខណ្ឌ ............... ខេត្ត-ក្រុង ...............
ទីលំនៅបច្ចុប្បន្ន ..................................................................................
ទោសពីមុន ........... ឪពុកឈ្មោះ ..................... "□រ-□ស" ម្ដាយឈ្មោះ ..................... "□រ-□ស"
ប្ដី ឬ ប្រពន្ធឈ្មោះ ..................... "□រ-□ស" មានកូន ........... ឬ □នៅលីវ - □អនីតិជន ឬ □នីតិជន។

អនុវត្តការបង្ខំដល់រូបកាយទារប្រាក់ធនទណ្ឌ ។

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ

**តំណាងអយ្យការ**

ឧបសម្ព័ន្ធ៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យ្យការអម

ដំបូងរាជធានីភ្នំពេញ

**កំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**[1]

ព្រហ្មទណ្ឌលេខ ..........

...... ខែ ......... ឆ្នាំ ..........

.................... អ.យ

ឆ្នាំពីរពាន់ .................. ខែ .............. ថ្ងៃទី ......................... វេលាម៉ោង .......................................... ។

**យើង** ......................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញសំណុំរឿងលេខ ................................. ចុះថ្ងៃទី .............. ខែ .............. ឆ្នាំ .............. របស់

.......................................................................................................................................................... ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម :

១- នាម-គោត្តនាម ................................ ហៅ .................... ភេទ □ប្រុស-□ស្រី អាយុ ......... ឆ្នាំ

ជាតិ ...................... របររកស៊ី ..........................................................................................

ទីកន្លែងកំណើត ............... ឃុំ-សង្កាត់ ............... ស្រុក-ខណ្ឌ ............... ខេត្ត-ក្រុង ...............

ទីលំនៅបច្ចុប្បន្ន ..........................................................................................................

ទោសពីមុន .......... ឪពុកឈ្មោះ ....................... "□រ-□ស" ម្ដាយឈ្មោះ ....................... "□រ-□ស"

ប្ដី ឬ ប្រពន្ធឈ្មោះ .................... "□រ-□ស" មានកូន ........... ឬ □នៅលីវ - □អនីតិជន ឬ □នីតិជន ។

យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ : ........................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

អង្គហេតុនេះជាបទល្មើស ..........................................................

ប្រព្រឹត្តនៅ ..........................................................

កាលពីថ្ងៃទី .............. ខែ .............. ឆ្នាំ .............. តាមបញ្ញត្តិមាត្រា ..............................

នៃច្បាប់ .......................................................... ។

យើងបានទទួលចម្លើយពីជននេះដូចតទៅ : ..........................................................

..........................................................................................................................................................................................
..........................................................................................................................................................................................
